# ព្រះ
# ត្រៃបិដកបាលី
## និង
## សេចក្តីប្រែជាភាសាខ្មែរ
# អភិធម្មបិដក
## កថាវត្ថុ ទុតិយភាគ

# ៨៥

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
ព.ស ២៥០៩

ឯកសារគម្ពីរព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពីច្បាប់គម្ពីរព្រះត្រៃបិដកដប៉ុន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥០០០ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ។

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ។

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ។

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ។

ថតស្កានដោយ
ប្អូនប្រុស ម៉ាន់ សាវ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងច្រើនលើសលុបពី៖

- ឧបាសិកា កាំង ហ៊ុចឈ័ណ (ភ្នំពេញ)
- ឧបាសក ជុត លីស្រ៊ុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សរ ចន និង ឧបាសិកា អ៊ូច សាទៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ីវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជឹម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផែង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ាទី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រ៊ុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រ៊ុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រ៊ុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រ៊ុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទួត សេរីស័ក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ែ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)
- ឧបាសិកា វ៉ាន់ លុយ និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- លោកស្រី ហួ ច័ន្ទសុវណ្ណ និងស្វាមី ព្រមទាំងបុត្រ (ស.រ.អ)

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# អភិធម្មបិដក
# កថាវត្ថុ ទុតិយភាគ
# ៨៥

ពុទ្ធសាសនបណ្ឌិត្យ

ព. ស. ២៥០៩

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្ចង់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ  ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនា
ជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណាប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូ ខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

| | | | |
|---|---|---|---|
| 世話人代表　無着　成恭 | 世話人 | 松永　然道 | 有馬　実成 |
| 事務局長　篠原　鋭一 | | 伊藤　佳通 | 渡井　奎一 |
| | | 杉谷　義純 | 茂田　真澄 |
| | | 前田　利勝 | 中島　教之 |
| | | 永　六輔 | |

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# អភិធម្មបិដក

## កថាវត្ថុ ទុតិយភាគ

៨៥

ព. ស. ២៥០៩

# អភិធម្មបិដកេ
# កថាវត្ថុស្ស ទុតិយោ ភាគោ
## បរូបហារកថា

(១) អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ អត្ថិ អរហតោ រាគោ កាមរាគោ កាមរាគបរិយុដ្ឋានំ កាមរាគសញ្ញោជនំ កាមោឃោ កាមយោគោ កាមច្ឆន្ទនីវរណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២) នត្ថិ អរហតោ រាគោ កាមរាគោ កាមរាគបរិយុដ្ឋានំ កាមរាគសញ្ញោជនំ កាមោឃោ កាមយោគោ កាមច្ឆន្ទនីវរណន្តិ ។ អាមន្តា ។ ហញ្ចិ នត្ថិ អរហតោ រាគោ កាមរាគោ កាមរាគបរិយុដ្ឋានំ កាមរាគសញ្ញោជនំ កាមោឃោ កាមយោគោ កាមច្ឆន្ទនីវរណំ នោ ច វត រេ វត្តព្វេ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

(៣) អត្ថិ បុថុជ្ជនស្ស អសុចិសុក្កវិសដ្ឋិ អត្ថិ តស្ស រាគោ កាមរាគោ កាមរាគបរិយុដ្ឋានំ កាមរាគសញ្ញោជនំ កាមោឃោ កាមយោគោ កាមច្ឆន្ទនីវរណន្តិ ។ អាមន្តា ។ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋិ អត្ថិ តស្ស រាគោ កាមរាគោ កាមរាគបរិយុដ្ឋានំ ។ បេ ។ កាមច្ឆន្ទនីវរណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# អភិធម្មបិដក

## កថាវត្ថុ ទុតិយភាគ

## បរូបហារកថា

(១) (សកវាទីសួរថា) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ (បរវាទី ឆ្លើយថា) អើ ។ រាគៈ កាមរាគៈ បរិយុដ្ឋានៈ គឺកាមរាគៈ សញ្ញោជនៈ គឺកាមរាគៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ របស់ព្រះអរហន្ត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២) រាគៈ កាមរាគៈ បរិយុដ្ឋានៈ គឺកាមរាគៈ សញ្ញោជនៈ គឺកាមរាគៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បើ រាគៈ កាមរាគៈ បរិយុដ្ឋានៈ គឺកាបរាគៈ សញ្ញោជនៈ គឺកាមរាគៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ របស់ព្រះអរហន្ត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

(៣) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់បុថុជ្ជន មាន រាគៈ កាមរាគៈ បរិយុដ្ឋានៈ គឺកាមរាគៈ សញ្ញោជនៈ គឺកាមរាគៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ របស់បុថុជ្ជននោះ មានដែរឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មាន រាគៈ កាមរាគៈ បរិយុដ្ឋានៈ គឺកាមរាគៈ ។ បេ ។ កាមច្ឆន្ទនីវរណៈ របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤ ) អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋិ នត្ថិ តស្ស រាគោ កាមរាគោ កាមរាគបរិយុដ្ឋានំ ។ បេ ។ កាមច្ឆន្ទនីវរណន្តិ ។ អាមន្តា ។ អត្ថិ បុថុជ្ជនស្ស អសុចិសុក្កវិសដ្ឋិ នត្ថិ តស្ស រាគោ កាមរាគោ កាមរាគបរិយុដ្ឋានំ ។ បេ ។ កាមច្ឆន្ទនីវរណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៥ ) អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ កេនដ្ឋេនាតិ ។ ហន្ទ ហិ មារកាយិកា ទេវតា អរហតោ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។

( ៦ ) មារកាយិកា ទេវតា អរហតោ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។ អាមន្តា ។ អត្ថិ មារកាយិកានំ ទេវតានំ អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៧ ) នត្ថិ មារកាយិកានំ ទេវតានំ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ ហញ្ចិ នត្ថិ មារកាយិកានំ ទេវតានំ អសុចិសុក្កវិសដ្ឋិ នោ ច វត រេ វត្តព្វេ មារកាយិកា ទេវតា អរហតោ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។

( ៨ ) មារកាយិកា ទេវតា អរហតោ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។ អាមន្តា ។ មារកាយិកា ទេវតា

(៤) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មាន រាគៈ កាមរាគៈ បរិយុដ្ឋានៈ គឺ កាមរាគៈ ។ បេ ។ កាមច្ឆន្ទនីវរណៈ របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់បុថុជ្ជន មាន រាគៈ កាមរាគៈ បរិយុដ្ឋានៈ គឺ កាមរាគៈ ។ បេ ។ កាមច្ឆន្ទនីវរណៈ របស់បុថុជ្ជននោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៥) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ (ការបញ្ចេញ ទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត) មានដោយអត្ថដូចម្ដេច ។ ទំនងជាទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ។

(៦) ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ទេវតាជាពួកនៃមារ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ទេវតា ជាពួកនៃមារ មិនមានទេឬ ។ អើ ។ បើការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ទេវតាជាពួកនៃមារ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរនិយាយថា ទេវតាជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ។

(៨) ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តឬ ។ អើ ។ ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញ

## បរូបហារកថា

អត្តនោ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តិ អញ្ញេសំ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តិ តស្ស អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។ ន ហេវំ វត្តព្វេ ។បេ ។

(៩) មារកាយិកា ទេវតា នេវ អត្តនោ ន អញ្ញេសំ ន តស្ស អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។ អាមន្តា ។ ហញ្ចិ មារកាយិកា ទេវតា នេវ អត្តនោ ន អញ្ញេសំ ន តស្ស អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តិ នោ វត រេ វត្តព្វេ មារកាយិកា ទេវតា អរហតោ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។

(១០) មារកាយិកា ទេវតា អរហតោ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។ អាមន្តា ។ លោមកូបេហិ ឧបសំហរន្តីតិ ។ ន ហេវំ វត្តព្វេ ។បេ ។

(១១) មារកាយិកា ទេវតា អរហតោ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។ អាមន្តា ។ កឹការណាតិ ។ ហន្ទ ហិ វិមតឹ គាហយិស្សាមាតិ ។ អត្ថិ អរហតោ វិមតីតិ ។ ន ហេវំ វត្តព្វេ ។បេ ។

(១២) អត្ថិ អរហតោ វិមតីតិ ។ អាមន្តា ។ អត្ថិ អរហតោ សត្ថរិ វិមតិ ធម្មេ វិមតិ សង្ឃេ វិមតិ

## បរូបហារកថា

ទឹកសុក្កៈ មិនស្អាត របស់ខ្លួន នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ពួកជនដទៃ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩) ទេវតា ជាពួកនៃមារ មិននាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ខ្លួន មិននាំយកទឹកសុក្កៈ របស់អ្នកដទៃ មិននាំយកទឹកសុក្កៈ របស់ព្រះអរហន្តនោះទេឬ ។ អើ ។ បើទេវតា ជាពួកនៃមារ មិននាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ខ្លួន មិននាំយកទឹកសុក្កៈ របស់ជនដទៃ មិននាំយកទឹកសុក្កៈ របស់ព្រះអរហន្តនោះ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តទេ ។

(១០) ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តឬ ។ អើ ។ ទេវតា ជាពួកនៃមារ នាំយកតាមរណ្តៅនៃរោមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១១) ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តឬ ។ អើ ។ ព្រោះហេតុអ្វី ។ ព្រោះទេវតា (មានគំនិតថា) យើងនឹងញុំាងអ្នកដទៃឲ្យកាន់យកមតិខុស ។ ព្រះអរហន្ត មានមតិខុសដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១២) មតិខុស របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ មតិខុស របស់ព្រះអរហន្ត ក្នុងព្រះសាស្តា មតិខុសក្នុងព្រះធម៌ មតិខុសក្នុងព្រះសង្ឃ

សិក្ខាយ វិមតិ បុព្វន្តេ វិមតិ អបរន្តេ វិមតិ បុព្វន្តា-
បរន្តេ វិមតិ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ
វិមតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១៣) នត្ថិ អរហតោ សត្ថរិ វិមតិ ធម្មេ វិមតិ
សង្ឃេ វិមតិ សិក្ខាយ វិមតិ បុព្វន្តេ វិមតិ អបរន្តេ
វិមតិ បុព្វន្តាបរន្តេ វិមតិ ឥទប្បច្ចយតាបដិច្ចសមុប្ប-
ន្នេសុ ធម្មេសុ វិមតីតិ ។ អាមន្តា ។ ហញ្ចិ នត្ថិ
អរហតោ សត្ថរិ វិមតិ ។ បេ ។ ឥទប្បច្ចយតាបដិច្ចស-
មុប្បន្នេសុ ធម្មេសុ វិមតិ នោ វត រេ វត្តព្វេ អត្ថិ
អរហតោ វិមតីតិ ។

(១៤) អត្ថិ បុថុជ្ជនស្ស វិមតិ អត្ថិ តស្ស សត្ថរិ
វិមតិ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ
វិមតីតិ ។ អាមន្តា ។ អត្ថិ អរហតោ វិមតិ អត្ថិ
តស្ស សត្ថរិ វិមតិ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្ប-
ន្នេសុ ធម្មេសុ វិមតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

មតិខុសក្នុងសិក្ខា មតិខុសក្នុងចំណែកខាងដើម មតិខុសក្នុងចំណែកខាងចុង មតិខុសក្នុងចំណែកខាងដើមនិងខាងចុង មតិខុសក្នុងធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៣) មតិខុស របស់ព្រះអរហន្ត មិនមានក្នុងព្រះសាស្តា មិនមានមតិខុសក្នុងព្រះធម៌ មិនមានមតិខុសក្នុងព្រះសង្ឃ មិនមានមតិខុសក្នុងសិក្ខា មិនមានមតិខុសក្នុងចំណែកខាងដើម មិនមានមតិខុសក្នុងចំ-ណែកខាងចុង មិនមានមតិខុសក្នុងចំណែកខាងដើមនិងខាងចុង មិនមានក្នុងព្រះធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យទេឬ ។ អើ ។ បើមតិខុស របស់ព្រះអរហន្ត មិនមានក្នុងព្រះសាស្តា ។ បេ ។ មិនមានមតិខុសក្នុងព្រះធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា មតិខុស របស់ព្រះអរហន្ត មានទេ ។

(១៤) មតិខុស របស់បុថុជ្ជន មាន មតិខុស របស់បុថុជ្ជននោះ ក្នុងព្រះសាស្តា ។ បេ ។ មតិខុសក្នុងធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានដែរឬ ។ អើ ។ មតិខុស របស់ព្រះអរហន្ត មាន មតិខុស របស់ព្រះអរហន្តនោះ ក្នុងព្រះសាស្តា ។ បេ ។ មតិខុសក្នុងធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៥) អត្ថិ អរហតោ វិមតិ នត្ថិ តស្ស សត្ថរិ វិមតិ ។បេ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ វិមតីតិ ។ អាមន្តា ។ អត្ថិ បុថុជ្ជនស្ស វិមតិ នត្ថិ តស្ស សត្ថរិ វិមតិ ។បេ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ វិមតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(១៦) អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ អរហតោ អសុចិសុក្កវិសដ្ឋិ កិស្ស និស្សន្ទោតិ ។ អសិតបីតខាយិតសាយិតស្ស និស្សន្ទោតិ ។ អរហតោ អសុចិសុក្កវិសដ្ឋិ អសិតបីតខាយិតសាយិតស្ស និស្សន្ទោតិ ។ អាមន្តា ។ យេ កេចិ អសន្តិ បិវន្តិ ខាយន្តិ សាយន្តិ សព្វេសញ្ញេវ អត្ថិ អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(១៧) យេ កេចិ អសន្តិ បិវន្តិ ខាទន្តិ សាយន្តិ សព្វេសញ្ញេវ អត្ថិ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ ទារកា អសន្តិ បិវន្តិ ខាទន្តិ សាយន្តិ អត្ថិ ទារកានំ អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។បេ។

បរូបហារកថា

(១៥) មតិខុស របស់ព្រះអរហន្ត មាន មតិខុស របស់ព្រះអរហន្តនោះ មិនមានក្នុងព្រះសាស្តា ។ បេ ។ មិនមានមតិខុសក្នុងធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យឬ ។ អើ ។ មតិខុសរបស់បុថុជ្ជន មាន មតិខុស របស់បុថុជ្ជននោះ មិនមានក្នុងព្រះសាស្តា ។ បេ ។ មិនមានមតិខុសក្នុងធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៦) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ជាអានិសង្ស នៃរបស់អ្វី ។ ការបញ្ចេញទឹកសុក្កៈ របស់ព្រះអរហន្ត ជាអានិសង្ស នៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រសដែលលិទ្ធភក្ស ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ជាអានិសង្ស នៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី និងរសដែលលិទ្ធភក្សដែរឬ ។ អើ ។ ពួកជនណាមួយ ស៊ី ផឹក ទំពាស៊ី លិទ្ធភក្ស ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ជនទាំងអស់នោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៧) ពួកជនណាមួយ ស៊ី ផឹក ទំពាស៊ី លិទ្ធភក្ស ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ជនទាំងអស់នោះ មានដែរឬ ។ អើ ។ ពួកទារក ស៊ី ផឹក ទំពាស៊ី លិទ្ធភក្ស ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ទារក មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៨] បណ្ឌកា អសន្តិ បិវន្តិ ខាទន្តិ សាយន្តិ អត្ថិ បណ្ឌកានំ អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៩] ទេវា អសន្តិ បិវន្តិ ខាទន្តិ សាយន្តិ អត្ថិ ទេវានំ អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២០] អរហតោ អសុចិសុក្កវិសដ្ឋិ អសិតបីតខាយិតសាយិតស្ស និស្សន្ទោតិ ។ អាមន្តា ។ អត្ថិ តស្ស អាសយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២១] អរហតោ ឧច្ចារប្បស្សាវោ អសិតបីតខាយិតសាយិតស្ស និស្សន្ទោ អត្ថិ តស្ស អាសយោតិ ។ អាមន្តា ។ អរហតោ អសុចិសុក្កវិសដ្ឋិ អសិតបីតខាយិតសាយិតស្ស និស្សន្ទោ អត្ថិ តស្ស អាសយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២២] អរហតោ អសុចិសុក្កវិសដ្ឋិ អសិតបីតខាយិតសាយិតស្ស និស្សន្ទោ នត្ថិ តស្ស អាសយោតិ ។ អាមន្តា ។ អរហតោ ឧច្ចារប្បស្សាវោ អសិតបីត-

(១៨) ពួកបណ្ឌកៈ (មនុស្សខ្ទើយ) ស៊ី ផឹក ទំពាស៊ី លិទ្ធភ្លក្ស ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ពួកបណ្ឌកៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៩) ពួកទេវតាស៊ី ផឹក ទំពាស៊ី លិទ្ធភ្លក្ស ការបញ្ចេញទឹកសុក្កៈមិនស្អាត របស់ពួកទេវតា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(២០) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ជាអានិសង្ស នៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រសដែលលិទ្ធភ្លក្សឬ ។ អើ ។ ទីនៅនៃទឹកសុក្កៈ របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរនិយាយយ៉ាងនេះទេ ។ បេ ។

(២១) ឧច្ចារៈនិងបស្សាវៈ របស់ព្រះអរហន្ត ជាអានិសង្ស នៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រសដែលលិទ្ធភ្លក្ស ទីនៅនៃទឹកសុក្កៈ របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ជាអានិសង្ស នៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រសដែលលិទ្ធភ្លក្ស ទីនៅនៃទឹកសុក្កៈ របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២២) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ជាអានិសង្ស នៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រសដែលលិទ្ធភ្លក្ស ទីនៅនៃទឹកសុក្កៈ របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ឧច្ចារៈនិងបស្សាវៈ របស់ព្រះអរហន្ត ជាអានិសង្ស នៃបាយដែលស៊ី ទឹកដែលផឹក

ខាយិតសាយិតស្ស និស្សន្ទោ នត្ថិ តស្ស អាសយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៣) អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ អរហា មេថុនំ ធម្មំ បដិសេវេយ្យ មេថុនំ ធម្មំ ឧប្បាទេយ្យ បុត្តសម្ពាធសយនំ អជ្ឈាវសេយ្យ កាសិកចន្ទនំ បច្ចនុភវេយ្យ មាលាគន្ធវិលេបនំ ធារេយ្យ ជាតរូបរជតំ សាទិយេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៤) អត្ថិ បុថុជ្ជនស្ស អសុចិសុក្កវិសដ្ឋិ បុថុជ្ជនោ មេថុនំ ធម្មំ បដិសេវេយ្យ មេថុនំ ធម្មំ ឧប្បាទេយ្យ ។ បេ ។ ជាតរូបរជតំ សាទិយេយ្យាតិ ។ អាមន្តា ។ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋិ អរហា មេថុនំ ធម្មំ បដិសេវេយ្យ មេថុនំ ធម្មំ ឧប្បាទេយ្យ ។ បេ ។ ជាតរូបរជតំ សាទិយេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៥) អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋិ ន ច អរហា មេថុនំ ធម្មំ បដិសេវេយ្យ មេថុនំ ធម្មំ ឧប្បាទេយ្យ ។ បេ ។ ជាតរូបរជតំ សាទិយេយ្យាតិ ។ អាមន្តា ។ អត្ថិ បុថុជ្ជនស្ស អសុចិសុក្កវិសដ្ឋិ ន ច បុថុជ្ជនោ មេថុនំ ធម្មំ បដិសេវេយ្យ មេថុនំ ធម្មំ ឧប្បាទេយ្យ បុត្តសម្ពាធសយនំ

វត្ថុដែលទំពាស៊ី រសដែលលិទ្ធភក្ស ទីនៅនៃទឹកសុក្កៈ របស់ព្រះអរហន្ត នោះ មិនមានទេឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ

(២៣) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរ ឬ ៗ អើ ៗ ព្រះអរហន្ត គប្បីសេពមេថុនធម្ម គប្បីញ៉ាំងមេថុនធម្មឲ្យកើតឡើង គប្បីនៅគ្រប់គ្រងនូវទីដេកដ៏ចង្អៀតដោយកូន គប្បីប្រដាប់នូវខ្លឹមចន្ទន៍ក្នុងដែនកាសិកៈ គប្បីទ្រទ្រង់ នូវកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប គប្បីត្រេកអរចំពោះមាសនិងប្រាក់ ដែរឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ

(២៤) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់បុថុជ្ជនមាន បុថុជ្ជន គប្បីសេពមេថុនធម្ម គប្បីញ៉ាំងមេថុនធម្មឲ្យកើតឡើង ៗ បេ ៗ គប្បីត្រេកអរចំពោះមាសនិងប្រាក់ ដែរឬ ៗ អើ ៗ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មាន ព្រះអរហន្ត គប្បីសេពមេថុនធម្ម គប្បីញ៉ាំងមេថុនធម្មឲ្យកើតឡើង ៗ បេ ៗ គប្បីត្រេកអរចំពោះមាសនិងប្រាក់ ដែរឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗបេៗ

(២៥) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មាន តែព្រះអរហន្ត មិនសេពមេថុនធម្ម មិនញ៉ាំងមេថុនធម្មឲ្យកើតឡើងទេ ៗបេៗ មិនត្រេកអរចំពោះមាសនិងប្រាក់ ទេឬ ៗ អើ ៗ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់បុថុជ្ជន មាន តែបុថុជ្ជន មិនសេពមេថុនធម្ម មិនញ៉ាំងមេថុនធម្មឲ្យកើតឡើង មិនគប្បីអាស្រ័យនូវទីដេកដ៏ចង្អៀតដោយកូន

អជ្ឈាវសេយ្យ កាសិកចន្ទនំ បច្ចនុភវេយ្យ មាលាគន្ធវិលេបនំ ធារេយ្យ ជាតរូបរជតំ សាទិយេយ្យាតិ ។ ន ហេវំ វត្តព្វេ ។បេ ។

(២៦) អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ ននុ អរហតោ រាគោ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោតិ ។ អាមន្តា ។ ហញ្ចិ អរហតោ រាគោ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ នោ វត រេ វត្តព្វេ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

(២៧) អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ ននុ អរហតោ ទោសោ បហីនោ ។បេ ។ មោហោ បហីនោ មានោ បហីនោ ទិដ្ឋិ បហីនា វិចិកិច្ឆា បហីនា ថីនំ បហីនំ ឧទ្ធច្ចំ បហីនំ អហិរិកំ បហីនំ ។បេ ។ អនោត្តប្បំ បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មន្តិ ។ អាមន្តា ។ ហញ្ចិ អរហតោ អនោត្តប្បំ បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មំ នោ វត រេ វត្តព្វេ

មិនប្រដាប់ នូវខ្លឹមចន្ទន៍ក្នុងដែនកាសិកៈ មិនទ្រទ្រង់ នូវកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប មិនត្រេកអរចំពោះមាសនិងប្រាក់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២៦) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត លះបង់រាគៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះបង់រាគៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើត តទៅទៀតហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

(២៧) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត លះទោសៈ ។ បេ ។ លះមោហៈ លះមានះ លះទិដ្ឋិ លះវិចិកិច្ឆា លះថីនៈ លះឧទ្ធច្ចៈលះ អហិរិកៈ ។ បេ ។ លះអនោត្តប្បៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើត តទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះអនោត្តប្បៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើត តទៅទៀតហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា

## បរូបហារកថា

អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

(២៨) អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ ននុ អរហតោ រាគប្បហានាយ មគ្គោ ភាវិតោតិ ។ អាមន្តា ។ ហញ្ចិ អរហតោ រាគប្បហានាយ មគ្គោ ភាវិតោ នោ វត រេ វត្តព្វេ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

(២៩) អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ ននុ អរហតោ រាគប្បហានាយ សតិប្បដ្ឋានា ភាវិតា ។បេ។ សម្មប្បធានា ភាវិតា ឥទ្ធិបាទា ភាវិតា ឥន្ទ្រិយា ភាវិតា ពលា ភាវិតា ។បេ។ ពោជ្ឈង្គា ភាវិតាតិ ។ អាមន្តា ។ ហញ្ចិ អរហតោ រាគប្បហានាយ ពោជ្ឈង្គា ភាវិតា នោ វត រេ វត្តព្វេ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

(៣០) អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ ននុ អរហតោ ទោសប្បហានាយ ។បេ។ មោហប្បហានាយ ។បេ។ អនោត្តប្បប្បហានាយ មគ្គោ ភាវិតោ ។បេ។ ពោជ្ឈង្គា ភាវិតាតិ ។ អាមន្តា ។ ហញ្ចិ អរហតោ អនោត្តប្បប្បហានាយ ពោជ្ឈង្គា ភាវិតា

## បរូបហារកថា

ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

(២៨) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះរាគៈឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះរាគៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

(២៩) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនសតិប្បដ្ឋាន ដើម្បីលះរាគៈ ។បេ។ ចម្រើនសម្មប្បធាន ចម្រើនឥទ្ធិបាទ ចម្រើនឥន្ទ្រិយ ចម្រើនពលៈ ។បេ។ ចម្រើនពោជ្ឈង្គៈ ដើម្បីលះរាគៈឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គៈ ដើម្បីលះរាគៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

(៣០) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះទោសៈ ។បេ។ ដើម្បីលះមោហៈ ។បេ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គៈឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គៈ ដើម្បីលះអនោត្តប្បៈ

នោ វត រេ វត្តព្វេ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

[៣១] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ ននុ អរហា វីតរាគោ វីតទោសោ វីតមោហោ កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញាវិមុត្តោ ឧក្ខិត្តបលិឃោ សង្កិណ្ណបរិខោ អព្វុឡ្ហេសិកោ និរគ្គឡោ អរិយោ បន្នទ្ធជោ បន្នភារោ វិសញ្ញុត្តោ សុវិជិតវិជយោ ទុក្ខន្តស្ស បរិញ្ញាតំ សមុទយោ បហីនោ និរោធោ សច្ឆិកតោ មគ្គោ ភាវិតោ អភិញ្ញេយ្យំ អភិញ្ញាតំ បរិញ្ញេយ្យំ បរិញ្ញាតំ បហាតព្វំ បហីនំ ភាវេតព្វំ ភាវិតំ សច្ឆិកាតព្វំ សច្ឆិកតន្តិ ។ អាមន្តា ។ ហញ្ចិ អរហា វីតរាគោ វីតទោសោ វីតមោហោ កតករណីយោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ នោ វត រេ វត្តព្វេ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

[៣២] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[៣១] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានឬ ។ អើ ។ តែគង់ព្រះអរហន្ត ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មានករណីយកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនដល់ហើយ មានសញ្ញោជនៈកង្វក់ក្នុងភពអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ មានសន្ទះបើកឡើងហើយ មានគូទម្លាយហើយ មានសសរខឿនដកឡើងហើយ មិនមានគន្លឹះទ្វារ ជាអរិយបុគ្គល មានទង់ដាក់ចុះហើយ មានភារៈដាក់ចុះហើយ មិនប្រកបដោយកិលេស មានជំនះល្អហើយ ព្រះអរហន្តនោះ កំណត់ដឹងនូវទុក្ខ លះនូវសមុទ័យ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ ចម្រើនមគ្គ ត្រាស់ដឹងនូវអភិញ្ញេយ្យកិច្ច កំណត់ដឹងនូវបរិញ្ញេយ្យកិច្ច លះនូវបហាតព្វកិច្ច ចម្រើននូវភាវេតព្វកិច្ច ធ្វើឲ្យជាក់ច្បាស់នូវសច្ឆិកាតព្វកិច្ចឬ ។ អើ ។ បើព្រះអរហន្ត ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មានករណីយកិច្ចធ្វើហើយ ។ បេ ។ ធ្វើឲ្យជាក់ច្បាស់នូវសច្ឆិកាតព្វកិច្ច ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[៣២] ការបញ្ចេញទឹកសុក្ក មិនស្អាត របស់ព្រះអរហន្ត មាន

បរូបហារកថា

សធម្មកុសលស្ស អរហតោ អត្ថិ អសុចិសុក្កវិសដ្ឋិ បរធម្មកុសលស្ស អរហតោ នត្ថិ អសុចិសុក្កវិសដ្ឋីតិ ។ សធម្មកុសលស្ស អរហតោ អត្ថិ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ បរធម្មកុសលស្ស អរហតោ អត្ថិ អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៣) បរធម្មកុសលស្ស អរហតោ នត្ថិ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ សធម្មកុសលស្ស អរហតោ នត្ថិ អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៤) សធម្មកុសលស្ស អរហតោ រាគោ បហីនោ អត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ បរធម្មកុសលស្ស អរហតោ រាគោ បហីនោ អត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៥) សធម្មកុសលស្ស អរហតោ ទោសោ បហីនោ

បរូបហារកថា

ឬ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន[១] មាន ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ[២] មិនមានទេ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មានឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៣] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មិនមានទេឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៤] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះរាគៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះរាគៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៥] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះទោសៈហើយ

---

១ ធម៌របស់ខ្លួន បានដល់អរហត្តធម៌ ។ ២ ធម៌ដទៃ បានដល់សមាបត្តិ ៨ ។ អដ្ឋកថា ។

មោហោ បហីនោ ។ បេ ។ អនោត្តប្បំ បហីនំ អត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ បរជម្មកុសលស្ស អរហតោ អនោត្តប្បំ បហីនំ អត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៦) សជម្មកុសលស្ស អរហតោ រាគប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា ។ បេ ។ ទោសប្បហានាយ ។ បេ ។ មោហប្បហានាយ ។ បេ ។ អនោត្តប្បប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា អត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ បរជម្មកុសលស្ស អរហតោ អនោត្តប្បប្បហានាយ ពោជ្ឈង្គា ភាវិតា អត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៧) សជម្មកុសលោ អរហា វីតរាគោ វីតទោសោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ អត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ បរជម្មកុសលោ អរហា វីតរាគោ វីតទោសោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ អត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

លះមោហៈហើយ ។ បេ ។ លះអនោត្តប្បៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះអនោត្តប្បៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៦] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ចម្រើនមគ្គ ដើម្បីលះរាគៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ។ បេ ។ ដើម្បីលះទោសៈ ។ បេ ។ ដើម្បីលះមោហៈ ។ បេ ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ចម្រើនពោជ្ឈង្គៈ ដើម្បីលះអនោត្តប្បៈ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៧] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ប្រាសចាករាគៈ ប្រាសចាកទោសៈ ។ បេ ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ប្រាសចាករាគៈ ប្រាសចាកទោសៈ ។ បេ ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៨) បរធម្មកុសលស្ស អរហតោ រាគោ បហីនោ នត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ សកធម្មកុសលស្ស អរហតោ រាគោ បហីនោ នត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៩) បរធម្មកុសលស្ស អរហតោ ទោសោ បហីនោ មោហោ បហីនោ ។ បេ ។ អនោត្តប្បំ បហីនំ នត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ សកធម្មកុសលស្ស អរហតោ អនោត្តប្បំ បហីនំ នត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤០) បរធម្មកុសលស្ស អរហតោ រាគប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា ។ បេ ។ ទោសប្បហានាយ ។ បេ ។ មោហប្បហានាយ ។ បេ ។ អនោត្តប្បប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា នត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ សកធម្មកុសលស្ស អរហតោ អនោត្តប្បប្បហានាយ ពោជ្ឈង្គា ភាវិតា នត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

បរូបហារកថា

(៣៨) ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ បានលះរាគៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន បានលះរាគៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៩) ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ បានលះទោសៈហើយ លះមោហៈហើយ ។បេ។ លះអនោត្តប្បៈហើយ ការបញ្ចេញទឹកសុក្កៈមិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន បានលះអនោត្តប្បៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។

(៤០) ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ បម្រើនមគ្គ ដើម្បីលះរាគៈ ។បេ។ បម្រើនពោជ្ឈង្គៈ ។បេ។ ដើម្បីលះទោសៈ ។បេ។ ដើម្បីលះមោហៈ ។បេ។ បម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។បេ។ បម្រើនពោជ្ឈង្គៈ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន បម្រើនពោជ្ឈង្គៈ ដើម្បីលះអនោត្តប្បៈ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៨១] បរធម្មកុសលោ អរហា វីតរាគោ វីតទោសោ វីតមោហោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ នត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ សធម្មកុសលោ អរហា វីតរាគោ វីតទោសោ វីតមោហោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ នត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៨២] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា យេ តេ ភិក្ខវេ ភិក្ខូ បុថុជ្ជនា សីលសម្បន្នា សតិសម្បជានា និទ្ទំ ឱក្កមន្តិ តេសំ អសុចិ ន មុច្ចតិ យេបិ តេ ភិក្ខវេ ពាហិរកា ឥសយោ កាមេសុ វីតរាគា តេសម្បិ អសុចិ ន មុច្ចតិ អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ អរហតោ អសុចិ មុច្ចេយ្យាតិ អត្ថេវ សុត្តន្តោតិ ។ (១)តេន ហិ ន វត្តព្វំ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

---

១ ឱ. ម. ឯត្ថន្តរេ អាមន្តាតិ ទិស្សតិ ។

(៨១) ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។បេ។ សច្ចិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។បេ។ សច្ចិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៨២) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ជាបុថុជ្ជន បរិបូណ៌ដោយសីល មានសតិនិងសម្បជញ្ញៈ ចុះស៊ប់កាន់កិរិយាដេកលក់ អសុចិរបស់ភិក្ខុទាំងនោះ មិនឃ្លាតចេញទេ ម្នាលភិក្ខុទាំងឡាយ ពួកឥសី ជាខាងក្រៅ ណា ប្រាសចាករាគៈ ក្នុងកាមទាំងឡាយ អសុចិរបស់ឥសីទាំងនោះ មិនឃ្លាតចេញទេ អសុចិរបស់ព្រះអរហន្ត គប្បីឃ្លាតចេញ ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ ហេតុនុះ រមែងមិនមាន មិនមែនជាឱកាសទេ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[ ៤៣ ] ន វត្តព្វំ អត្ថិ អរហតោ បរូបហារោតិ(១) ។ អាមន្តា ។ ននុ អរហតោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ បរេ ឧបសំហរន្តីតិ ។ អាមន្តា ។ ហញ្ចិ អរហតោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ បរេ ឧបសំហរន្តិ តេន វត រេ វត្តព្វេ អត្ថិ អរហតោ បរូបហារោតិ(១) ។

[ ៤៤ ] អរហតោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ បរេ ឧបសំហរន្តីតិ ។ អត្ថិ អរហតោ បរូបហារោតិ ។ អាមន្តា ។ អរហតោ សោតាបត្តិផលំ វា សកទាគាមិផលំ វា អនាគាមិផលំ វា អរហត្តំ វា បរេ ឧបសំហរន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

បរូបហារកថា ។

## អញ្ញាណកថា

[ ៤៥ ] អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ អត្ថិ អរហតោ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណន្តិ ។

១ ឱ. អសុចិសុក្កវិសដ្ឋីតិ ទិស្សតិយេវ ។

(៤៣) អ្នកមិនគប្បីពោលថា ការញុំាងបុគ្គលដទៃឲ្យនាំមក របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងពួកជនដទៃ គប្បីនាំមក នូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យ និងភេសជ្ជបរិក្ខារ ដើម្បីព្រះអរហន្តដែរឬ ។ អើ ។ បើពួកជនដទៃ គប្បីនាំមក នូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យ និងភេសជ្ជបរិក្ខារ ដើម្បីព្រះអរហន្ត ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា ការញុំាងបុគ្គលដទៃឲ្យនាំមក របស់ព្រះអរហន្ត មានដែរ ។

(៤៤) ពួកជនដទៃ គប្បីនាំមក នូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យ និងភេសជ្ជបរិក្ខារ ដើម្បីព្រះអរហន្តដែរឬ ។ ការញុំាងបុគ្គលដទៃឲ្យនាំមក របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ពួកជនដទៃគប្បីនាំមក នូវសោតាបត្តិផលក្តី សកទាគាមិផលក្តី អនាគាមិផលក្តី អរហត្តផលក្តី ដើម្បីព្រះអរហន្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ បរូបហារកថា ។

# អញ្ញាណកថា

(៤៥) ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ អវិជ្ជា ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានៈគឺអវិជ្ជា សញ្ញោជនៈគឺអវិជ្ជា នីវរណៈគឺអវិជ្ជា របស់ព្រះអរហន្ត មានដែរឬ ។

ន ហេវំ វត្តព្វេ ។ បេ ។

(៤៦) នត្ថិ អរហតោ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណន្តិ ។ អាមន្តា ។ ហញ្ចិ នត្ថិ អរហតោ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណំ នោ វត រេ វត្តព្វេ អត្ថិ អរហតោ អញ្ញាណន្តិ ។

(៤៧) អត្ថិ បុថុជ្ជនស្ស អញ្ញាណំ អត្ថិ តស្ស អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណន្តិ ។ អាមន្តា ។ អត្ថិ អរហតោ អញ្ញាណំ អត្ថិ តស្ស អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៨) អត្ថិ អរហតោ អញ្ញាណំ នត្ថិ តស្ស អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណន្តិ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤៦ ] អវិជ្ជា ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានៈគឺអវិជ្ជា សញ្ញោជនៈគឺអវិជ្ជា នីវរណៈគឺអវិជ្ជា របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បើអវិជ្ជា ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានៈគឺអវិជ្ជា សំញោជនៈគឺអវិជ្ជា នីវរណៈគឺអវិជ្ជា របស់ព្រះអរហន្ត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[ ៤៧ ] ការមិនដឹង របស់បុថុជ្ជន មាន អវិជ្ជា ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានៈគឺអវិជ្ជា សញ្ញោជនៈគឺអវិជ្ជា នីវរណៈគឺអវិជ្ជា របស់បុថុជ្ជននោះ មានដែរឬ ។ អើ ។ ការមិនដឹង របស់ព្រះអរហន្ត មាន អវិជ្ជា ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានៈគឺអវិជ្ជា សញ្ញោជនៈគឺអវិជ្ជា នីវរណៈគឺអវិជ្ជា របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤៨ ] ការមិនដឹង របស់ព្រះអរហន្ត មាន អវិជ្ជា ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានៈគឺអវិជ្ជា សញ្ញោជនៈគឺអវិជ្ជា នីវរណៈគឺអវិជ្ជា របស់ព្រះអរហន្តនោះ មិនមានទេឬ ។

អញ្ញាណកថា

អាបន្នា ។ អត្ថិ បុថុជ្ជនស្ស អញ្ញាណំ នត្ថិ តស្ស អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៤៩ ) អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ អរហា អញ្ញាណបកតោ បាណំ ហនេយ្យ អទិន្នំ អាទិយេយ្យ មុសា ភណេយ្យ បិសុណំ ភណេយ្យ ផរុសំ ភណេយ្យ សម្ផំ បលបេយ្យ សន្ធឹ ឆិន្ទេយ្យ និល្លោបំ ហរេយ្យ ឯកាគារិកំ ករេយ្យ បរិបន្ថេ តិដ្ឋេយ្យ បរទារំ គច្ឆេយ្យ គាមឃាតំ ករេយ្យ និគមឃាតំ ករេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៥០ ) អត្ថិ បុថុជ្ជនស្ស អញ្ញាណំ បុថុជ្ជនោ អញ្ញាណបកតោ បាណំ ហនេយ្យ អទិន្នំ អាទិ-យេយ្យ ។ បេ ។ គាមឃាតំ ករេយ្យ និគមឃាតំ ករេយ្យាតិ ។ អាមន្តា ។ អត្ថិ អរហតោ អញ្ញាណំ អរហា អញ្ញាណបកតោ បាណំ ហនេយ្យ អទិន្នំ អាទិយេយ្យ ។ បេ ។ គាមឃាតំ ករេយ្យ និគមឃាតំ ករេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អើ ។ ការមិនដឹង របស់បុថុជ្ជន មាន អវិជ្ជា ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានៈគឺអវិជ្ជា សញ្ញោជនៈគឺអវិជ្ជា នីវរណៈគឺអវិជ្ជា របស់បុថុជ្ជននោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៩ ) ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ព្រះអរហន្ត ដែលការមិនដឹងគ្របសង្កត់ គប្បីសម្លាប់សត្វ គប្បីកាន់យកទ្រព្យដែលគេមិនឲ្យ គប្បីពោលពាក្យកុហក គប្បីពោលពាក្យញុះញង់ គប្បីពោលពាក្យអាក្រក់ គប្បីពោលពាក្យឥតប្រយោជន៍ គប្បីកាត់ទី-ត គប្បីពួនចាំឆក់ គប្បីប្លន់តែផ្ទះមួយ គប្បីឈរស្ទាក់ត្រង់ផ្លូវ គប្បីគប់រកប្រពន្ធបុគ្គលដទៃ គប្បីសម្លាប់អ្នកស្រុក គប្បីសម្លាប់អ្នកនិគមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៥០ ) ការមិនដឹង របស់បុថុជ្ជន មាន បុថុជ្ជន ដែលការមិនដឹងគ្របសង្កត់ គប្បីសម្លាប់សត្វ គប្បីកាន់យកទ្រព្យដែលគេមិនឲ្យ ។ បេ ។ គប្បីសម្លាប់អ្នកស្រុក គប្បីសម្លាប់អ្នកនិគមឬ ។ អើ ។ ការមិនដឹង របស់ព្រះអរហន្ត មាន ព្រះអរហន្ត ដែលការមិនដឹងគ្របសង្កត់ គប្បីសម្លាប់សត្វ គប្បីកាន់យកទ្រព្យដែលគេមិនឲ្យ ។ បេ ។ គប្បីសម្លាប់អ្នកស្រុក គប្បីសម្លាប់អ្នកនិគមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៥១ ) អត្ថិ អរហតោ អញ្ញាណំ ន ច អរហា អញ្ញាណបកតោ បាណំ ហនេយ្យ អទិន្នំ អាទិយេយ្យ ។ បេ ។ គាមឃាតំ ករេយ្យ និគមឃាតំ ករេយ្យាតិ ។ អាមន្តា ។ អត្ថិ បុថុជ្ជនស្ស អញ្ញាណំ ន ច បុថុជ្ជនោ អញ្ញាណបកតោ បាណំ ហនេយ្យ អទិន្នំ អាទិយេយ្យ ។ បេ ។ គាមឃាតំ ករេយ្យ និគមឃាតំ ករេយ្យា-តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៥២ ) អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ អត្ថិ អរហតោ សត្ថរិ អញ្ញាណំ ធម្មេ អញ្ញាណំ សង្ឃេ អញ្ញាណំ សិក្ខាយ អញ្ញាណំ បុព្វន្តេ អញ្ញាណំ អបរន្តេ អញ្ញាណំ បុព្វន្តាបរន្តេ អញ្ញាណំ ឥទប្បច្ច-យតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៥៣ ) នត្ថិ អរហតោ សត្ថរិ អញ្ញាណំ ធម្មេ អញ្ញាណំ សង្ឃេ អញ្ញាណំ សិក្ខាយ អញ្ញាណំ បុព្វន្តេ អញ្ញាណំ អបរន្តេ អញ្ញាណំ បុព្វន្តាបរន្តេ អញ្ញាណំ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណន្តិ ។ អាមន្តា ។ ហញ្ចិ នត្ថិ អរហតោ

( ៥១ ) ការមិនដឹង របស់ព្រះអរហន្ត មាន ប៉ុន្តែព្រះអរហន្ត ដែលការមិនដឹងគ្របសង្កត់ មិនគប្បីសម្លាប់សត្វ មិនគប្បីកាន់យកទ្រព្យ ដែលគេមិនឲ្យ ។ បេ ។ មិនគប្បីសម្លាប់អ្នកស្រុក មិនគប្បីសម្លាប់អ្នកនិគម ទេឬ ។ អើ ។ ការមិនដឹង របស់បុថុជ្ជន មាន ប៉ុន្តែបុថុជ្ជន ដែលការមិនដឹងគ្របសង្កត់ មិនគប្បីសម្លាប់សត្វ មិនគប្បីកាន់យកទ្រព្យដែលគេមិនឲ្យ ។ បេ ។ មិនគប្បីសម្លាប់អ្នកស្រុក មិនគប្បីសម្លាប់អ្នកនិគមទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៥២ ) ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ការមិនដឹង របស់ព្រះអរហន្ត ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ មិនដឹងក្នុងសិក្ខា មិនដឹងក្នុងចំណែកខាងដើម មិនដឹងក្នុងចំណែកខាងចុង មិនដឹងក្នុងចំណែកខាងដើមនិងចំណែកខាងចុង មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៥៣ ) ការមិនដឹង របស់ព្រះអរហន្ត ក្នុងព្រះសាស្តា ការមិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ មិនដឹងក្នុងសិក្ខា មិនដឹងក្នុងចំណែកខាងដើម មិនដឹងក្នុងចំណែកខាងចុង មិនដឹងក្នុងចំណែកខាងដើមនិងចំណែកខាងចុង មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មិនមានទេឬ ។ អើ ។ បើការមិនដឹង របស់ព្រះអរហន្ត

អញ្ញាណកថា

សត្ថរិ អញ្ញាណំ ធម្មេ អញ្ញាណំ សង្ឃេ អញ្ញាណំ ។បេ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ នោ វត រេ វត្តព្វេ អត្ថិ អរហតោ អញ្ញាណន្តិ ។

( ៥៤ ) អត្ថិ បុថុជ្ជនស្ស អញ្ញាណំ អត្ថិ តស្ស សត្ថរិ អញ្ញាណំ ធម្មេ អញ្ញាណំ សង្ឃេ អញ្ញាណំ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណន្តិ ។ អាមន្តា ។ អត្ថិ អរហតោ អញ្ញាណំ អត្ថិ តស្ស សត្ថរិ អញ្ញាណំ ធម្មេ អញ្ញាណំ សង្ឃេ អញ្ញាណំ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

( ៥៥ ) អត្ថិ អរហតោ អញ្ញាណំ នត្ថិ តស្ស សត្ថរិ អញ្ញាណំ ធម្មេ អញ្ញាណំ សង្ឃេ អញ្ញាណំ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណន្តិ ។ អាមន្តា ។ អត្ថិ បុថុជ្ជនស្ស អញ្ញាណំ នត្ថិ តស្ស សត្ថរិ អញ្ញាណំ ធម្មេ អញ្ញាណំ សង្ឃេ អញ្ញាណំ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ ។ បេ ។ មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

(៩៨) ការមិនដឹង របស់បុថុជ្ជន មាន ការមិនដឹង របស់បុថុជ្ជននោះ ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ ។ បេ ។ មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានដែរឬ ។ អើ ។ ការមិនដឹង របស់ព្រះអរហន្ត មាន ការមិនដឹង របស់ព្រះអរហន្តនោះ ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ ។ បេ ។ មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩៩) ការមិនដឹង របស់ព្រះអរហន្ត មាន ការមិនដឹង របស់ព្រះអរហន្តនោះ ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ ។ បេ ។ មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មិនមានទេឬ ។ អើ ។ ការមិនដឹង របស់បុថុជ្ជន មាន ការមិនដឹង របស់បុថុជ្ជននោះ ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ ។ បេ ។ មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨៦) អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ ននុ អរហតោ រាគោ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោតិ ។ អាមន្តា ។ ហញ្ចិ អរហតោ រាគោ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ នោ វត រេ វត្តព្វេ អត្ថិ អរហតោ អញ្ញាណន្តិ ។បេ។ ននុ អរហតោ ទោសោ បហីនោ ។បេ។ មោហោ បហីនោ ។បេ។ អនោត្តប្បំ បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មន្តិ ។ អាមន្តា ។ ហញ្ចិ អរហតោ អនោត្តប្បំ បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អនុប្បាទធម្មំ នោ វត រេ វត្តព្វេ អត្ថិ អរហតោ អញ្ញាណន្តិ ។

(៨៧) អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ ននុ អរហតោ រាគប្បហានាយ មគ្គោ ភាវិតោ ។បេ។ ពោជ្ឈង្គា ភាវិតាតិ ។ អាមន្តា ។ ហញ្ចិ អរហតោ រាគប្បហានាយ ពោជ្ឈង្គា ភាវិតា នោ វត រេ វត្តព្វេ អត្ថិ អរហតោ អញ្ញាណន្តិ ។

(៨៨) អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។

[ ៤៦ ] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែង ព្រះអរហន្ត លះរាគៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅ នៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះរាគៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅ ទៀត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។ បេ ។ ក្រែងព្រះអរហន្ត លះទោសៈ ។ បេ ។ លះមោហៈ ។ បេ ។ លះអនោត្តប្បៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើម ត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះអនោត្តប្បៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតត ទៅទៀត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះ អរហន្ត មានទេ ។

[ ៤៧ ] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែង ព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះរាគៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គៈ ដើម្បីលះរាគៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[ ៤៨ ] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។

អញ្ញាណកថា

ននុ អរហតោ ទោសប្បហានាយ ។ បេ ។ អនោត្ត-ប្បប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតាតិ ។ អាមន្តា ។ ហញ្ចិ អរហតោ អនោត្តប្ប-ប្បហានាយ ពោជ្ឈង្គា ភាវិតា នោ វត រេ វត្តព្វេ អត្ថិ អរហតោ អញ្ញាណន្តិ ។

(៥៩) អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ ននុ អរហា វីតរាគោ វីតទោសោ វីតមោហោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតន្តិ ។ អាមន្តា ។ ហញ្ចិ អរហា វីតរាគោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ នោ វត រេ វត្តព្វេ អត្ថិ អរហតោ អញ្ញាណន្តិ ។

(៦០) អត្ថិ អរហតោ អញ្ញាណន្តិ ។ សធម្ម-កុសលស្ស អរហតោ អត្ថិ អញ្ញាណំ បរធម្មកុស-លស្ស អរហតោ នត្ថិ អញ្ញាណន្តិ ។ សធម្មកុស-លស្ស អរហតោ អត្ថិ អញ្ញាណន្តិ ។ អាមន្តា ។ បរធម្មកុសលស្ស អរហតោ អត្ថិ អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ក្រែងព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះទោសៈ ។បេ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គៈ ដើម្បីលះអនោត្តប្បៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

( ៥៩ ) ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។ បេ ។ សច្ឆិកាតព្វកិច្ច (កិច្ចដែលគួរធ្វើឲ្យជាក់ច្បាស់) លោកធ្វើឲ្យជាក់ច្បាស់ហើយឬ ។ អើ ។ បើព្រះអរហន្ត ប្រាសចាករាគៈ ។ បេ ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

( ៦០ ) ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ ការមិនដឹង របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មាន ការមិនដឹង របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មិនមានទេ ។ ការមិនដឹង របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មានដែរឬ ។ អើ ។ ការមិនដឹង របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៥១) បរធម្មកុសលស្ស អរហតោ នត្ថិ អញ្ញាណន្តិ ។ អាមន្តា ។ សធម្មកុសលស្ស អរហតោ នត្ថិ អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦២) សធម្មកុសលស្ស អរហតោ រាគោ បហីនោ អត្ថិ តស្ស អញ្ញាណន្តិ ។ អាមន្តា ។ បរធម្មកុសលស្ស អរហតោ រាគោ បហីនោ អត្ថិ តស្ស អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៣) សធម្មកុសលស្ស អរហតោ ទោសោ បហីនោ មោហោ បហីនោ ។ បេ ។ អនោត្តប្បំ បហីនំ អត្ថិ តស្ស អញ្ញាណន្តិ ។ អាមន្តា ។ បរធម្មកុសលស្ស អរហតោ អនោត្តប្បំ បហីនំ អត្ថិ តស្ស អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៤) សធម្មកុសលស្ស អរហតោ រាគប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា អត្ថិ តស្ស អញ្ញាណន្តិ ។ អាមន្តា ។ បរធម្មកុសលស្ស អរហតោ រាគប្បហានាយ[1] ពោជ្ឈង្គា ភាវិតា អត្ថិ តស្ស អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

---

១ ឱ. ឥតោ បរំ មគ្គោ ភាវិតោ ។បេ។ ឥតិ បាឋោ ទិស្សតិ ។

[ ៦១ ] ការមិនដឹង របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មិនមានទេឬ ។ អើ ។ ការមិនដឹង របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៦២ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះរាគៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះរាគៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៦៣ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះទោសៈ លះមោហៈ ។ បេ ។ លះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៦៤ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ចម្រើនមគ្គដើម្បីលះរាគៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ចម្រើនពោជ្ឈង្គៈ ដើម្បីលះរាគៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## អញ្ញាណកថា

(៦៥) សធម្មកុសលស្ស អរហតោ ទោសប្ប-ហាណាយ ។ បេ ។ អនោត្តប្បប្បហាណាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា អត្ថិ តស្ស អញ្ញាណន្តិ ។ អាមន្តា ។ បរធម្មកុសលស្ស អរហតោ អនោត្តប្បប្បហាណាយ ពោជ្ឈង្គា ភាវិតា អត្ថិ តស្ស អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦) សធម្មកុសលោ អរហា វីតរាគោ វីតទោ-សោ វីតមោហោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ អត្ថិ តស្ស អញ្ញាណន្តិ ។ អាមន្តា ។ បរធម្មកុសលោ អរហា វីតរាគោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ អត្ថិ តស្ស អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៧) បរធម្មកុសលស្ស អរហតោ រាគោ បហីនោ នត្ថិ តស្ស អញ្ញាណន្តិ ។ អាមន្តា ។ សធម្មកុសលស្ស អរហតោ រាគោ បហីនោ នត្ថិ តស្ស អញ្ញាណន្តិ ។

## អញ្ញាណកថា

( ៦៥ ) ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន បម្រើនមគ្គ ដើម្បីលះទោសៈ ។ បេ ។ បម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។ បេ ។ បម្រើនពោជ្ឈង្គៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ បម្រើនពោជ្ឈង្គៈ ដើម្បីលះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៦ ) ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។ បេ ។ សច្ចិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ប្រាសចាករាគៈ ។ បេ ។ សច្ចិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៧ ) ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះរាគៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះរាគៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។

ន ហេវំ វត្តព្វេ ។ បេ ។

[ ៦៨ ] បរធម្មកុសលស្ស អរហតោ ទោសោ បហីនោ ។ បេ ។ អនោត្តប្បំ បហីនំ នត្ថិ តស្ស អញ្ញាណន្តិ ។ អាមន្តា ។ សធម្មកុសលស្ស អរហតោ(១) អនោត្តប្បំ បហីនំ នត្ថិ តស្ស អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៦៩ ] បរធម្មកុសលស្ស អរហតោ រាគប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា ។ បេ ។ អនោត្តប្បប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា នត្ថិ តស្ស អញ្ញាណន្តិ ។ អាមន្តា ។ សធម្មកុសលស្ស អរហតោ អនោត្តប្បប្បហានាយ ពោជ្ឈង្គា ភាវិតា នត្ថិ តស្ស អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៧០ ] បរធម្មកុសលោ អរហា វីតរាគោ វីតទោសោ វីតមោហោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ នត្ថិ តស្ស អញ្ញាណន្តិ ។ អាមន្តា ។ សធម្មកុសលោ អរហា វីតរាគោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ

---

១ ឱ. បោត្ថកេ ឯត្តន្តរេ ទោសោ បហីនោ ។បេ។ ឥតិ លិខិតំ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៨ ) ព្រះអរហន្ត អ្នកឃ្លាសកនូវធម៌ដទៃ លះរាគៈ ។ បេ ។ លះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឃ្លាសកនូវធម៌របស់ខ្លួន លះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៩ ) ព្រះអរហន្ត អ្នកឃ្លាសកនូវធម៌ដទៃ ចម្រើនមគ្គ ដើម្បីលះរាគៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ។ បេ ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឃ្លាសកនូវធម៌របស់ខ្លួន ចម្រើនពោជ្ឈង្គៈ ដើម្បីលះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៧០ ) ព្រះអរហន្ត អ្នកឃ្លាសកនូវធម៌ដទៃ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។ បេ ។ សច្ចិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឃ្លាសកនូវធម៌របស់ខ្លួន ប្រាសចាករាគៈ ។ បេ ។ សច្ចិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការមិនដឹង របស់ព្រះអរហន្តនោះ

## អញ្ញាណកថា

នត្ថិ តស្ស អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

(៧១) អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ជានតោហំ ភិក្ខវេ បស្សតោ អាសវានំ ខយំ វទាមិ នោ អជានតោ នោ អបស្សតោ កិញ្ច ភិក្ខវេ ជានតោ កឹ បស្សតោ អាសវានំ ខយោ ហោតិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា ។បេ។ ឥតិ សញ្ញា ។បេ។ ឥតិ សង្ខារា ។បេ។ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ឯវំ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ អាសវានំ ខយោ ហោតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ អត្ថិ អរហតោ អញ្ញាណន្តិ ។

(៧២) អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ជានតោហំ ភិក្ខវេ បស្សតោ

មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៧១ ) ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញ មិនពោលនូវការអស់ទៅ នៃអាសវៈ របស់បុគ្គល កាលមិនដឹង មិនពោលនូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលមិនឃើញទេ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹងដូចម្ដេច កាលឃើញដូចម្ដេច (ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញយ៉ាងនេះថា) រូប ដូច្នេះ ការកើតឡើងនៃរូប ដូច្នេះ សេចក្ដីវិនាសទៅនៃរូប ដូច្នេះ វេទនា ដូច្នេះ ។ បេ ។ សញ្ញាដូច្នេះ ។ បេ ។ សង្ខារទាំងឡាយ ដូច្នេះ ។ បេ ។ វិញ្ញាណ ដូច្នេះ ការកើតឡើងនៃវិញ្ញាណ ដូច្នេះ ការវិនាសទៅនៃវិញ្ញាណ ដូច្នេះ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះ ដូច្នេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

( ៧២ ) ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅ នៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញ

អាសវានំ ខយំ វទាមិ នោ អជានតោ នោ អបស្សតោ កិញ្ច ភិក្ខវេ ជានតោ កឹ បស្សតោ អាសវានំ ខយោ ហោតិ ឥទំ ទុក្ខន្តិ ភិក្ខវេ ជានតោ បស្សតោ អាសវានំ ខយោ ហោតិ អយំ ទុក្ខសមុទយោតិ ជានតោ បស្សតោ អាសវានំ ខយោ ហោតិ អយំ ទុក្ខនិរោធោតិ ជានតោ បស្សតោ អាសវានំ ខយោ ហោតិ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ ជានតោ បស្សតោ អាសវានំ ខយោ ហោតិ ឯវំ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ អាសវានំ ខយោ ហោតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ អត្ថិ អរហតោ អញ្ញាណន្តិ ។

[ ៧៣ ] អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សព្វំ ភិក្ខវេ អនភិជានំ អបរិជានំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ សព្វញ្ច ខោ ភិក្ខវេ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយាតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។

មិនពោលនូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលមិនដឹង មិនពោលនូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលមិនឃើញទេ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹងដូចម្តេច កាលឃើញដូចម្តេច ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញថា នេះជាទុក្ខ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹងថា នេះជាទុក្ខសមុទ័យ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញថា នេះជាទុក្ខនិរោធ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញថា នេះជាទុក្ខនិរោធគាមិនីបដិបទា ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

( ៧៣ ) ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គ កាលមិនដឹងច្បាស់ មិនកំណត់ដឹង មិនបន្ទោបង់ មិនលះបង់ នូវធម៌ទាំងពួង មិនគួរដើម្បីអស់ទៅនៃទុក្ខ ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលដឹងច្បាស់ កំណត់ដឹង បន្ទោបង់ លះបង់ នូវធម៌ទាំងពួង គួរដើម្បីអស់ទៅនៃទុក្ខ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។

## អញ្ញាណកថា

តេន ហិ ន វត្តព្វំ អត្ថិ អរហតោ អញ្ញាណន្តិ ។

(៧៤) អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

សហាវស្ស ទស្សនសម្បទាយ
តយស្សុ ធម្មា ជហិតា ភវន្តិ
សក្កាយទិដ្ឋិ វិចិកិច្ឆិតញ្ច
( ៣០៤ ) ចិត្ត ដែលប្រកបដោយផស្សៈ រួចស្រឡះ ចុះផស្សៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ ចិត្ត ដែលប្រកបដោយមោហៈ រួចស្រឡះ ចុះមោហៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣០៥ ) ចិត្ត ដែលប្រកបដោយវេទនា ។ បេ ។ ប្រកបដោយសញ្ញា ។ បេ ។ ប្រកបដោយចេតនា ។ បេ ។ ប្រកបដោយបញ្ញា រួចស្រឡះ ចុះបញ្ញានិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ ចិត្ត ដែលប្រកបដោយមោហៈ រួចស្រឡះ ចុះមោហៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣០៦ ) ចិត្ត ដែលប្រកបដោយផស្សៈ ប្រកបដោយមោហៈ រួចស្រឡះ ចុះផស្សៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ មោហៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣០៧) សវេទនំ សមោហំ ។បេ។ សសញ្ញំ សមោហំ ។បេ។ សចេតនំ សមោហំ ។បេ។ សបញ្ញំ សមោហំ ចិត្តំ វិមុច្ចតិ បញ្ញា ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ អាមន្តា ។ មោហោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣០៨) ន វត្តព្វំ(១) សរាគំ សទោសំ សមោហំ ចិត្តំ វិមុច្ចតីតិ ។ អាមន្តា ។ វីតរាគំ វីតទោសំ វីតមោហំ និក្កិលេសំ ចិត្តំ វិមុច្ចតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ តេន ហិ(២) សរាគំ សទោសំ សមោហំ ចិត្តំ វិមុច្ចតីតិ ។

វិមុត្តិកថា ។

# វិមុច្ចមានកថា

(៣០៩) វិមុត្តំ វិមុច្ចមានន្តិ ។ អាមន្តា ។ ឯកទេសំ វិមុត្តំ ឯកទេសំ អវិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

---

១ ម. ន វត្តព្វន្តិ អយមេវ បាឋោ ន វិជ្ជតិ ។ ២ ម. ឯត្ថន្តរេ ន វត្តព្វន្តិ ទិស្សតិ ។

( ៣០៧ ) ចិត្ត ដែលប្រកបដោយវេទនា ប្រកបដោយមោហៈ ។ បេ ។ ប្រកបដោយសញ្ញា ប្រកបដោយមោហៈ ។ បេ ។ ប្រកបដោយចេតនា ប្រកបដោយមោហៈ ។ បេ ។ ប្រកបដោយបញ្ញា ប្រកបដោយមោហៈ រួចស្រឡះ ចុះបញ្ញានិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ មោហៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣០៨ ) បុគ្គលមិនគួរនិយាយថា ចិត្ត ដែលប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ រួចស្រឡះទេឬ ។ អើ ។ ចិត្ត ដែលប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនមានកិលេស រួចស្រឡះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ ចិត្ត ដែលប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ រមែងរួចស្រឡះ ( ចាកអាសវៈ ) ។

ចប់ វិមុត្តិកថា ។

## វិមុច្ចមានកថា

( ៣០៩ ) ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះ មែនឬ ។ អើ ។ ចិត្តរួចស្រឡះហើយ មួយផ្នែក ចិត្តមិនទាន់រួចស្រឡះហើយ មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣១០) ឯកច្ចេសំ វិមុត្តំ ឯកច្ចេសំ អវិមុត្តន្តិ ។ អាមន្តា ។ ឯកច្ចេសំ សោតាបន្នោ ឯកច្ចេសំ ន សោតាបន្នោ ឯកច្ចេសំ សោតាបត្តិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ឯកច្ចេសំ ន កាយេន ផុសិត្វា វិហរតិ ឯកច្ចេសំ សត្តក្ខត្តុំ[១]បរមោ កោលំកោលោ ឯកពីជី ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ធម្មេ ។ បេ ។ សង្ឃេ ។ បេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ឯកច្ចេសំ អរិយកន្តេហិ សីលេហិ ន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣១១) ឯកច្ចេសំ វិមុត្តំ ឯកច្ចេសំ អវិមុត្តន្តិ ។ អាមន្តា ។ ឯកច្ចេសំ សកទាគាមី ឯកច្ចេសំ ន សកទាគាមី ឯកច្ចេសំ សកទាគាមិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ឯកច្ចេសំ ន កាយេន ផុសិត្វា វិហរតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

---

១ ម. សត្តក្ខត្តុបរមោ ។

(៣១០) ចិត្តប្រែប្រួលហើយ មួយផ្នែក ចិត្តមិនទាន់ប្រែប្រួលហើយ មួយផ្នែក មែនឬ ។ អើ ។ បុគ្គល ជាសោតាបន្នៈ មួយផ្នែក មិនមែនជាសោតាបន្នៈ មួយផ្នែក បុគ្គលដល់នូវសោតាបត្តិផល ដែលបានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ មួយផ្នែក មិនពាល់ត្រូវដោយនាមកាយ មួយផ្នែក សត្តក្ខត្តុំបរមបុគ្គល កោលំកោលបុគ្គល ឯកពីជិបុគ្គល ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ ។ បេ ។ ក្នុងព្រះសង្ឃ ។ បេ ។ ប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយៈទាំងឡាយ មួយផ្នែក មិនប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយៈទាំងឡាយ មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣១១) ចិត្តប្រែប្រួលហើយ មួយផ្នែក ចិត្តមិនទាន់ប្រែប្រួលហើយ មួយផ្នែក មែនឬ ។ អើ ។ បុគ្គល ជាសកទាគាមី មួយផ្នែក មិនមែនជាសកទាគាមី មួយផ្នែក បុគ្គល ដល់នូវសកទាគាមិផល ដែលបានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ មួយផ្នែក មិនពាល់ត្រូវដោយនាមកាយ មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣១២) ឯកទេសំ វិមុត្តំ ឯកទេសំ អវិមុត្តន្តិ ។ អាមន្តា ។ ឯកទេសំ អនាគាមី ឯកទេសំ ន អនាគាមី ឯកទេសំ អនាគាមិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ឯកទេសំ ន កាយេន ផុសិត្វា វិហរតិ ឯកទេសំ អន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតោ អកនិដ្ឋគាមី ឯកទេសំ ន ឧទ្ធំសោតោ ន[១] អកនិដ្ឋគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣១៣) ឯកទេសំ វិមុត្តំ ឯកទេសំ អវិមុត្តន្តិ ។ អាមន្តា ។ ឯកទេសំ អរហា ឯកទេសំ ន អរហា ឯកទេសំ អរហត្តប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ឯកទេសំ ន កាយេន ផុសិត្វា វិហរតិ ឯកទេសំ វីតរាគោ វីតទោសោ វីតមោហោ ។ បេ ។ ឯកទេសំ សច្ឆិកាតព្វំ សច្ឆិកតំ ឯកទេសំ សច្ឆិកាតព្វំ ន សច្ឆិកតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

---

១ ម. នសេក្ខោ នត្ថិ ។

[ ៣១២ ] ចិត្តរួចស្រឡះហើយ មួយផ្នែក ចិត្តមិនទាន់រួចស្រឡះហើយ មួយផ្នែក មែនឬ ។ អើ ។ បុគ្គល ជាអនាគាមី មួយផ្នែក មិនមែនជាអនាគាមី មួយផ្នែក បុគ្គលដល់នូវអនាគាមិផល ដែលបានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ មួយផ្នែក មិនពាល់ត្រូវដោយនាមកាយ មួយផ្នែក ជាអន្តុបរិទិញាយី ជាឧបហច្ចបរិនិព្វាយី ជាអសង្ខារបរិនិព្វាយី ជាសសង្ខារបរិនិព្វាយី ជាឧទ្ធំសោតៈ អកនិដ្ឋគាមី មួយផ្នែក មិនមែនជាឧទ្ធំសោតៈ មិនមែនជាអកនិដ្ឋគាមី មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣១៣ ] ចិត្តរួចស្រឡះហើយ មួយផ្នែក ចិត្តមិនទាន់រួចស្រឡះហើយ មួយផ្នែក មែនឬ ។ អើ ។ បុគ្គល ជាអរហន្ត មួយផ្នែក មិនមែនជាអរហន្ត មួយផ្នែក បុគ្គលដល់នូវអរហត្ត ដែលបានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ មួយផ្នែក មិនពាល់ត្រូវដោយនាមកាយ មួយផ្នែក បុគ្គល ប្រាសចាកពកៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មួយផ្នែក ។ បេ ។ សច្ឆិកាតព្វកិច្ច លោកបានធ្វើឲ្យជាក់ច្បាស់ហើយ មួយផ្នែក សច្ឆិកាតព្វកិច្ច លោកមិនបាធ្វើឲ្យជាក់ច្បាស់ហើយ មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេឬ ។ បេ ។

(៣១៤) វិមុត្តំ វិមុច្ចមានន្តិ ។ អាមន្តា ។ ឧប្បា-ទក្ខណេ វិមុត្តំ វយក្ខណេ វិមុច្ចមានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣១៥) ន វត្តព្វំ វិមុត្តំ វិមុច្ចមានន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ វិមុត្តំ វិមុច្ចមានន្តិ ។

(៣១៦) វិមុត្តំ វិមុច្ចមានន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញា-ណាយ ចិត្តំ អភិនិន្នាមេតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ វិមុត្តំ វិមុច្ចមានន្តិ ។

( ៣១៤ ) ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះ មែនឬ ។ អើ ។ ចិត្តដែលរួចស្រឡះហើយ ក្នុងខណៈដែលកើតឡើង ចិត្តកំពុងរួចស្រឡះ ក្នុងខណៈសាបសូន្យ មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣១៥ ) បុគ្គលមិនគួរពោលថា ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះ មែនឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា កាលបុគ្គលនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តរមែងរួចស្រឡះចាកកាមាសវៈផង ចិត្តរួចស្រឡះ ចាកភវាសវៈផង ចិត្តរួចស្រឡះចាកអវិជ្ជាសវៈផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ចិត្ត ឈ្មោះថារួចស្រឡះហើយ ឈ្មោះថាកំពុងរួចស្រឡះ ។

( ៣១៦ ) ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះ (ឈ្មោះថារួច) មែនឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា កាលដែលចិត្ត ខាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រ យ៉ាងនេះហើយ បុគ្គលនោះ រមែងបង្អោនចិត្ត ដើម្បីញាណជាហេតុឲ្យអស់ទៅ នៃអាសវៈទាំងឡាយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គល មិនគួរពោលថា ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះទេ ។

[៣១៧] អត្ថិ ចិត្តំ វិមុច្ចមានន្តិ ។ អាមន្តា ។ អត្ថិ ចិត្តំ រជ្ជមានំ ទុស្សមានំ មុយ្ហមានំ កិលិស្សមានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ រត្តញ្ចេវ អរត្តញ្ច ទុដ្ឋញ្ចេវ អទុដ្ឋញ្ច មូឡ្ហញ្ចេវ អមូឡ្ហញ្ច ឆិន្នញ្ចេវ អច្ឆិន្នញ្ច ភិន្នញ្ចេវ អភិន្នញ្ច កតញ្ចេវ អកតញ្ចាតិ ។ អាមន្តា ។ ហញ្ចិ រត្តញ្ចេវ អរត្តញ្ច ទុដ្ឋញ្ចេវ អទុដ្ឋញ្ច មូឡ្ហញ្ចេវ អមូឡ្ហញ្ច ឆិន្នញ្ចេវ អច្ឆិន្នញ្ច ភិន្នញ្ចេវ អភិន្នញ្ច កតញ្ចេវ អកតញ្ច តេន វត រេ វត្តព្វេ អត្ថិ ចិត្តំ វិមុច្ចមានន្តិ ។

វិមុច្ចមានកថា ។

## អដ្ឋមកកថា

[៣១៨] អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកោ បុគ្គលោ សោតាបន្នោ សោតាបត្តិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

### វិមុច្ចមានកថា

( ៣១៧ ) ចិត្តកំពុងរួចស្រឡះ មានឬ ។ អើ ។ ចិត្តកំពុងត្រេកអរ កំពុងខឹង កំពុងវង្វេង កំពុងសៅហ្មង មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងចិត្ត ដែលត្រេកអរផង មិនត្រេកអរផង ខឹងផង មិនខឹងផង វង្វេងផង មិនវង្វេងផង ដាច់ផង មិនដាច់ផង បែកផង មិនបែកផង ធ្វើផង មិនធ្វើផង មានឬ ។ អើ ។ ប្រសិនបើចិត្ត ត្រេកអរផង មិនត្រេកអរផង ខឹងផង មិនខឹងផង វង្វេងផង មិនវង្វេងផង ដាច់ផង មិនដាច់ផង បែកផង មិនបែកផង ធ្វើផង មិនធ្វើផង មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្តកំពុងរួចស្រឡះ មានទេ ។

ចប់ វិមុច្ចមានកថា ។

## អដ្ឋមកកថា

( ៣១៨ ) ទិដ្ឋិបរិយុដ្ឋានៈ ( ការស្ទាក់ដំណើរគឺទិដ្ឋិ ) គឺបុគ្គលទី ៨[១] លះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ ជាសោតាបន្នៈ ដល់សោតាបត្តិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេចពាល់ត្រូវដោយនាមកាយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

---

១ អរិយបុគ្គល ៨ ពួក បុគ្គលដែលឋិតនៅក្នុងសោតាបត្តិមគ្គ រាប់ថាជាបុគ្គលទី ៨ ក្នុងទីនេះ ។

(៣១៩) អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកោ បុគ្គលោ សោតាបន្នោ សោតាបត្តិផលប្បត្តោ ។ បេ ។ កាយេន ផុសិត្វា វិហរតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២០) អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋានុសយោ បហីនោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆានុសយោ ។ បេ ។ សីលព្វតបរាមាសោ បហីនោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២១) អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆានុសយោ បហីនោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋានុសយោ ។ បេ ។ សីលព្វតបរាមាសោ បហីនោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៣៥៩ ) វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ ជាសោតាបន្នៈ ដល់នូវសោតាបត្តិផល ។ បេ ។ ពាល់ត្រូវដោយនាមកាយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៦០ ) ទិដ្ឋិបរិយុដ្ឋានៈ បុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ ទិដ្ឋានុស័យ បុគ្គលទី ៨ លះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទិដ្ឋិបរិយុដ្ឋានៈ បុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ វិចិកិច្ឆានុស័យ បុគ្គលទី ៨ លះបង់ហើយ ។ បេ ។ សីលព្វតបរាមាសៈ លោកលះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៦១ ) វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ វិចិកិច្ឆានុស័យ បុគ្គលទី ៨ លះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ ទិដ្ឋានុស័យ បុគ្គលទី ៨ លះបង់ហើយ ។ បេ ។ សីលព្វតបរាមាសៈ លោកលះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## អដ្ឋមកកថា

(៣២២) អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋានុសយោ អប្បហីនោតិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ អប្បហីនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋានុសយោ អប្បហីនោតិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ អប្បហីនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆានុសយោ ។ បេ ។ សីលព្វតបរាមាសោ អប្បហីនោតិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ អប្បហីនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស សីលព្វតបរាមាសោ អប្បហីនោតិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ អប្បហីនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២៣) អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានប្បហានាយ មគ្គោ ភាវិតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនន្តិ ។

( ៣២២ ) ទិដ្ឋានុស័យ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អើ ។ ទិដ្ឋិបរិយុដ្ឋានៈ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទិដ្ឋានុស័យ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អើ ។ វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិចិកិច្ឆានុស័យ បុគ្គលទី ៨ មិនបានលះបង់ទេ ។ បេ ។ សីលព្វតបរាមាសៈ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អើ ។ ទិដ្ឋិបរិយុដ្ឋានៈ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សីលព្វតបរាមាសៈ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អើ ។ វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣២៣ ) ទិដ្ឋិបរិយុដ្ឋានៈ បុគ្គលទី៨ បានលះបង់ហើយឬ ។ អើ ។ បុគ្គលទី៨ បានចម្រើនមគ្គ ដើម្បីលះបង់ទិដ្ឋិបរិយុដ្ឋានៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលទី ៨ បានលះបង់ទិដ្ឋិបរិយុដ្ឋានៈឬ ។

អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានប្ប-
ហានាយ សតិប្បដ្ឋានា ភាវិតា ។ បេ ។ សម្មប្បធានា
។ បេ ។ ពោជ្ឈង្គា ភាវិតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២៤) អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិ-
យុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គ-
លស្ស វិចិកិច្ឆាបរិយុដ្ឋានប្បហានាយ មគ្គោ ភាវិតោ
។ បេ ។ ពោជ្ឈង្គា ភាវិតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២៥) អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋា-
នប្បហានាយ មគ្គោ អភាវិតោតិ ។ អាមន្តា ។ អ-
មគ្គេន បហីនំ លោកិយេន សាសវេន ។ បេ ។ សង្កិ-
លេសិកេនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋម-
កស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានប្បហានាយ សតិប្ប-
ដ្ឋានា ។ បេ ។ ពោជ្ឈង្គា អភាវិតាតិ ។ អាមន្តា ។
អមគ្គេន បហីនំ លោកិយេន សាសវេន ។ បេ ។
សង្កិលេសិកេនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២៦) អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិ-
យុដ្ឋានប្បហានាយ មគ្គោ អភាវិតោ ។ បេ ។
សតិប្បដ្ឋានា ។ បេ ។ ពោជ្ឈង្គា អភាវិតាតិ ។

អើ ។ បុគ្គលទី៨ បានចម្រើនសតិប្បដ្ឋាន ។បេ។ សម្មប្បធាន ។បេ។ បានចម្រើនពោជ្ឈង្គៈ ដើម្បីលះបង់ទិដ្ឋិបរិយុដ្ឋានៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣៦៤) វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ បានលះបង់ហើយឬ ។ អើ ។ បុគ្គលទី៨ បានចម្រើនមគ្គ ។បេ។ បានចម្រើនពោជ្ឈង្គៈ ដើម្បីលះបង់វិចិកិច្ឆាបរិយុដ្ឋានៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣៦៥) បុគ្គលទី៨ មិនបានចម្រើនមគ្គ ដើម្បីលះបង់ទិដ្ឋិបរិយុដ្ឋានៈទេឬ ។ អើ ។ បរិយុដ្ឋានកិលេស គឺលោកលះបង់ហើយ ដោយធម៌មិនមែនជាមគ្គ ជាលោកិយៈ ប្រកបដោយអាសវៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មង មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលទី៨ មិនបានចម្រើនសតិប្បដ្ឋាន ។បេ។ មិនបានចម្រើនពោជ្ឈង្គៈ ដើម្បីលះបង់ទិដ្ឋិបរិយុដ្ឋានៈទេឬ ។ អើ ។ (បរិយុដ្ឋានកិលេស) គឺលោកលះបង់ហើយ ដោយធម៌មិនមែនជាមគ្គ ជាលោកិយៈ ប្រកបដោយអាសវៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មង មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣៦៦) បុគ្គលទី៨ មិនបានចម្រើនមគ្គ ។បេ។ សតិប្បដ្ឋាន ។បេ។ មិនបានចម្រើនពោជ្ឈង្គៈ ដើម្បីលះបង់វិចិកិច្ឆាបរិយុដ្ឋានៈទេឬ ។

អាមន្តា ។ អមគ្គេន បហីនំ លោកិយេន សាសវេន ។បេ។ សង្កិលេសិកេនាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣២៧) ន វត្តព្វំ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ ឧប្បជ្ជិស្សតីតិ ។ នុប្បជ្ជិស្សតីតិ ។ ហញ្ចិ នុប្បជ្ជិស្សតិ តេន វត រេ វត្តព្វេ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនន្តិ ។

(៣២៨) ន វត្តព្វំ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ ឧប្បជ្ជិស្សតីតិ ។ នុប្បជ្ជិស្សតីតិ ។ ហញ្ចិ នុប្បជ្ជិស្សតិ តេន វត រេ វត្តព្វេ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ បហីនន្តិ ។

(៣២៩) អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ នុប្បជ្ជិស្សតីតិ កត្វា បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋានុសយោ នុប្បជ្ជិស្សតីតិ កត្វា បហីនោតិ ។ ន ហេវំ វត្តព្វេ ។បេ។

អើ ៗ (បរិយុដ្ឋានកិលេស) គឺលោកលះបង់ហើយ ដោយធម៌មិនមែនជាមគ្គ ជាលោកិយៈ ប្រកបដោយអាសវៈ ។ បេ ។ ប្រកបដោយសេចក្តីសៅហ្មង មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៦៧] បុគ្គលមិនគួរពោលថា ទិដ្ឋិបរិយុដ្ឋានៈ បុគ្គលទី ៨ បានលះបង់ហើយឬ ។ អើ ។ ទិដ្ឋិបរិយុដ្ឋានៈ នឹងកើតឡើងឬ ។ ទិដ្ឋិ-បរិយុដ្ឋានៈ នឹងមិនកើតឡើងទេ ។ ប្រសិនបើ ទិដ្ឋិបរិយុដ្ឋានៈ នឹងមិនកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ទិដ្ឋិបរិយុដ្ឋានៈ បុគ្គលទី ៨ បានលះបង់ហើយ ។

[៣៦៨] បុគ្គលមិនគួរពោលថា វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ បានលះបង់ហើយឬ ។ អើ ។ វិចិកិច្ឆាបរិយុដ្ឋានៈ នឹងកើតឡើងឬ ។ វិចិកិច្ឆាបរិយុដ្ឋានៈ នឹងមិនកើតឡើងទេ ។ ប្រសិនបើ វិចិកិច្ឆា-បរិយុដ្ឋានៈ នឹងមិនកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ បានលះបង់ហើយ ។

[៣៦៩] បុគ្គលទី ៨ ធ្វើសេចក្តីចូលចិត្តថា ទិដ្ឋិបរិយុដ្ឋានៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ ធ្វើសេចក្តីចូលចិត្តថា ទិដ្ឋានុស័យ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៣០) អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ ឧប្បជ្ជិស្សតីតិ កត្វា បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆានុសយោ ។ បេ ។ សីលព្វតបរាមាសោ ឧប្បជ្ជិស្សតីតិ កត្វា បហីនោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៣១) អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ ឧប្បជ្ជិស្សតីតិ កត្វា បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆានុសយោ ។ បេ ។ សីលព្វតបរាមាសោ ឧប្បជ្ជិស្សតីតិ កត្វា បហីនោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៣២) អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ ឧប្បជ្ជិស្សតីតិ កត្វា បហីនន្តិ ។ អាមន្តា ។ គោត្រភុនោ បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ ឧប្បជ្ជិស្សតីតិ កត្វា បហីនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៣៣) អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ ឧប្បជ្ជិស្សតីតិ កត្វា បហីនន្តិ ។ អាមន្តា ។ គោត្រភុនោ បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ ឧប្បជ្ជិស្សតីតិ កត្វា បហីនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អដ្ឋមកកថា ។

[ ៣៣០ ] បុគ្គលទី ៨ ធ្វើសេចក្តីប្តូលចិត្តថា ទិដ្ឋិបរិយុដ្ឋានៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ ធ្វើសេចក្តីប្តូលចិត្តថា វិចិកិច្ឆានុស័យ ។ បេ ។ សីលព្វតបរាមាសៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៣១ ] បុគ្គលទី ៨ ធ្វើសេចក្តីប្តូលចិត្តថា វិចិកិច្ឆាបរិយុដ្ឋានៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ ធ្វើសេចក្តីប្តូលចិត្តថា វិចិកិច្ឆានុស័យ ។ បេ ។ សីលព្វតបរាមាសៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៣២ ] បុគ្គលទី ៨ ធ្វើសេចក្តីប្តូលចិត្តថា ទិដ្ឋិបរិយុដ្ឋានៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អើ ។ បុគ្គលជាគោត្រភូ ធ្វើសេចក្តីប្តូលចិត្តថា ទិដ្ឋិបរិយុដ្ឋានៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៣៣ ] បុគ្គលទី ៨ ធ្វើសេចក្តីប្តូលចិត្តថា វិចិកិច្ឆាបរិយុដ្ឋានៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អើ ។ បុគ្គលជាគោ-ត្រភូ ធ្វើសេចក្តីប្តូលចិត្តថា វិចិកិច្ឆាបរិយុដ្ឋានៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ អដ្ឋមកកថា ។

# អដ្ឋមកស្ស ឥន្ទ្រិយកថា

(៣៣៤) អដ្ឋមកស្ស បុគ្គលស្ស នត្ថិ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស នត្ថិ សទ្ធាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៣៥) អដ្ឋមកស្ស បុគ្គលស្ស នត្ថិ វីរិយិន្ទ្រិយំ ។បេ។ នត្ថិ សតិន្ទ្រិយំ ។បេ។ នត្ថិ សមាធិន្ទ្រិយំ ។បេ។ នត្ថិ បញ្ញិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស នត្ថិ បញ្ញាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៣៦) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធាតិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ វីរិយំ ។បេ។ អត្ថិ សតិ អត្ថិ សមាធិ ។បេ។ អត្ថិ បញ្ញាតិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

# អដ្ឋមកឥន្ទ្រិយកថា

(៣៣៤) បុគ្គលទី ៨ មិនមានសទ្ធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ មិនមានសទ្ធាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៣៥) បុគ្គលទី ៨ មិនមានវីរិយិន្ទ្រិយ ។ បេ ។ មិនមានសតិន្ទ្រិយ ។ បេ ។ មិនមានសមាធិន្ទ្រិយ ។ បេ ។ មិនមានបញ្ញិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ មិនមានបញ្ញាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៣៦) បុគ្គលទី ៨ មានសទ្ធាដែរឬ ។ អើ ។ បុគ្គលទី ៨ មានសទ្ធិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលទី ៨ មានវីរិយៈ ។ បេ ។ មានសតិ មានសមាធិ ។ បេ ។ មានបញ្ញាដែរឬ ។ អើ ។ បុគ្គលទី ៨ មានបញ្ញិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## អភិធម្មបិដកេ កថាវត្ថុ

(៣៣៧) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ មនោ អត្ថិ មនិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា អត្ថិ សទ្ធិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ មនោ អត្ថិ មនិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ញា អត្ថិ បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៣៨) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សោមនស្សំ អត្ថិ សោមនស្សិន្ទ្រិយំ ។ បេ ។ អត្ថិ ជីវិតំ អត្ថិ ជីវិតិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា អត្ថិ សទ្ធិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ ជីវិតំ អត្ថិ ជីវិតិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ វីរិយំ ។ បេ ។ អត្ថិ បញ្ញា អត្ថិ បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៣៩) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា នត្ថិ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ មនោ នត្ថិ មនិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៣៣៧ ) បុគ្គលទី ៨ មានមនោ មានមនិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានសទ្ធា មានសទ្ធិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលទី ៨ មានមនោ មានមនិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៣៨ ) បុគ្គលទី ៨ មានសោមនស្ស មានសោមនស្សិន្ទ្រិយ ។ បេ ។ មានជីវិត មានជីវិតិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានសទ្ធា មានសទ្ធិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលទី ៥ មាងជីវិត មានជីវិតិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានវីរិយៈ ។ បេ ។ មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៣៩ ) បុគ្គលទី ៨ មានតែសទ្ធា មិនមានសទ្ធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ មានតែមនោ មិនមានមនិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## អដ្ឋមកស្ស ឥន្ទ្រិយកថា

(៣៤០) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា នត្ថិ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សោមនស្សំ នត្ថិ សោមនស្សិន្ទ្រិយំ ។ បេ ។ អត្ថិ ជីវិតំ នត្ថិ ជីវិតិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៤១) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ញា នត្ថិ បញ្ញិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ មនោ នត្ថិ មនិន្ទ្រិយន្តិ ។ បេ ។ អត្ថិ សោមនស្សំ នត្ថិ សោមនស្សិន្ទ្រិយន្តិ ។ បេ ។ អត្ថិ ជីវិតំ នត្ថិ ជីវិតិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៤២) អដ្ឋមកស្ស បុគ្គលស្ស នត្ថិ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកោ បុគ្គលោ អសទ្ធោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស នត្ថិ វីរិយិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកោ បុគ្គលោ កុសីតោ ហីនវីរិយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស នត្ថិ សតិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកោ បុគ្គលោ មុដ្ឋស្សតិ អសម្បជានោតិ ។

អដ្ឋមកឥន្ទ្រិយកថា

(៣៤០) បុគ្គលទី ៨ មានតែសទ្ធា មិនមានសទ្ធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ មានតែសោមនស្ស មិនមានសោមនស្សិន្ទ្រិយ ។បេ។ មានតែជីវិត មិនមានជីវិតិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣៤១) បុគ្គលទី ៨ មានតែបញ្ញា មិនមានបញ្ញិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ មានតែមនោ មិនមានមនិន្ទ្រិយ ។បេ។ មានតែសោមនស្ស មិនមានសោមនស្សិន្ទ្រិយ ។បេ។ មានតែជីវិត មិនមានជីវិតិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣៤២) បុគ្គលទី ៨ មិនមានសទ្ធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ ជាអ្នកមិនមានសទ្ធាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលទី ៨ មិនមានវីរិយិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ ជាអ្នកខ្ជិលច្រអូស មិនមានព្យាយាមទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលទី ៨ មិនមានសតិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ ជាអ្នកភ្លេចស្មារតី មិនដឹងខ្លួនឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស នត្ថិ សមាធិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកោ បុគ្គលោ អសមាហិតោ វិក្ខិត្តចិត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៤៣) អដ្ឋមកស្ស បុគ្គលស្ស នត្ថិ បញ្ញិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកោ បុគ្គលោ ទុប្បញ្ញោ ឯឡមូគោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៤៤) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា សា ច សទ្ធា និយ្យានិកាតិ ។ អាមន្តា ។ ហញ្ចិ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា សា ច សទ្ធា និយ្យានិកា តេន វត វេ វត្តព្វេ អដ្ឋមកស្ស បុគ្គលស្ស នត្ថិ សទ្ធិន្ទ្រិយន្តិ ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ វីរិយំ តញ្ច វីរិយំ និយ្យានិកំ ។ បេ ។ អត្ថិ សតិ សា ច សតិ និយ្យានិកា ។ បេ ។ អត្ថិ សមាធិ សោ ច សមាធិ និយ្យានិកោ ។ បេ ។ អត្ថិ បញ្ញា សា ច បញ្ញា និយ្យានិកាតិ ។ អាមន្តា ។ ហញ្ចិ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ញា សា ច បញ្ញា និយ្យានិកា តេន វត វេ វត្តព្វេ អដ្ឋមកស្ស បុគ្គលស្ស នត្ថិ បញ្ញិន្ទ្រិយន្តិ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលទី ៨ មិនមានសមាធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ ជាអ្នកមានចិត្តមិនខ្ជាប់ខ្ជួន មានចិត្តរាយមាយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៨៣) បុគ្គលទី ៨ មិនមានបញ្ញិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ ជាអ្នកឥតប្រាជ្ញា ជាមនុស្សល្ងង់ខ្លៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៨៤) បើបុគ្គលទី ៨ មានសទ្ធា ចុះសទ្ធានោះ ជាធម្មជាតិនាំសត្វចេញចាកទុក្ខដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលទី ៨ មានសទ្ធា សទ្ធានោះឯង ជាធម្មជាតិនាំសត្វចេញចាកទុក្ខមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលទី ៨ មិនមានសទ្ធិន្ទ្រិយទេ ។ បុគ្គលទី ៨ មានវីរិយៈ ចុះវីរិយៈនោះ ជាធម្មជាតនាំសត្វចេញចាកទុក្ខ ។ បេ ។ មានសតិ ចុះសតិនោះ ជាធម្មជាតិនាំសត្វចេញចាកទុក្ខ ។ បេ ។ មានសមាធិ ចុះសមាធិនោះ ជាធម៌នាំសត្វចេញចាកទុក្ខ ។ បេ ។ មានបញ្ញា ចុះបញ្ញានោះ ជាធម្មជាតិនាំសត្វចេញចាកទុក្ខដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលទី ៨ មានបញ្ញា បញ្ញានោះឯង ជាធម្មជាតិនាំសត្វចេញចាកទុក្ខមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលទី ៨ មិនមានបញ្ញិន្ទ្រិយទេ ។

( ៣៤៥ ) សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស អត្ថិ សទ្ធា អត្ថិ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា អត្ថិ សទ្ធិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស អត្ថិ បញ្ញា អត្ថិ បញ្ញិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ញា អត្ថិ បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៣៤៦ ) អនាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស ។ បេ ។ អរហត្តសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស អត្ថិ សទ្ធា អត្ថិ សទ្ធិន្ទ្រិយំ ។ បេ ។ អត្ថិ បញ្ញា អត្ថិ បញ្ញិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ញា អត្ថិ បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៣៤៧ ) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា នត្ថិ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស អត្ថិ សទ្ធា នត្ថិ សទ្ធិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

## អដ្ឋមកឥន្ទ្រិយកថា

(៣៨៥) បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល មានសទ្ធា មានសទ្ធិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានសទ្ធា មានសទ្ធិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៨៦) បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ។ បេ ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត មានសទ្ធា មានសទ្ធិន្ទ្រិយ ។ បេ ។ មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៨៧) បុគ្គលទី ៨ មានតែសទ្ធា មិនមានសទ្ធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល មានតែសទ្ធា មិនមានសទ្ធិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ញា នត្ថិ បញ្ញិន្ទ្រិ-
យន្តិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ
បដិបន្នស្ស បុគ្គលស្ស អត្ថិ បញ្ញា នត្ថិ បញ្ញិន្ទ្រិ
យន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៤៨) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា
នត្ថិ សទ្ធិន្ទ្រិយំ ។បេ។ អត្ថិ បញ្ញា នត្ថិ បញ្ញិន្ទ្រិ-
យន្តិ ។ អាមន្តា ។ អនាគាមិផលសច្ឆិកិរិយាយ
បដិបន្នស្ស បុគ្គលស្ស ។បេ។ អរហត្តសច្ឆិកិរិ-
យាយ បដិបន្នស្ស បុគ្គលស្ស អត្ថិ បញ្ញា នត្ថិ
បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៤៩) អដ្ឋមកស្ស បុគ្គលស្ស នត្ថិ បញ្ចិន្ទ្រិ-
យានីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា បញ្ចិ-
មានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សទ្ធិ-
ន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិ-
យំ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ឥមេសំ
ខោ ភិក្ខវេ បញ្ចន្នំ ឥន្ទ្រិយានំ សមត្តា បរិបូរត្តា

បុគ្គលទី ៨ មានតែបញ្ញា មិនមានបញ្ញិន្ទ្រិយទេឬ ។ អើ ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល មានតែបញ្ញា មិនមានបញ្ញិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៤៨] បុគ្គលទី ៨ មានតែសទ្ធា មិនមានសទ្ធិន្ទ្រិយទេ ។ បេ ។ មានតែបញ្ញា មិនមានបញ្ញិន្ទ្រិយទេឬ ។ អើ ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ។ បេ ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត មានតែបញ្ញា មិនមានបញ្ញិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៤៩] បុគ្គលទី ៨ មិនមានឥន្ទ្រិយ ៥ ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ យ៉ាង ។ ឥន្ទ្រិយ ៥ យ៉ាង តើដូចម្តេច ។ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ មាន ៥ យ៉ាង នេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបានឈ្មោះថាអរហន្ត ព្រោះមានឥន្ទ្រិយទាំង ៥ នេះឯងសម្រេចបរិបូណ៌

អរហា ហោតិ តតោ មុទុតរេហិ អរហត្តសច្ឆិកិរិយាយ បដិបន្នោ ហោតិ តតោ មុទុតរេហិ អនាគាមី ហោតិ តតោ មុទុតរេហិ អនាគាមិផលសច្ឆិកិរិយាយ បដិ-បន្នោ ហោតិ តតោ មុទុតរេហិ សកទាគាមី ហោតិ តតោ មុទុតរេហិ សកទាគាមិផលសច្ឆិកិរិយាយ ប-ដិបន្នោ ហោតិ តតោ មុទុតរេហិ សោតាបន្នោ ហោតិ តតោ មុទុតរេហិ សោតាបត្តិផលសច្ឆិកិរិយាយ បដិ-បន្នោ ហោតិ យស្ស ខោ ភិក្ខវេ ឥមានិ បញ្ចិន្ទ្រិយានិ សព្វេន សព្វំ សព្វថា សព្វំ នត្ថិ តមហំ ពាហិរោ បុថុជ្ជនបក្ខេ ឋិតោតិ វទាមីតិ អត្ថេះ សុត្តន្តោតិ ។

អដ្ឋមកឥន្ទ្រិយកថា

បុគ្គល ដែលបានឈ្មោះថាអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ព្រោះមានឥន្ទ្រិយទាំងឡាយទន់ ជាឥន្ទ្រិយរបស់បុគ្គលជាអរហន្តនោះ បុគ្គល ដែលបានឈ្មោះថាអនាគាមី ព្រោះមានឥន្ទ្រិយទាំងឡាយទន់ ជាឥន្ទ្រិយរបស់បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តនោះ បុគ្គល ដែលបានឈ្មោះថាអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ព្រោះមានឥន្ទ្រិយទាំងឡាយទន់ ជាឥន្ទ្រិយរបស់បុគ្គលជាអនាគាមីនោះ បុគ្គល ដែលបានឈ្មោះថាសកទាគាមី ព្រោះមានឥន្ទ្រិយទាំងឡាយទន់ ជាឥន្ទ្រិយរបស់បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលនោះ បុគ្គល ដែលបានឈ្មោះថា អ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ព្រោះមានឥន្ទ្រិយទាំងឡាយទន់ ជាឥន្ទ្រិយរបស់បុគ្គលជាសកទាគាមីនោះ បុគ្គល ដែលបានឈ្មោះថាសោតាបន្នៈ ព្រោះមានឥន្ទ្រិយទាំងឡាយទន់ ជាឥន្ទ្រិយរបស់អ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលនោះ បុគ្គល ដែលបានឈ្មោះថាអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ព្រោះមានឥន្ទ្រិយទាំងឡាយទន់ ជាឥន្ទ្រិយរបស់បុគ្គលជាសោតាបន្នៈនោះ ម្នាលភិក្ខុទាំងឡាយ បុគ្គលណា មិនមានឥន្ទ្រិយទាំង ៥ នេះ សព្វគ្រប់ឥតខ្ចះ ដោយប្រការទាំងពួងទេ តថាគត ហៅបុគ្គលនោះថាជាអ្នកតាំងនៅ ក្នុងពួកបុថុជ្ជន ជាខាងក្រៅ ពាក្យដូច្នេះ មានក្នុងព្រះសូត្របួ ៗ

អាមន្តា ។ អដ្ឋមកោ បុគ្គលោ ពាហិរេ បុថុជ្ជនបក្ខេ ឋិតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ចិន្ទ្រិយានីតិ ។

អដ្ឋមកស្ស ឥន្ទ្រិយកថា ។

## ទិព្វចក្ខុកថា

(៣៨០) មំសចក្ខុំ ធម្មុបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ មំសចក្ខុំ ទិព្វចក្ខុំ ទិព្វចក្ខុំ មំសចក្ខុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨១) មំសចក្ខុំ ធម្មុបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ យាទិសំ មំសចក្ខុំ តាទិសំ ទិព្វចក្ខុំ យាទិសំ ទិព្វចក្ខុំ តាទិសំ មំសចក្ខុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨២) មំសចក្ខុំ ធម្មុបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ តញ្ញេវ មំសចក្ខុំ តំ ទិព្វចក្ខុំ តំ ទិព្វចក្ខុំ តំ មំសចក្ខុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៣) មំសចក្ខុំ ធម្មុបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ យាទិសោ មំសចក្ខុស្ស វិសយោ អានុភាវោ គោចរោ តាទិសោ ទិព្វស្ស ចក្ខុស្ស វិសយោ អានុភាវោ គោចរោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អើ ។ បុគ្គលទី ៨ ឈ្មោះថាតាំងនៅ ក្នុងពួកបុថុជ្ជន ជាខាងក្រៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ បុគ្គលទី ៨ ក៏មានឥន្ទ្រិយ ៥ ដែរ ។

ចប់ អដ្ឋមកឥន្ទ្រិយកថា ។

# ទិព្វចក្ខុកថា

( ៣៩០ ) មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ មំសចក្ខុ គឺទិព្វចក្ខុ ឯទិព្វចក្ខុ គឺមំសចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៩១ ) មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ មំសចក្ខុ ដូចម្តេច ទិព្វចក្ខុ ក៏ដូច្នោះ ទិព្វចក្ខុ ដូចម្តេច មំសចក្ខុ ក៏ដូច្នោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៩២ ) មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ មំសចក្ខុនោះឯង គឺទិព្វចក្ខុនោះ ទិព្វចក្ខុនោះ គឺមំសចក្ខុនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៩៣ ) មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ មំសចក្ខុ មានវិស័យ មានអានុភាព មានគោចរ ដូចម្តេច ទិព្វចក្ខុ ក៏មានវិស័យ មានអានុភាព មានគោចរ ដូច្នោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## ទិព្វចក្ខុកថា

[៣៥៤] មំសចក្ខុំ ធម្មូបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ ឧបាទិន្នំ ហុត្វា អនុបាទិន្នំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៥៥] ឧបាទិន្នំ ហុត្វា អនុបាទិន្នំ ហោតីតិ ។ អាមន្តា ។ កាមាវចរំ ហុត្វា រូបាវចរំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៥៦] កាមាវចរំ ហុត្វា រូបាវចរំ ហោតីតិ ។ អាមន្តា ។ រូបាវចរំ ហុត្វា អរូបាវចរំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៥៧] រូបាវចរំ ហុត្វា អរូបាវចរំ ហោតីតិ ។ អាមន្តា ។ បរិយាបន្នំ ហុត្វា អបរិយាបន្នំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៥៨] មំសចក្ខុំ ធម្មូបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ ទិព្វចក្ខុំ ធម្មូបត្ថទ្ធំ មំសចក្ខុំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៥៩] មំសចក្ខុំ ធម្មូបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ ទិព្វចក្ខុំ ធម្មូបត្ថទ្ធំ បញ្ញាចក្ខុំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ទព្វចក្ខុកថា

( ៣៥៤ ) មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ ( មំសចក្ខុ ) ជាឧបាទិន្នៈ ទៅជា ( ទិព្វចក្ខុ ) អនុបាទិន្នៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៥៥ ) ឧបាទិន្នៈ ទៅជាអនុបាទិន្នៈឬ ។ អើ ។ កាមាវចរៈ ទៅជារូបាវចរៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៥៦ ) កាមាវចរៈ ទៅជារូបាវចរៈឬ ។ អើ ។ រូបាវចរៈ ទៅជាអរូបាវចរៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៥៧ ) រូបាវចរៈ ទៅជាអរូបាវចរៈឬ ។ អើ ។ បរិយាបន្នៈ ទៅជាអបរិយាបន្នៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៥៨ ) មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុ ឬ ។ អើ ។ ទិព្វចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាមំសចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៥៩ ) មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុ ឬ ។ អើ ។ ទិព្វចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាបញ្ញាចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៦០] មំសចក្ខុំ ធម្មុបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ ទិព្វចក្ខុំ ធម្មុបត្ថទ្ធំ មំសចក្ខុំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៦១] មំសចក្ខុំ ធម្មុបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ ទ្វេវ ចក្ខូនីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៦២] ទ្វេវ ចក្ខូនីតិ ។ អាមន្តា ។ ននុ តីណិ ចក្ខូនិ វុត្តានិ ភគវតា មំសចក្ខុំ ទិព្វចក្ខុំ បញ្ញាចក្ខុន្តិ ។ អាមន្តា ។ ហញ្ចិ តីណិ ចក្ខូនិ វុត្តានិ ភគវតា មំសចក្ខុំ ទិព្វចក្ខុំ បញ្ញាចក្ខុំ តេន វត រេ វត្តព្វេ ទ្វេវ ចក្ខូនីតិ ។

[៣៦៣] ទ្វេវ ចក្ខូនីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា តីណិមានិ ភិក្ខវេ ចក្ខូនិ ។ កតមានិ តីណិ ។ មំសចក្ខុំ ទិព្វចក្ខុំ បញ្ញាចក្ខុំ ឥមានិ ខោ ភិក្ខវេ តីណិ ចក្ខូនីតិ

[ ៣៦០ ] មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ ទិព្វចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាមំសចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៦១ ] មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ ចក្ខុទាំងឡាយ មានតែពីរប៉ុណ្ណោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៦២ ] ចក្ខុទាំងឡាយ មានតែពីរប៉ុណ្ណោះឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ចក្ខុទាំងឡាយ មាន ៣ គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ១ ដូច្នេះមែនឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ចក្ខុទាំងឡាយ មាន ៣ គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ១ ដូច្នេះមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុទាំង-ឡាយ មានតែពីរប៉ុណ្ណោះទេ ។

[ ៣៦៣ ] ចក្ខុទាំងឡាយ មានតែពីរប៉ុណ្ណោះឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចក្ខុទាំងឡាយ មាន ៣ ។ ចក្ខុទាំង ៣ តើដូចម្តេច ។ គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ១ ម្នាលភិក្ខុទាំងឡាយ ចក្ខុទាំងឡាយ មាន ៣ យ៉ាងនេះឯង

មំសចក្ខុំ ទិព្វចក្ខុំ បញ្ញាចក្ខុំ អនុត្តរំ
ឯតានិ តីណិ ចក្ខូនិ អក្ខាសិ បុរិសុត្តមោ
មំសចក្ខុស្ស ឧប្បាទោ មគ្គោ ទិព្វស្ស ចក្ខុនោ
យទា ច ញាណំ ឧទបាទិ បញ្ញាចក្ខុំ អនុត្តរំ
តស្ស ចក្ខុស្ស បដិលាភា សព្វទុក្ខា បមុច្ចតីតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ ទ្វេវ ចក្ខូនីតិ ។

ទិព្វចក្ខុកថា ។

## ទិព្វសោតកថា

(៣៦៤) មំសសោតំ ធម្មុបត្ថទ្ធំ ទិព្វសោតំ ហោតីតិ ។ អាមន្តា ។ មំសសោតំ ទិព្វសោតំ ទិព្វសោតំ មំសសោតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៦៥) មំសសោតំ ធម្មុបត្ថទ្ធំ ទិព្វសោតំ ហោតីតិ ។ អាមន្តា ។ យាទិសំ មំសសោតំ តាទិសំ ទិព្វសោតំ យាទិសំ ទិព្វសោតំ តាទិសំ មំសសោតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

បុរសឧត្តម បានពោលថា ចក្ខុទាំងឡាយ មាន ៣ បុណ្ណោះ គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុជាធម្មជាតដ៏ប្រសើរ ១ ការកើតឡើងនៃមំសចក្ខុ ជាផ្លូវនាំឲ្យកើតឡើងនៃទិព្វចក្ខុ កាលណាបើញាណ កើតឡើងហើយ បញ្ញា-ចក្ខុដ៏ប្រសើរ (ក៏កើតឡើង កាលណោះដែរ) បុគ្គលរួបស្រឡះចាកទុក្ខទាំងអស់ ព្រោះតែបានបញ្ញាចក្ខុនោះ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ចក្ខុទាំងឡាយ មានតែ ២ បុណ្ណោះទេ ។

ចប់ ទិព្វចក្ខុកថា ។

# ទិព្វសោតកថា

(៣៦៨) មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ មំសសោត គឺទិព្វសោត ទិព្វសោត គឺមំសសោតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៦៩) មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ មំសសោត ដូចម្តេច ទិព្វសោត ក៏ដូច្នោះដែរ ទិព្វសោត ដូចម្តេច មំសសោត ក៏ដូច្នោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៦៦ ] មំសសោតំ ធម្មុបត្ថទ្ធំ ទិព្វសោតំ ហោតីតិ ។ អាមន្តា ។ តញ្ញេវ មំសសោតំ តំ ទិព្វសោតំ តំ ទិព្វសោតំ តំ មំសសោតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៣៦៧ ] មំសសោតំ ធម្មុបត្ថទ្ធំ ទិព្វសោតំ ហោតីតិ ។ អាមន្តា ។ យាទិសោ មំសសោតស្ស វិសយោ អានុភាវោ គោចរោ តាទិសោ ទិព្វសោតស្ស វិសយោ អានុភាវោ គោចរោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៣៦៨ ] មំសសោតំ ធម្មុបត្ថទ្ធំ ទិព្វសោតំ ហោតីតិ ។ អាមន្តា ។ ឧបាទិន្នំ ហុត្វា អនុបាទិន្នំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៣៦៩ ] ឧបាទិន្នំ ហុត្វា អនុបាទិន្នំ ហោតីតិ ។ អាមន្តា ។ កាមាវចរំ ហុត្វា រូបាវចរំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៣៧០ ] កាមាវចរំ ហុត្វា រូបាវចរំ ហោតីតិ ។ អាមន្តា ។ រូបាវចរំ ហុត្វា អរូបាវចរំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៦៦] មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ មំសសោតនោះឯង គឺទិព្វសោតនោះ ទិព្វសោតនោះ គឺមំសសោតនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៦៧] មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ មំសសោត មានវិស័យ អានុភាព គោចរ ដូចម្តេច ទិព្វសោត ក៏មានវិស័យ អានុភាព គោចរ ដូច្នោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៦៨] មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ មំសសោត ជាឧបាទិន្នៈ ទៅជា (ទិព្វសោត) អនុបាទិន្នៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៦៩] (មំសសោត) ជាឧបាទិន្នៈ ទៅជា (ទិព្វសោត) អនុបាទិន្នៈឬ ។ អើ ។ កាមាវចរៈ ទៅជារូបាវចរៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៧០] កាមាវចរៈ ទៅជារូបាវចរៈឬ ។ អើ ។ រូបាវចរៈ ទៅជាអរូបាវចរៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ទិព្វសោតកថា

[៣៧១] ទូរាវចរំ ហុត្វា អទូរាវចរំ ហោតីតិ ។ អាមន្តា ។ បរិយាបន្នំ ហុត្វា អបរិយាបន្នំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៧២] មំសសោតំ ធម្មុបត្ថទ្ធំ ទិព្វសោតំ ហោតីតិ ។ អាមន្តា ។ ទិព្វសោតំ ធម្មុបត្ថទ្ធំ មំសសោតំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៧៣] មំសសោតំ ធម្មុបត្ថទ្ធំ ទិព្វសោតំ ហោតីតិ ។ អាមន្តា ។ ឯកញ្ញេវ សោតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៧៤] ឯកញ្ញេវ សោតន្តិ ។ អាមន្តា ។ ននុ ទ្វេ សោតានិ វុត្តានិ ភគវតា មំសសោតំ ទិព្វសោតន្តិ ។ អាមន្តា ។ ហញ្ចិ ទ្វេ សោតានិ វុត្តានិ ភគវតា មំសសោតំ ទិព្វសោតំ នោ ច វត រេ វត្តព្វេ ឯកញ្ញេវ សោតន្តិ ។

ទិព្វសោតកថា ។

ទិព្វសោតកថា

[ ៣៧១ ] រូបាវចរៈ ទៅជាអរូបាវចរៈឬ ។ អើ ។ បរិយាបន្នៈ ទៅជាអបរិយាបន្នៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៧២ ] មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោត ឬ ។ អើ ។ ទិព្វសោត ដែលធម៌ទំនុកបម្រុងហើយ ជាមំសសោតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៧៣ ] មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោត ឬ ។ អើ ។ សោតៈ មានតែមួយប៉ុណ្ណោះឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[ ៣៧៤ ] សោតៈ មានតែមួយប៉ុណ្ណោះឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា សោតៈទាំងឡាយ មាន ២ គឺមំស-សោត១ ទិព្វសោត១ មែនឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះ ភាគ ទ្រង់ត្រាស់ថា សោតៈទាំងឡាយ មាន ២ គឺមំសសោត ១ ទិព្វ-សោត ១ មែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សោតៈ មាន តែមួយប៉ុណ្ណោះទេ ។

ចប់ ទិព្វសោតកថា ។

# យថាកម្មូបគតញ្ញាណកថា

[៣៧៥] យថាកម្មូបគតញ្ញាណំ ទិព្វចក្ខុន្តិ ។ អាមន្តា ។ យថាកម្មូបគតញ្ច មនសិការោតិ ទិព្វេន ចក្ខុនា រូបំ បស្សតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៣៧៦] យថាកម្មូបគតញ្ច មនសិការោតិ ទិព្វេន ចក្ខុនា រូបំ បស្សតីតិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៣៧៧] យថាកម្មូបគតញ្ញាណំ ទិព្វចក្ខុន្តិ ។ អាមន្តា ។ ឥមេ វត ភោន្តោ សត្តាតិ ច មនសិការោតិ កាយទុច្ចរិតេន សមន្នាគតាតិ ច មនសិការោតិ វចីទុច្ចរិតេន សមន្នាគតាតិ ច មនសិការោតិ មនោទុច្ចរិតេន សមន្នាគតាតិ ច មនសិការោតិ អរិយានំ ឧបវាទកាតិ ច មនសិការោតិ មិច្ឆាទិដ្ឋិកាតិ ច មនសិការោតិ មិច្ឆាទិដ្ឋិកម្មសមាទានាតិ ច មនសិការោតិ តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នាតិ ច មនសិការោតិ ឥមេ វា បន ភោន្តោ សត្តាតិ ច មនសិការោតិ

# យថាកម្មូបគតញ្ញាណកថា

( ៣៧៥ ) យថាកម្មូបគតញ្ញាណ ( ការដឹងពួកសត្វ ដែលអន្ទោលទៅតាមកម្ម ) គឺទិព្វចក្ខុ ។ អើ ។ បុគ្គល ធ្វើទុកក្នុងចិត្ត ចំពោះយថាកម្មូបគតៈ ( សត្វដែលអន្ទោលទៅតាមកម្ម ) ឈ្មោះថាឃើញរូប ដោយទិព្វចក្ខុ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៧៦ ) បុគ្គល ធ្វើទុកក្នុងចិត្ត ចំពោះយថាកម្មូបគតៈ ឈ្មោះថាឃើញរូប ដោយទិព្វចក្ខុ ។ អើ ។ ការប្រជុំ នៃផស្សៈទាំង ២ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៧៧ ) យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុ ។ អើ ។ បុគ្គល ធ្វើទុកក្នុងចិត្តថា អើហ្ន៎ ពួកសត្វដ៏ចម្រើនទាំងអម្បាលនេះ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយកាយទុច្ចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយវចីទុច្ចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយមនោទុច្ចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វអ្នកតិះដៀលព្រះអរិយៈទាំងឡាយ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វជាមិច្ឆាទិដ្ឋិ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកាន់នូវអំពើជាមិច្ឆាទិដ្ឋិ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ហើយ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត និងនរក ដូច្នេះខ្លះ មួយទៀត បុគ្គល ធ្វើទុកក្នុងចិត្តថា អើហ្ន៎ ពួកសត្វដ៏ចម្រើនទាំងអម្បាលនេះ ដូច្នេះខ្លះ

កាយសុចរិតេន សមន្នាគតាតិ ច មនសិការោតិ
វចីសុចរិតេន សមន្នាគតាតិ ច មនសិការោតិ មនោ-
សុចរិតេន សមន្នាគតាតិ ច មនសិការោតិ អរិយានំ
អនុបវាទកាតិ ច មនសិការោតិ សម្មាទិដ្ឋិកាតិ ច
មនសិការោតិ សម្មាទិដ្ឋិកម្មសមាទានាតិ ច មនសិ-
ការោតិ តេ កាយស្ស ភេទា បរម្មរណា សុគតឹ
សគ្គំ លោកំ ឧបបន្នាតិ ច មនសិការោតិ ទិព្វេន
ចក្ខុនា រូបំ បស្សតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៧៨) យថាកម្មូបគញាណំ ទិព្វចក្ខុន្តិ ។
អាមន្តា ។ ឥមេ វត ភោន្តោ សត្តាតិ ច មនសិការោតិ
។បេ។ តេ កាយស្ស ភេទា បរម្មរណា សុគតឹ
សគ្គំ លោកំ ឧបបន្នាតិ ច មនសិការោតិ ទិព្វេន
ចក្ខុនា រូបំ បស្សតីតិ ។ អាមន្តា ។ ទ្វិន្នំ ផស្សា-
នំ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ
វត្តព្វេ ។បេ។

(៣៧៩) យថាកម្មូបគញាណំ ទិព្វចក្ខុន្តិ ។ អាម-
ន្តា ។ អត្ថិ កោចិ អទិព្វចក្ខុកោ ទិព្វចក្ខុំ អប្បដិលទ្ធោ
អនធិគតោ អសច្ឆិកតោ យថាកម្មូបគំ ជានាតីតិ ។

យថាកម្មូបគញ្ញាណកថា

ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយកាយសុចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយវចីសុចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយមនោសុចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វជាអ្នកមិនតិះដៀលព្រះអរិយៈទាំងឡាយ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វជាសម្មាទិដ្ឋិ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វជាអ្នកប្រកាន់នូវអំពើជាសម្មាទិដ្ឋិ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ហើយ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ដូច្នេះខ្លះ ឈ្មោះថាឃើញរូប ដោយទិព្វចក្ខុ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៧៨) យថាកម្មូបគញ្ញាណ គឺទិព្វចក្ខុ ។ អើ ។ បុគ្គលធ្វើទុកក្នុងចិត្តថា អើហ្ន៎+ ពួកសត្វដ៏ចម្រើនទាំងអម្បាលនេះ ដូច្នេះខ្លះ ។ បេ ។ ធ្វើទុកក្នុងចិត្តថា ពួកសត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ហើយ ទៅកើតក្នុងសុគតិសួគ៌ ទេវលោក ដូច្នេះខ្លះ ឈ្មោះថាឃើញរូប ដោយទិព្វចក្ខុ ។ អើ ។ ការប្រជុំ នៃផស្សៈទាំង ២ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៧៩) យថាកម្មូបគញ្ញាណ គឺទិព្វចក្ខុ ។ អើ ។ បុគ្គលណាមួយ មិនមានទិព្វចក្ខុ មិនបានចំពោះ មិនបានត្រាស់ដឹង មិនធ្វើឲ្យជាក់ច្បាស់ នូវទិព្វចក្ខុ តែងដឹង នូវយថាកម្មូបគៈ មានដែរឬ ។

អាមន្តា ។ ហញ្ចិ អត្ថិ កោចិ អទិព្វចក្ខុកោ ទិព្វចក្ខុំ អប្បដិលទ្ធោ អនធិគតោ អសច្ឆិកតោ យថាកម្មូបគតំ ជានាតិ នោ វត រេ វត្តព្វេ យថាកម្មូបគតញាណំ ទិព្វចក្ខុន្តិ ។

(៣៨០) យថាកម្មូបគតញាណំ ទិព្វចក្ខុន្តិ ។ អាមន្តា ។ អាយស្មា សារីបុត្តោ យថាកម្មូបគតំ(១) ជានាតីតិ ។ អាមន្តា ។ ហញ្ចិ អាយស្មា សារីបុត្តោ យថាកម្មូបគតំ ជានាតិ នោ វត រេ វត្តព្វេ យថាកម្មូបគតញាណំ ទិព្វចក្ខុន្តិ ។

(៣៨១) អាយស្មា សារីបុត្តោ យថាកម្មូបគតំ ជានាតីតិ ។ អាមន្តា ។ អត្ថាយស្មតោ សារីបុត្តស្ស ទិព្វចក្ខុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨២) អត្ថាយស្មតោ សារីបុត្តស្ស ទិព្វចក្ខុន្តិ ។ អាមន្តា ។ ននុ អាយស្មា សារីបុត្តោ ឯតទវោច

នេវ បុព្វេ និវាសាយ  នបិ ទិព្វស្ស ចក្ខុនោ
ចេតោបរិយាយ ឥទ្ធិយា  សោតធាតុវិសុទ្ធិយា
ចុតិយា ឧបបត្តិយា  បណិធិ មេ ន វិជ្ជតីតិ

១ ម. ឯត្ថន្តរេ ញាណន្តិ ទិស្សតិ ។ ឯវំ សព្វត្ថ ។

អើ ។ ប្រសិនបើ បុគ្គលណាមួយ មិនមានទិព្វចក្ខុ មិនបានចំពោះ មិនបានត្រាស់ដឹង មិនបានធ្វើឲ្យជាក់ច្បាស់ នូវទិព្វចក្ខុទេ តែងដឹង នូវយថាកម្មូបគតៈដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុទេ ។

(៣៨០) យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុឬ ។ អើ ។ ព្រះសារីបុត្រមានអាយុ បានជ្រាប នូវយថាកម្មូបគតៈឬ ។ អើ ។ ប្រសិនបើ ព្រះសារីបុត្រមានអាយុ បានជ្រាប នូវយថាកម្មូបគតៈដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុទេ ។

(៣៨១) ព្រះសារីបុត្រមានអាយុ បានជ្រាប នូវយថាកម្មូបគតៈឬ ។ អើ ។ ព្រះសារីបុត្រមានអាយុ មានទិព្វចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៨២) ព្រះសារីបុត្រមានអាយុ មានទិព្វចក្ខុឬ ។ អើ ។ តែក្រែងព្រះសារីបុត្រមានអាយុ បានពោលគាថានេះថា

ការតាំងចិត្ត របស់ខ្ញុំ មិនមាន ដើម្បីបុព្វេនិវាសានុស្ស-
តិញ្ញាណ មិនមាន ដើម្បីទិព្វចក្ខុ មិនមាន ដើម្បីចេតោបរិ-
យញ្ញាណ មិនមាន ដើម្បីឥទ្ធិវិធញ្ញាណ មិនមាន ដើម្បី
សោតធាតុដ៏បរិសុទ្ធ មិនមាន ដើម្បីចុតូបបាតញ្ញាណទេ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ យថាកម្មូបគតញ្ញាណំ ទិព្វចក្ខូតិ ។

យថាកម្មូបគតញ្ញាណកថា ។

# សំវរកថា

(៣៨៣) អត្ថិ ទេវេសុ សំវរោតិ ។ អាមន្តា ។ អត្ថិ ទេវេសុ អសំវរោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៤) នត្ថិ ទេវេសុ អសំវរោតិ ។ អាមន្តា ។ នត្ថិ ទេវេសុ សំវរោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៥) ននុ អសំវរា សំវរោ សីលំ អត្ថិ ទេវេសុ សំវរោតិ ។ អាមន្តា ។ អត្ថិ ទេវេសុ អសំវរោ យម្ហា អសំវរា សំវរោ សីលន្តិ ។ ន ហេវំ វត្តព្វេ ។ អាជានាហិ និគ្គហំ ហញ្ចិ អសំវរា សំវរោ សីលំ អត្ថិ ទេវេសុ សំវរោ តេន វត រេ វត្តព្វេ អត្ថិ ទេវេសុ អសំវរោ យម្ហា អសំវរា សំវរោ សីលន្តិ យំ តត្ថ វទេសិ វត្តព្វេ ខោ អសំវរា សំវរោ សីលំ អត្ថិ ទេវេសុ សំវរោ នោ ច វត្តព្វេ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុទេ ។

ចប់ យថាកម្មូបគតញ្ញាណកថា ។

# សំវរកថា

[៣៨៣] ការសង្រួម មានក្នុងពួកទេវតាឬ ។ អើ ។ ការមិនសង្រួម មានក្នុងពួកទេវតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៨៤] ការមិនសង្រួម មិនមានក្នុងពួកទេវតាទេឬ ។ អើ ។ ការសង្រួម មិនមានក្នុងពួកទេវតាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៨៥] ក្រែង ការសង្រួម ជាសីល ព្រោះការមិនសង្រួមចុះ ការសង្រួម មានក្នុងពួកទេវតាឬ ។ អើ ។ ការសង្រួម ជាសីល ព្រោះការមិនសង្រួមណា ការមិនសង្រួមនោះ មានក្នុងពួកទេវតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរជ្រាបនូវកំហុស (របស់អ្នក) ចុះ ប្រសិនបើ ការសង្រួម ជាសីល ព្រោះការមិនសង្រួម ការសង្រួម មានក្នុងពួកទេវតាមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួមណា ការមិនសង្រួមនោះ មានក្នុងពួកទេវតា ដូច្នេះ បណ្ដាពាក្យទាំង ២ ប្រការនោះ អ្នកពោលពាក្យណាថា គេគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួម ការសង្រួម មានក្នុងពួកទេវតា មិនគួរពោលថា

អត្ថិ ទេវេសុ អសំវរោ យម្ហា អសំវរា សំវរោ សីលន្តិ មិច្ឆា នោ ច បន វត្តព្វេ អត្ថិ ទេវេសុ អសំវរោ យម្ហា អសំវរា សំវរោ សីលន្តិ នោ វត វេ វត្តព្វេ អសំវរា សំវរោ សីលំ អត្ថិ ទេវេសុ សំវរោតិ យំ តត្ថ វទេសិ វត្តព្វេ ខោ អសំវរា សំវរោ សីលំ អត្ថិ ទេវេសុ សំវរោ នោ ច វត្តព្វេ អត្ថិ ទេវេសុ អសំវរោ យម្ហា អសំវរា សំវរោ សីលន្តិ មិច្ឆា ។

(៣៨៦) អត្ថិ មនុស្សេសុ សំវរោ អត្ថិ តត្ថ អសំវរោតិ ។ អាមន្តា ។ អត្ថិ ទេវេសុ សំវរោ អត្ថិ តត្ថ អសំវរោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៧) អត្ថិ ទេវេសុ សំវរោ នត្ថិ តត្ថ អសំវរោតិ ។ អាមន្តា ។ អត្ថិ មនុស្សេសុ សំវរោ នត្ថិ តត្ថ អសំវរោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ការសង្រួម ជាសីល ព្រោះការមិនសង្រួមណា ការមិនសង្រួមនោះ មានក្នុងពួកទេវតា ដូច្នេះ ពាក្យនោះ ជាពាក្យខុសទេ ប្រសិនបើ គេមិនគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួមណា ការមិនសង្រួមនោះ មានក្នុងពួកទេវតា ដូច្នេះ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួម ការសង្រួម មានក្នុងពួកទេវតា ដូច្នេះ បណ្ដាពាក្យទាំង ២ ប្រការនោះ អ្នកពោលពាក្យណាថា គេគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួម ការសង្រួម មានក្នុងពួកទេវតា មិនគួរពោលថា ការសង្រួមជាសីល ព្រោះការមិនសង្រួមណា ការមិនសង្រួមនោះ មានក្នុងពួកទេវតា ដូច្នេះ ពាក្យនោះ ជាពាក្យខុសទេ ។

(៣៨៦) ការសង្រួម មានក្នុងពួកមនុស្ស ចុះការមិនសង្រួម មាន ក្នុងពួកមនុស្សនោះដែរឬ ។ អើ ។ ការសង្រួម មានក្នុងពួកទេវតា ចុះការមិនសង្រួម មានក្នុងពួកទេវតានោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៨៧) ការសង្រួម មានក្នុងពួកទេវតា ចុះការមិនសង្រួម មិនមានក្នុងពួកទេវតានោះទេឬ ។ អើ ។ ការសង្រួម មានក្នុងពួកមនុស្ស ចុះការមិនសង្រួម មិនមានក្នុងពួកមនុស្សនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## សំវរកថា

[៣៨៨] អត្ថិ ទេវេសុ បាណាតិបាតា វេរមណីតិ ។ អាមន្តា ។ អត្ថិ ទេវេសុ បាណាតិបាតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ ទេវេសុ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីតិ ។ អាមន្តា ។ អត្ថិ ទេវេសុ សុរាមេរយមជ្ជប្បមាទដ្ឋានដ្ឋិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៨៩] នត្ថិ ទេវេសុ បាណាតិបាតោតិ ។ អាមន្តា ។ នត្ថិ ទេវេសុ បាណាតិបាតា វេរមណីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ នត្ថិ ទេវេសុ សុរាមេរយមជ្ជប្បមាទដ្ឋានដ្ឋិ ។ អាមន្តា ។ នត្ថិ ទេវេសុ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៩០] អត្ថិ មនុស្សេសុ បាណាតិបាតា វេរមណី អត្ថិ តត្ថ បាណាតិបាតោតិ ។ អាមន្តា ។ អត្ថិ ទេវេសុ បាណាតិបាតា វេរមណី អត្ថិ តត្ថ បាណាតិបាតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ មនុស្សេសុ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី អត្ថិ តត្ថ សុរាមេរយមជ្ជប្បមាទដ្ឋានដ្ឋិ ។ អាមន្តា ។

## សំវរកថា

(៣៨៨) ការវៀរចាកបាណាតិបាត មាន ក្នុងពួកទេវតាឬ ៗ អើ ៗ ចុះបាណាតិបាត (ការសម្លាប់សត្វ) មាន ក្នុងពួកទេវតាឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការវៀរចាកសុរាមេរយមជ្ជប្ប-មាទដ្ឋានៈ (ហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺការផឹកទឹកស្រវឹងគឺសុរានិងមេរ័យ) មាន ក្នុងពួកទេវតាឬ ៗ អើ ៗ សុរាមេរយមជ្ជប្បមាទដ្ឋានៈ (ហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺការផឹកទឹកស្រវឹងគឺសុរានិងមេរ័យ) មាន ក្នុងពួកទេវតាឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣៨៩) បាណាតិបាត មិនមាន ក្នុងពួកទេវតាទេឬ ៗ អើ ៗ ការវៀរចាកបាណាតិបាត មិនមាន ក្នុងពួកទេវតាទេឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សុរាមេរយមជ្ជប្បមាទដ្ឋានៈ មិនមាន ក្នុងពួកទេវតាទេឬ ៗ អើ ៗ ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋានៈ មិនមាន ក្នុងពួកទេវតាទេឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣៩០) ការវៀរចាកបាណាតិបាត មាន ក្នុងពួកមនុស្ស ចុះបាណាតិបាត មាន ក្នុងពួកមនុស្សនោះឬ ៗ អើ ៗ ការវៀរចាកបាណាតិបាត មាន ក្នុងពួកទេវតា ចុះបាណាតិបាត មាន ក្នុងពួកទេវតានោះឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋានៈ មាន ក្នុងពួកមនុស្ស ចុះសុរាមេ-រយមជ្ជប្បមាទដ្ឋានៈ មាន ក្នុងពួកមនុស្សនោះឬ ៗ អើ ៗ

អត្ថិ ទេវេសុ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី អត្ថិ តត្ថ សុរាមេរយមជ្ជប្បមាទដ្ឋានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៩១) អត្ថិ ទេវេសុ បាណាតិបាតា វេរមណី នត្ថិ តត្ថ បាណាតិបាតោតិ ។ អាមន្តា ។ អត្ថិ មនុស្សេសុ បាណាតិបាតា វេរមណី នត្ថិ តត្ថ បាណាតិបាតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ ទេវេសុ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី នត្ថិ តត្ថ សុរាមេរយមជ្ជប្បមាទដ្ឋានន្តិ ។ អាមន្តា ។ អត្ថិ មនុស្សេសុ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី នត្ថិ តត្ថ សុរាមេរយមជ្ជប្បមាទដ្ឋានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៩២) នត្ថិ ទេវេសុ សំវរោតិ ។ អាមន្តា ។ សព្វេ ទេវា បាណាតិបាតិនោ អទិន្នាទាយិនោ

ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋានៈ មាន ក្នុងពួកទេវតា ចុះសុរាមេរយមជ្ជប្បមាទដ្ឋានៈ មាន ក្នុងពួកទេវតានោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣៩១) ការវៀរចាកបាណាតិបាត មាន ក្នុងពួកទេវតា ចុះបាណាតិបាត មិនមាន ក្នុងពួកទេវតានោះទេឬ ។ អើ ។ ការវៀរចាកបាណាតិបាត មាន ក្នុងពួកមនុស្ស ចុះបាណាតិបាត មិនមាន ក្នុងពួកមនុស្សនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋានៈ មាន ក្នុងពួកទេវតា ចុះសុរាមេរយមជ្ជប្បមាទដ្ឋានៈ មិនមាន ក្នុងពួកទេវតានោះទេឬ ។ អើ ។ ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋានៈ មាន ក្នុងពួកមនុស្ស ចុះសុរាមេរយមជ្ជប្បមាទដ្ឋានៈ មិនមាន ក្នុងពួកមនុស្សនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣៩២) ការសង្រួម មិនមាន ក្នុងពួកទេវតាទេឬ ។ អើ ។ ពួកទេវតាទាំងអស់ ជាអ្នកសម្លាប់សត្វ ជាអ្នកកាន់យកទ្រព្យដែលម្ចាស់គេមិនឲ្យ

កាមេសុមិច្ឆាចារិនោ មុសាវាទិនោ សុរាមេរយមជ្ជប្ប-
មាទដ្ឋាយិនោតិ ។ ន ហេវំ វត្តព្វេ ។បេ។ តេន
ហិ អត្ថិ ទេវេសុ សំវរោតិ ។

សំវរកថា ។

## អសញ្ញកថា

(៣៩៣) អសញ្ញសត្តេសុ សញ្ញា អត្ថីតិ ។ អា-
មន្តា ។ សញ្ញាភវោ សញ្ញាគតិ សញ្ញាសត្តាវាសោ
សញ្ញាសំសារោ សញ្ញាយោនិ សញ្ញត្តភាវប្បដិលាភោ-
តិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៩៤) ននុ អសញ្ញាភវោ អសញ្ញាគតិ អសញ្ញា-
សត្តាវាសោ អសញ្ញាសំសារោ អសញ្ញាយោនិ អសញ្ញ-
ត្តភាវប្បដិលាភោតិ ។ អាមន្តា ។ ហញ្ចិ អសញ្ញា-
ភវោ អសញ្ញាគតិ អសញ្ញាសត្តាវាសោ អសញ្ញាសំ-
សារោ អសញ្ញាយោនិ អសញ្ញត្តភាវប្បដិលាភោ នោ
វត រេ វត្តព្វេ អសញ្ញសត្តេសុ សញ្ញា អត្ថីតិ ។

ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាអ្នកពោលពាក្យកុហក ជាអ្នកប្រព្រឹត្តនូវហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកទឹកស្រវឹងគឺសុរានិងមេរ័យដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ ការសង្រួម មាន ក្នុងពួកទេវតាដែរ ។

ចប់ សំវរកថា ។

# អសញ្ញកថា

(៣៩៣) សញ្ញា ក្នុងពួកអសញ្ញសត្វ (សត្វមិនមានសញ្ញា) មានដែរឬ ។ អើ ។ ភពរបស់សញ្ញសត្វ (សត្វមានសញ្ញា) គតិរបស់សញ្ញសត្វ លំនៅរបស់សញ្ញសត្វ សំសាររបស់សញ្ញសត្វ កំណើតរបស់សញ្ញសត្វ ការបានចំពោះនូវអត្តភាពរបស់សញ្ញសត្វ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៩៤) ក្រែង ភពរបស់អសញ្ញសត្វ គតិរបស់អសញ្ញសត្វ លំនៅរបស់អសញ្ញសត្វ សំសាររបស់អសញ្ញសត្វ កំណើតរបស់អសញ្ញ-សត្វ ការបានចំពោះនូវអត្តភាពរបស់អសញ្ញសត្វ មានដែរឬ ។ អើ ។ ប្រសិនបើ ភពរបស់អសញ្ញសត្វ គតិរបស់អសញ្ញសត្វ លំនៅរបស់អសញ្ញសត្វ សំសាររបស់អសញ្ញសត្វ កំណើតរបស់អសញ្ញសត្វ ការបានចំពោះនូវអត្តភាពរបស់អសញ្ញសត្វ មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញា ក្នុងពួកអសញ្ញសត្វ មានទេ ។

(៣៩៥) អសញ្ញសត្តេសុ សញ្ញា អត្ថីតិ ។ អាមន្តា ។ បញ្ចវោការភវោ គតិ សត្តាវាសោ សំសារោ យោនិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៩៦) ននុ ឯកវោការភវោ គតិ សត្តាវាសោ សំសារោ យោនិ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ ហញ្ចិ ឯកវោការភវោ គតិ សត្តាវាសោ សំសារោ យោនិ អត្តភាវប្បដិលាភោ នោ វត រេ វត្តព្វេ អសញ្ញសត្តេសុ សញ្ញា អត្ថីតិ ។

(៣៩៧) អសញ្ញសត្តេសុ សញ្ញា អត្ថីតិ ។ អាមន្តា ។ តាយ សញ្ញាយ សញ្ញាករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៩៨) មនុស្សេសុ សញ្ញា អត្ថិ សោ ច សញ្ញភវោ សញ្ញគតិ សញ្ញសត្តាវាសោ សញ្ញសំសារោ សញ្ញយោនិ សញ្ញត្តភាវប្បដិលាភោតិ ។ អាមន្តា ។ អសញ្ញសត្តេសុ សញ្ញា អត្ថិ សោ ច សញ្ញភវោ សញ្ញគតិ សញ្ញសត្តាវាសោ សញ្ញសំសារោ សញ្ញយោនិ សញ្ញត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៩៥) សញ្ញា ក្នុងពួកអសញ្ញសត្វ មានដែរឬ ។ អើ ។ បញ្ចវោការភព គតិ សត្តាវាសៈ សំសារ កំណើត ការបានអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៩៦) ក្រែង ឯកវោការភព គតិ សត្តាវាសៈ សំសារ កំណើត ការបានអត្តភាព មានដែរឬ ។ អើ ។ ប្រសិនបើ ឯកវោ-ការភព គតិ សត្តាវាសៈ សំសារ កំណើត ការបានអត្តភាព មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញា ក្នុងពួកអសញ្ញ-សត្វ មានទេ ។

(៣៩៧) សញ្ញា ក្នុងពួកអសញ្ញសត្វ មានដែរឬ ។ អើ ។ បុគ្គលធ្វើកិច្ចគួរធ្វើដោយសញ្ញា ដោយសញ្ញានោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៩៨) សញ្ញា ក្នុងពួកមនុស្ស មាន ទាំងសញ្ញភពនោះ សញ្ញគតិ (គតិរបស់សត្វមានសញ្ញា) សញ្ញសត្តាវាសៈ សញ្ញសំសារ សញ្ញយោនិ សញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អើ ។ សញ្ញា ក្នុងពួកអសញ្ញសត្វ មាន ទាំងសញ្ញភពនោះ សញ្ញគតិ សញ្ញសត្តាវាសៈ សញ្ញសំសារ សញ្ញយោនិ សញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## អសញ្ញកថា

[ ៣៩៩ ] មនុស្សេសុ សញ្ញា អត្ថិ សោ ច បញ្ចវោការភវោ គតិ សត្តាវាសោ សំសារោ យោនិ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ អសញ្ញសត្តេសុ សញ្ញា អត្ថិ សោ ច បញ្ចវោការភវោ គតិ សត្តាវាសោ សំសារោ យោនិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៤០០ ] មនុស្សេសុ សញ្ញា អត្ថិ តាយ សញ្ញាយ សញ្ញាករណីយំ ករោតីតិ ។ អាមន្តា ។ អសញ្ញសត្តេសុ សញ្ញា អត្ថិ តាយ សញ្ញាយ សញ្ញាករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៤០១ ] អសញ្ញសត្តេសុ សញ្ញា អត្ថិ សោ ច អសញ្ញភវោ អសញ្ញគតិ អសញ្ញសត្តាវាសោ អសញ្ញសំសារោ អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភោតិ ។ អាមន្តា ។ មនុស្សេសុ សញ្ញា អត្ថិ សោ ច អសញ្ញភវោ ។ បេ ។ អសញ្ញត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

## អសញ្ញកថា

[៣៩៩] សញ្ញា ក្នុងពួកមនុស្ស មាន ទាំងបញ្ចវោការភពនោះ គតិ សត្តាវាសៈ សំសារ យោនិ អត្តភាវប្បដិលាភ មានដែរឬ ។ អើ ។ សញ្ញា ក្នុងពួកអសញ្ញសត្វ មាន ទាំងបញ្ចវោការភពនោះ គតិ លំនៅរបស់សត្វ សំសារ កំណើត ការបានអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤០០] សញ្ញា ក្នុងពួកមនុស្ស មាន ទាំងបុគ្គលធ្វើកិច្ចដែលគួរធ្វើដោយសញ្ញា ដោយសញ្ញានោះដែរឬ ។ អើ ។ សញ្ញា ក្នុងពួកអសញ្ញសត្វ មាន ទាំងបុគ្គលធ្វើកិច្ចដែលគួរធ្វើដោយសញ្ញា ដោយសញ្ញានោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤០១] សញ្ញា ក្នុងពួកអសញ្ញសត្វ មាន ទាំងអសញ្ញភពនោះ អសញ្ញគតិ អសញ្ញសត្តាវាសៈ អសញ្ញសំសារ អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អើ ។ សញ្ញា ក្នុងពួកមនុស្ស មាន ទាំងអសញ្ញភពនោះ ។ បេ ។ អសញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤០២] អសញ្ញសត្តេសុ សញ្ញា អត្ថិ សោ ច ឯកវោការភវោ គតិ សត្តាវាសោ សំសារោ យោនិ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ មនុស្សេសុ សញ្ញា អត្ថិ សោ ច ឯកវោការភវោ ។បេ។ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៤០៣] អសញ្ញសត្តេសុ សញ្ញា អត្ថិ ន ច តាយ សញ្ញាយ សញ្ញាករណីយំ ករោតីតិ ។ អាមន្តា ។ មនុស្សេសុ សញ្ញា អត្ថិ ន ច តាយ សញ្ញាយ សញ្ញាករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៤០៤] ន វត្តព្វំ អសញ្ញសត្តេសុ សញ្ញា អត្ថីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សន្តិ ភិក្ខវេ អសញ្ញសត្តា នាម ទេវា សញ្ញុប្បាទា ច បន តេ ទេវា តម្ហា កាយា ចវន្តីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អសញ្ញសត្តេសុ សញ្ញា អត្ថីតិ ។

[៤០៥] អសញ្ញសត្តេសុ សញ្ញា អត្ថីតិ ។ កាញ្ចិ(១) កាលេ អត្ថិ កាញ្ចិ កាលេ នត្ថីតិ ។ កាញ្ចិ កាលេ សញ្ញសត្តា កាញ្ចិ កាលេ អសញ្ញសត្តា

---

១ ម. កិញ្ចិ ។ ឯវំ សព្វត្ថ ។

(៤០២) សញ្ញា ក្នុងពួកអសញ្ញសត្វ មាន ទាំងឯកវោការភព នោះ គតិ លំនៅរបស់សត្វ សំសារ កំណើត ការបានអត្តភាព មាន ដែរឬ ។ អើ ។ សញ្ញា ក្នុងពួកមនុស្ស មាន ទាំងឯកវោការភពនោះ ។បេ។ ការបានអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។បេ។

(៤០៣) សញ្ញា ក្នុងពួកអសញ្ញសត្វ មាន ប៉ុន្តែអសញ្ញសត្វ នោះ មិនធ្វើកិច្ចដែលគួរធ្វើដោយសញ្ញា ដោយសញ្ញានោះទេឬ ។ អើ ។ សញ្ញា ក្នុងពួកមនុស្ស មាន ប៉ុន្តែមនុស្សនោះ មិនធ្វើកិច្ចដែលគួរធ្វើដោយ សញ្ញា ដោយសញ្ញានោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤០៤) បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងពួកអសញ្ញសត្វ មាន ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ពួកទេវតា ឈ្មោះថា អសញ្ញសត្វ ជាអ្នកញុំាងសញ្ញាឲ្យកើត ឡើង មាន ប៉ុន្តែ ទេវតាទាំងនោះ រមែងច្យុតចាកកាយនោះ ពាក្យ ដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សញ្ញា ក្នុង ពួកអសញ្ញសត្វ មានមែន ។

(៤០៥) សញ្ញា ក្នុងពួកអសញ្ញសត្វ មានដែរឬ ។ សញ្ញា ក្នុងកាលខ្លះ មាន ក្នុងកាលខ្លះ មិនមាន ។ ចុះពួក សញ្ញសត្វ ក្នុងកាលខ្លះ មាន ពួកអសញ្ញសត្វ ក្នុងកាលខ្លះ មាន

កស្មិំ ខណេ សញ្ញាភវោ កស្មិំ ខណេ អសញ្ញាភវោ កស្មិំ ខណេ បញ្ចវោការភវោ កស្មិំ ខណេ ឯកវោការភវោតិ ។ ន ហេវំ វត្តព្វេ ។បេ ។

(៤០៦) អសញ្ញសត្តេសុ សញ្ញា កស្មិំ ខណេ អត្ថិ កស្មិំ ខណេ នត្ថីតិ ។ អាមន្តា ។ កំ កាលំ អត្ថិ កំ កាលំ នត្ថីតិ ។ ចុតិកាលេ ឧបបត្តិកាលេ អត្ថិ ឋិតិកាលេ នត្ថីតិ ។ ចុតិកាលេ ច ឧបបត្តិកាលេ សញ្ញសត្តា ឋិតិកាលេ អសញ្ញសត្តា ចុតិកាលេ ឧបបត្តិកាលេ សញ្ញាភវោ ឋិតិកាលេ អសញ្ញាភវោ ចុតិកាលេ ឧបបត្តិកាលេ បញ្ចវោការភវោ ឋិតិកាលេ ឯកវោការភវោតិ ។ ន ហេវំ វត្តព្វេ ។បេ ។

អសញ្ញកថា ។

## នេវសញ្ញានាសញ្ញាយតនកថា

(៤០៧) នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។ អាមន្តា ។ អសញ្ញាភវោ អសញ្ញាគតិ អសញ្ញសត្តាវាសោ អសញ្ញាសំសារោ អសញ្ញាយោនិ អសញ្ញត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។បេ ។

សញ្ញាភព ក្នុងកាលខ្លះ មាន អសញ្ញាភព ក្នុងកាលខ្លះ មាន បញ្ចវោការភព ក្នុងកាលខ្លះ មាន ឯកវោការភព ក្នុងកាលខ្លះ មាន ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤០៦) សញ្ញា ក្នុងពួកអសញ្ញសត្វ ក្នុងកាលខ្លះ មាន ក្នុងកាលខ្លះ មិនមាន ឬ ។ អើ ។ កាលដូចម្តេច សញ្ញា មាន កាលដូចម្តេច សញ្ញា មិនមាន ។ សញ្ញា ក្នុងចុតិកាល ( កាលច្យុត) និងឧបបត្តិកាល (កាលដែលកើត) មាន តែក្នុងឋិតិកាល (កាលដែលតាំងនៅ) មិនមានទេ ។ ពួកសញ្ញសត្វ ក្នុងចុតិកាលនិងឧបបត្តិកាល មាន ពួកអសញ្ញសត្វ ក្នុងឋិតិកាល មាន សញ្ញាភព ក្នុងចុតិកាល និងឧបបត្តិកាល មាន អសញ្ញាភព ក្នុងឋិតិកាល មាន បញ្ចវោការភព ក្នុងចុតិកាល និងឧបបត្តិកាល មាន ឯកវោការភព ក្នុងឋិតិកាល មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ អសញ្ញកថា ។

## នេវសញ្ញានាសញ្ញាយតនកថា

(៤០៧) បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេឬ ។ អើ ។ អសញ្ញាភព អសញ្ញាគតិ អសញ្ញសត្តាវាសៈ អសញ្ញាសំសារ អសញ្ញាយោនិ អសញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ២០៨ ] ននុ សញ្ញាភវោ សញ្ញាគតិ សញ្ញាសត្តាវាសោ សញ្ញាសំសារោ សញ្ញាយោនិ សញ្ញត្តភាវប្បដិលាភោតិ ។ អាមន្តា ។ ហញ្ចិ សញ្ញាភវោ សញ្ញាគតិ ។ បេ ។ សញ្ញត្តភាវប្បដិលាភោតិ នោ វត រេ វត្តព្វេ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។

[ ២០៩ ] នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។ អាមន្តា ។ ឯកវោការភវោ គតិ ។ បេ ។ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ចតុវោការភវោ គតិ ។ បេ ។ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ ហញ្ចិ ចតុវោការភវោ គតិ ។ បេ ។ អត្តភាវប្បដិលាភោ នោ វត រេ វត្តព្វេ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។

[ ២១០ ] អសញ្ញសត្តេសុ ន វត្តព្វំ សញ្ញា អត្ថិ សោ ច អសញ្ញាភវោ អសញ្ញាគតិ អសញ្ញសត្តាវាសោ អសញ្ញាសំសារោ អសញ្ញាយោនិ អសញ្ញត្តភាវប្បដិលាភោតិ ។ អាមន្តា ។

[៤០៨] ក្រែង សញ្ញាភព សញ្ញាគតិ សញ្ញាសត្តាវាសៈ សញ្ញាសំសារ សញ្ញាយោនិ សញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អើ ។ ប្រសិនបើ សញ្ញាភព សញ្ញាគតិ ។ បេ ។ សញ្ញត្តភាវប្បដិលាភ មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ។

[៤០៩] បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេឬ ។ អើ ។ ឯកវោការភព គតិ ។ បេ ។ ការបានអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែង ចតុវោការភព គតិ ។ បេ ។ ការបានអត្តភាព មានដែរឬ ។ អើ ។ ប្រសិនបើ ចតុវោការភព គតិ ។ បេ ។ ការបានអត្តភាព មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ។

[៤១០] បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងពួកអសញ្ញាសត្វ មានទេ ចុះចំណែកខាង អសញ្ញាភពនោះ អសញ្ញាគតិ អសញ្ញាសត្តាវាសៈ អសញ្ញាសំសារ អសញ្ញាយោនិ អសញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អើ ។

## នេវសញ្ញានាសញ្ញាយតនកថា

នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថិ សោ ច អសញ្ញភវោ អសញ្ញគតិ អសញ្ញសត្តាវាសោ អសញ្ញសំសារោ អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អសញ្ញសត្តេសុ ន វត្តព្វំ សញ្ញា អត្ថិ សោ ច ឯកវោការភវោ គតិ ។ បេ ។ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថិ សោ ច ឯកវោការភវោ គតិ សត្តាវាសោ សំសារោ យោនិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦១១) នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថិ សោ ច សញ្ញភវោ សញ្ញគតិ ។ បេ ។ សញ្ញត្តភាវប្បដិលាភោតិ ។ អាមន្តា ។ អសញ្ញសត្តេសុ ន វត្តព្វំ សញ្ញា អត្ថិ សោ ច សញ្ញភវោ សញ្ញគតិ ។ បេ ។ សញ្ញត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦១២) នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថិ សោ ច ចតុវោការភវោ គតិ ។ បេ ។

## នេវសញ្ញានាសញ្ញាយតនកថា

បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ចុះចំណែកខាង អសញ្ញភពនោះ អសញ្ញគតិ អសញ្ញសត្តាវាសៈ អសញ្ញសំសារ អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មិនគួរនិយាយថា សញ្ញា ក្នុងពួកអសញ្ញសត្វ មានទេ ចុះចំណែកខាង ឯកវោការភពនោះ គតិ ។ បេ ។ ការបានអត្តភាព មានដែរឬ ។ អើ ។ មិនគួរនិយាយថា សញ្ញា ក្នុងេវសញ្ញានាសញ្ញាយតនភព មានទេ ចុះចំណែកខាង ឯកវោការភពនោះ គតិ លំនៅរបស់សត្វ សំសារ កំណើត ការបានអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤១១) បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ចុះចំណែកខាង សញ្ញភពនោះ សញ្ញគតិ ។ បេ ។ សញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អើ ។ មិនគួរនិយាយថា សញ្ញា ក្នុងពួកអសញ្ញសត្វ មានទេ ចុះចំណែកខាង សញ្ញភពនោះ សញ្ញគតិ ។ បេ ។ សញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤១២) បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ចុះចំណែកខាង ចតុវោការភពនោះ គតិ ។ បេ ។

អត្ថការប្បដិលាភោតិ ។ អាមន្តា ។ អសញ្ញសត្តេសុ ន វត្តព្វំ សញ្ញា អត្ថិ សោ ច ចតុវោការភវោ ។ បេ ។ អត្ថការប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤១៣] នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។ អាមន្តា ។ ននុ នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវោតិ ។ អាមន្តា ។ ហញ្ចិ នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវោ តេន វត រេ វត្តព្វេ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។

[៤១៤] នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវោ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។ អាមន្តា ។ អាកាសានញ្ចាយតនំ ចតុវោការភវោ អាកាសានញ្ចាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤១៥] នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវោ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។

ការបានអត្តភាព មានដែរឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងពួកអសញ្ញសត្វ មានទេ ចុះចំណែកខាង ចតុវោការភព នោះ ។បេ។ ការបានអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤១៣) បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេឬ ។ អើ ។ ក្រែងនេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភពឬ ។ អើ ។ ប្រសិនបើ នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភពមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ។

(៤១៤) នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេឬ ។ អើ ។ អាកាសានញ្ចាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងអាកាសានញ្ចាយតនភព មានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤១៥) នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេឬ ។

## នេវសញ្ញានាសញ្ញាយតនកថា

អាមន្តា ។ វិញ្ញាណញ្ចាយតនំ ។បេ។ អាកិញ្ចញ្ញា-
យតនំ ចតុវោការភវោ អាកិញ្ចញ្ញាយតនេ ន វត្តព្វំ
សញ្ញា អត្ថីតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៨១៦] អាកាសានញ្ចាយតនំ ចតុវោការភវោ
អត្ថិ តត្ថ សញ្ញាតិ ។ អាមន្តា ។ នេវសញ្ញានា-
សញ្ញាយតនំ ចតុវោការភវោ អត្ថិ តត្ថ សញ្ញាតិ ។
ន ហេវំ វត្តព្វេ ។បេ។ វិញ្ញាណញ្ចាយតនំ ។បេ។
អាកិញ្ចញ្ញាយតនំ ចតុវោការភវោ អត្ថិ តត្ថ សញ្ញា-
តិ ។ អាមន្តា ។ នេវសញ្ញានាសញ្ញាយតនំ ចតុវោការ
ភវោ អត្ថិ តត្ថ សញ្ញាតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៨១៧] នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ
សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។ អាមន្តា ។ ននុ នេ-
វសញ្ញានាសញ្ញាយតនំ ចតុវោការភវោតិ ។ អាមន្តា ។
ហញ្ចិ នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវោ តេន
វត រេ វត្តព្វេ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ
សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។

អើ ។ វិញ្ញាណញ្ចាយតនភព ។ បេ ។ អាកិញ្ចញ្ញាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងអាកិញ្ចញ្ញាយតនភព មានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤១៦ ) អាកាសានញ្ចាយតនភព ជាចតុវោការភព សញ្ញា ក្នុងអាកាសានញ្ចាយតនភពនោះ មានដែរឬ ។ អើ ។ នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភពនោះ មានដែរឬ ។ អ្នកមិ គួរពោលយ៉ាងនេះទេ ។ បេ ។ វិញ្ញាណញ្ចាយតនភព ។ បេ ។ អាកិញ្ចញ្ញាយតនភព ជាចតុវោការភព សញ្ញា ក្នុងអាកិញ្ចញ្ញាយតនភពនោះ មានដែរឬ ។ អើ ។ នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភពនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤១៧ ) បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានឬមិនមានទេឬ ។ អើ ។ ក្រែង នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភពឬ ។ អើ ។ ប្រសិនបើ នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភពមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានឬមិនមានទេ ។

[ ៦១៨ ] នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវេ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។ អាមន្តា ។ អាកាសានញ្ចាយតនំ ។ បេ ។ វិញ្ញាណញ្ចាយតនំ ។ បេ ។ អាកិញ្ចញ្ញាយតនំ ចតុវោការភវេ អាកិញ្ចញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៦១៩ ] អាកាសានញ្ចាយតនំ ចតុវោការភវេ អត្ថិ តត្ថ សញ្ញាតិ ។ អាមន្តា ។ នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវេ អត្ថិ តត្ថ សញ្ញាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វិញ្ញាណញ្ចាយតនំ ។ បេ ។ អាកិញ្ចញ្ញាយតនំ ចតុវោការភវេ អត្ថិ តត្ថ សញ្ញាតិ ។ អាមន្តា ។ នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវេ អត្ថិ តត្ថ សញ្ញាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤១៨) នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញា ក៏នេវសញ្ញានាសញ្ញាយតនភព មានឬមិនមានទេឬ ។ អើ ។ អាកាសានញ្ចាយតនភព ។ បេ ។ វិញ្ញាណញ្ចាយតនភព ។ បេ ។ អាកិញ្ចញ្ញាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញា ក៏អាកិញ្ចញ្ញាយតនភព មានឬមិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤១៩) អាកាសានញ្ចាយតនភព ជាចតុវោការភព សញ្ញា ក៏អាកាសានញ្ចាយតនភពនោះ មានដែរឬ ។ អើ ។ នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព សញ្ញា ក៏នេវសញ្ញានាសញ្ញាយតនភពនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិញ្ញាណញ្ចាយតនភព ។ បេ ។ អាកិញ្ចញ្ញាយតនភព ជាចតុវោការភព សញ្ញា ក៏អាកិញ្ចញ្ញាយតនភពនោះ មានដែរឬ ។ អើ ។ នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព សញ្ញា ក៏នេវសញ្ញានាសញ្ញាយតនភពនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## នេវសញ្ញានាសញ្ញាយតនកថា

[៦២០] នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។ អាមន្តា ។ ននុ នេវសញ្ញានាសញ្ញាយតនន្តិ ។ អាមន្តា ។ ហញ្ចិ នេវសញ្ញានាសញ្ញាយតនំ តេន វត រេ វត្តព្វេ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។

[៦២១] នេវសញ្ញានាសញ្ញាយតនន្តិ កត្វា នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។ អាមន្តា ។ អទុក្ខមសុខា វេទនាតិ កត្វា អទុក្ខមសុខាយ វេទនាយ ន វត្តព្វំ វេទនាតិ វា អវេទនាតិ វាតិ ។ ន ហេវំ វត្តព្វេ ។បេ។

នេវសញ្ញានាសញ្ញាយតនកថា ។

តតិយោ វគ្គោ ។

## នេវសញ្ញានាសញ្ញាយតនកថា

[៤៦០] បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានឬមិនមានទេឬ ។ អើ ។ ក្រែង នេវសញ្ញានាសញ្ញាយតនភព មានឬ ។ អើ ។ ប្រសិនបើ នេវសញ្ញានាសញ្ញាយតនភព មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានឬមិនមានទេ ។

[៤៦១] បុគ្គលធ្វើសេចក្តីចូលចិត្តថា នេវសញ្ញានាសញ្ញាយតនភព ដូច្នេះហើយ មិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានឬមិនមានទេឬ ។ អើ ។ បុគ្គលធ្វើសេចក្តីចូលចិត្តថា អទុក្ខមសុខវេទនា ដូច្នេះហើយ មិនគួរនិយាយថា វេទនា ឬមិនមែនវេទនា ក្នុងអទុក្ខមសុខវេទនាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ នេវសញ្ញានាសញ្ញាយតនកថា ។

ចប់ តតិយវគ្គ ។

## តស្ស ឧទ្ទានំ

ពលំ សាធារណំ អរិយំ សភាគំ ចិត្តំ វិមុច្ចតិ
វិមុត្តំ វិមុច្ចមានំ អត្ថិ ចិត្តំ វិមុច្ចមានំ
អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនំ
អដ្ឋមកស្ស បុគ្គលស្ស នត្ថិ បញ្ចិន្ទ្រិយានិ ចក្ខុំ
សោតំ ធម្មុបត្ថទ្ធំ យថាកម្មុបគតញ្ញាណំ ទេវេសុ
សំវរោ អសញ្ញសត្តេសុ សញ្ញា ឯវមេវ ភវគ្គន្តិ ។

---

## គិហិស្ស អរហាតិកថា

(៥២២) គិហិស្ស អរហាតិ ។ អាមន្តា ។ អត្ថិ អរហតោ គិហិសញ្ញោជនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ នត្ថិ អរហតោ គិហិសញ្ញោជនន្តិ ។ អាមន្តា ។ ហញ្ចិ នត្ថិ អរហតោ គិហិសញ្ញោជនំ នោ វត រេ វត្តព្វេ គិហិស្ស អរហាតិ ។

(៥២៣) គិហិស្ស អរហាតិ ។ អាមន្តា ។ ននុ អរហតោ គិហិសញ្ញោជនំ បហីនំ ឧច្ឆិន្នមូលំ

## ឧទ្ទាននៃតតិយវគ្គនោះ គឺ

និយាយ អំពីកម្លាំងព្រះតថាគត សាធារណៈដល់សាវ័ក ១ កម្លាំងព្រះតថាគត ជាអរិយៈ ១ ចិត្ត ប្រកបដោយរាគៈ រួចស្រឡះ ១ ចិត្ត រួចស្រឡះហើយ កំពុងរួចស្រឡះ និងចិត្តកំពុងរួចស្រឡះ ១ បុគ្គលទី ៨ លះបង់ទិដ្ឋិបរិយុដ្ឋានៈ ១ បុគ្គលទី ៨ មិនមានឥន្ទ្រិយ ៥ យ៉ាង ១ មំសចក្ខុ ដែលធម៌ទំនុកបម្រុង ១ មំសសោតដែលធម៌ទំនុកបម្រុង ១ យថាកម្មូបគតញ្ញាណ ១ ការសង្រួម ក្នុងពួកទេវតា ១ សញ្ញា ក្នុងពួកអសញ្ញសត្វ ១ ក្នុងនេវសញ្ញានាសញ្ញាយតនភព ១ ៗ

---

## គិហិអរហាតិកថា

(៤២២) គ្រហស្ថ បានជាព្រះអរហន្តដែរឬ ៗ អើ ៗ សញ្ញោជនៈនៃគ្រហស្ថ របស់ព្រះអរហន្ត មានដែរឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បើ ៗ សញ្ញោជនៈនៃគ្រហស្ថ របស់ព្រះអរហន្ត មិនមានទេឬ ៗ អើ ៗ បើសញ្ញោជនៈនៃគ្រហស្ថ របស់ព្រះអរហន្ត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តទេ ៗ

(៤២៣) គ្រហស្ថ បានជាព្រះអរហន្តដែរឬ ៗ អើ ៗ ក្រែងសញ្ញោជនៈនៃគ្រហស្ថ ព្រះអរហន្ត បានលះបង់ហើយ មានឫសគល់

តាលាវត្ថុកតំ អនភាវង្កតំ អាយតឹអនុប្បាទធម្មន្តិ ។ អាមន្តា ។ ហញ្ចិ អរហតោ គិហិសញ្ញោជនំ បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹអនុប្បា-ទធម្មំ នោ វត រេ វត្តព្វេ គិហិស្ស អរហាតិ ។

(៦២៦) គិហិស្ស អរហាតិ ។ អាមន្តា ។ អត្ថិ កោចិ គិហី គិហិសញ្ញោជនំ អប្បហាយ ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោតិ ។ នត្ថិ ។ ហញ្ចិ នត្ថិ កោចិ គិហី គិហិសញ្ញោជនំ អប្បហាយ ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ នោ វត រេ វត្តព្វេ គិហិស្ស អរហាតិ ។

(៦២៧) គិហិស្ស អរហាតិ ។ អាមន្តា ។ ននុ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច អត្ថិ នុ ខោ ភោ គោតម កោចិ គិហី គិហិសញ្ញោជនំ អប្បហាយ កាយស្ស ភេទា ទុក្ខស្សន្តករោតិ នត្ថិ ខោ វច្ឆ កោចិ គិហី គិហិសញ្ញោជនំ អប្បហាយ កាយស្ស ភេទា ទុក្ខស្សន្តករោតិ អត្ថេវ សុត្តន្តោតិ ។

ផ្តាច់ហើយ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើសញ្ញោជនៈនៃគ្រហស្ថព្រះអរហន្ត បានលះបង់ហើយ មានឫសគល់ផ្តាច់ហើយ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តទេ ។

( ៤២៨ ) គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ គ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈនៃគ្រហស្ថ ហើយធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ន មានដែរឬ ។ មិនមានទេ ។ បើគ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈនៃគ្រហស្ថ ហើយធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ន មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តទេ ។

( ៤២៩ ) គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ ក្រែងវច្ឆគោត្តបរិព្វាជក បានក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន គ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈរបស់គ្រហស្ថ លុះបែកធ្លាយរាងកាយ ហើយធ្វើនូវទីបំផុតនៃទុក្ខ មានដែរឬ (ព្រះមា ព្រះភាគ ទ្រង់ត្រាស់ថា) ម្នាលវច្ឆៈ គ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈរបស់គ្រហស្ថ លុះបែកធ្លាយរាងកាយ ហើយធ្វើនូវទីបំផុតនៃទុក្ខ មិនមានទេ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។

អាមន្តា ។ តេន ហិ ន វត្តព្វំ គិហិស្ស អរហាតិ ។

(៤២៦) គិហិស្ស អរហាតិ ។ អាមន្តា ។ អរហា មេថុនំ ធម្មំ បដិសេវេយ្យ មេថុនំ ធម្មំ ឧប្បាទេយ្យ បុត្តសម្ពាធសយនំ អជ្ឈាវសេយ្យ កាសិកចន្ទនំ បច្ចនុភវេយ្យ មាលាគន្ធវិលេបនំ ធារេយ្យ ជាតរូបរជតំ សាទិយេយ្យ អជេឡកំ បដិគ្គណ្ហេយ្យ កុក្កុដសូករំ បដិគ្គណ្ហេយ្យ ហត្ថិគវស្សវឡវំ បដិគ្គណ្ហេយ្យ តិត្តិរវដ្ដកមោរកបិញ្ជលំ បដិគ្គណ្ហេយ្យ បីតវណ្ណកាឡមោលិកំ ធារេយ្យ ឱទាតានិ វត្ថានិ ទីឃទសានិ ធារេយ្យ យាវជីវំ អគារិយភូតោ អស្សាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤២៧) ន វត្តព្វំ គិហិស្ស អរហាតិ ។ អាមន្តា ។ ននុ យសោ កុលបុត្តោ ឧត្តិយោ គហបតិ សេតុ មាណវោ គិហិស្ស ព្យញ្ជនេន អរហត្តំ បត្តាតិ ។ អាមន្តា ។ ហញ្ចិ យសោ កុលបុត្តោ ឧត្តិយោ គហបតិ សេតុ មាណវោ គិហិស្ស ព្យញ្ជនេន អរហត្តំ បត្តា តេន វត រេ វត្តព្វេ គិហិស្ស អរហាតិ ។

គិហិស្ស អរហាតិកថា ។

អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តទេ ។

(៤៦៦) គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ ព្រះអរហន្ត សេពមេថុនធម្ម ញុំាងមេថុនធម្មឲ្យកើតឡើង នៅគ្រប់គ្រងដំណេកដែលចង្អៀតដោយកូន លាបប្រោះព្រំខ្លឹមចន្ទន៍ដ៏ឧត្តម ទ្រទ្រង់ផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាប ត្រេកអរចំពោះមាសនិងប្រាក់ ទទួលពពែនិងចៀម ទទួលមាន់និងជ្រូក ទទួលដំរី គោ សេះឈ្មោល សេះញី ទទួលទទា គ្រួច ក្ងោក ចតាត ទ្រទ្រង់ក្ងួងសក់ដែលមានទង មានពណ៌លឿង ទ្រទ្រង់សំពត់សមានជាយវែង នៅជាគ្រហស្ថ ដរាបអស់មួយជីវិតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៦៧) បុគ្គលមិនគួរនិយាយថា គ្រហស្ថ បានជាព្រះអរហន្តទេឬ ។ អើ ។ ក្រែងយសកុលបុត្រ ឧត្តិយគហបតី និងសេតុមាណព ដល់នូវព្រះអរហត្ត ដោយភេទនៃគ្រហស្ថឬ ។ អើ ។ បើ យស-កុលបុត្រ ឧត្តិយគហបតិ និងសេតុមាណព ដល់នូវព្រះអរហត្ត ដោយភេទនៃគ្រហស្ថមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តដែរ ។

ចប់ គិហិអរហាតិកថា ។

## ឧបបត្តិកថា

(៤២៨) សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ សហ ឧបបត្តិយា សោតាបន្នោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤២៩) សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ សហ ឧបបត្តិយា សកទាគាមី ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៣០) សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ សហ ឧបបត្តិយា អនាគាមី ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៣១) សហ ឧបបត្តិយា សោតាបន្នោ ន ហោតីតិ ។ អាមន្តា ។ ហញ្ចិ សហ ឧបបត្តិយា សោតាបន្នោ ន ហោតិ នោ ច វត រេ វត្តព្វេ សហ ឧបបត្តិយា អរហាតិ ។

# ឧបបត្តិកថា

( ៤២៨ ) បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើង(១) ឬ ។ អើ ។ បុគ្គល បានជាសោតាបន្នៈ ជាមួយគ្នានឹងការកើតឡើង(២) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤២៩ ) បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គល បានជាសកទាគាមី ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៣០ ) បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គល បានជាអនាគាមី ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៣១ ) បុគ្គល បានជាសោតាបន្នៈ មិនមានជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើបុគ្គល បានជាសោតាបន្នៈ មិនមានជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

---

១ សំដៅយកបុគ្គល ដែល កើតក្នុងសុទ្ធាវាស បានសម្រេចជាអរហន្ត ជំណាលគ្នា នឹងការកើតឡើងឬ ?

២ សំដៅយក ឧបបត្តិចិត្ត ( ចិត្តកើតឡើងជាលោកិយៈ ) ។

[៤៣២] សហ ឧបបត្តិយា សកទាគាមី ន ហោតីតិ ។ អាមន្តា ។ ហញ្ចិ សហ ឧបបត្តិយា សកទាគាមី ន ហោតិ នោ វត រេ វត្តព្វេ សហ ឧបបត្តិយា អរហាតិ ។

[៤៣៣] សហ ឧបបត្តិយា អនាគាមី ន ហោតីតិ ។ អាមន្តា ។ ហញ្ចិ សហ ឧបបត្តិយា អនាគាមី ន ហោតិ នោ វត រេ វត្តព្វេ សហ ឧបបត្តិយា អរហាតិ ។

[៤៣៤] សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ សារីបុត្តោ ថេរោ សហ ឧបបត្តិយា អរហាតិ ។ ន ហេវំ វត្តព្វេ ។បេ។ មហាមោគ្គល្លានោ ថេរោ ។បេ។ មហាកស្សបោ ថេរោ ។បេ។ មហាកច្ចាយនោ ថេរោ ។បេ។ មហាកោដ្ឋិកោ ថេរោ ។បេ។ មហាបណ្ឋកោ ថេរោ សហ ឧបបត្តិយា អរហាតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៤៣៥] សារីបុត្តោ ថេរោ ន សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ ហញ្ចិ សារីបុត្តោ ថេរោ ន សហ ឧបបត្តិយា អរហា នោ វត រេ

[ ៤៣៦ ] បុគ្គល បានជាសកទាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើបុគ្គល បានជាសកទាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

[ ៤៣៧ ] បុគ្គល បានជាអនាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើបុគ្គល បានជាអនាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

[ ៤៣៨ ] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ ព្រះសារីបុត្តត្ថេរ បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះមោគ្គល្លានត្ថេរ ។ បេ ។ ព្រះមហាកស្សបត្ថេរ ។ បេ ។ ព្រះមហាកច្ចាយនត្ថេរ ។ បេ ។ ព្រះមហាកោដ្ឋិតត្ថេរ ។ បេ ។ ព្រះមហាបណ្ណកត្ថេរ បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤៣៩ ] ព្រះសារីបុត្តត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើព្រះសារីបុត្តត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន

វត្តព្វេ សហ ឧបបត្តិយា អរហាតិ ។

(៤៣៦) មហាមោគ្គល្លានោ ថេរោ ។ បេ ។ មហាកស្សបោ ថេរោ មហាកច្ចាយនោ ថេរោ មហាកោដ្ឋិកោ ថេរោ ។ បេ ។

(៤៣៧) មហាបន្ថកោ ថេរោ ន សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ ហញ្ចិ មហាបន្ថកោ ថេរោ ន សហ ឧបបត្តិយា អរហា នោ វត រេ វត្តព្វេ សហ ឧបបត្តិយា អរហាតិ ។

(៤៣៨) សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ ឧបបត្តេសិយេន ចិត្តេន អរហត្តំ សច្ឆិករោតិ លោកិយេន សាសវេន ។ បេ ។ សង្កិលេសិកេនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៣៩) សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ ឧបបត្តេសិយំ ចិត្តំ និយ្យានិកំ ខយគាមិ ពោធគាមិ អបចយគាមិ អនាសវំ ។ បេ ។ អសង្កិលេសិកន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

[ ៤៣៦ ] ព្រះមហាមោគ្គល្លានត្ថេរ ។ បេ ។ ព្រះមហាកស្សបត្ថេរ ព្រះមហាកច្ចាយនត្ថេរ ព្រះមហាកោដ្ឋិកត្ថេរ ។ បេ ។

[ ៤៣៧ ] ព្រះមហាបណ្ឌកត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើព្រះមហាបណ្ឌកត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

[ ៤៣៨ ] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវព្រះអរហត្ត ដោយចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង ( បដិសន្ធិចិត្ត ) ជាលោកិយៈ ប្រកបដោយអាសវៈ ។ បេ ។ ប្រកបដោយសេចក្តីសៅហ្មងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤៣៩ ] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ ចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង ជានិយ្យានិកៈ ដល់នូវការអស់ទៅ ដល់នូវការត្រាស់ដឹង ដល់នូវការមិនសន្សំ មិនមានអាសវៈ ។ បេ ។ មិនប្រកបដោយសេចក្តីសៅហ្មងទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៦០] ននុ ឧបបត្តេសិយំ ចិត្តំ អនិយ្យានិកំ ន ខយគាមិ ន ពោធគាមិ ន អបចយគាមិ សាសវំ ។បេ។ សង្កិលេសិកន្តិ ។ អាមន្តា ។ ហញ្ចិ ឧបបត្តេសិយំ ចិត្តំ អនិយ្យានិកំ ន ខយគាមិ ន ពោធគាមិ ន អបចយគាមិ សាសវំ ។បេ។ សង្កិលេសិកំ នោ វត រេ វត្តព្វេ សព្វា ឧបបត្តិយា អព្យាកតាតិ ។

[៦៦១] សព្វា ឧបបត្តិយា អព្យាកតាតិ ។ អាមន្តា ។ ឧបបត្តេសិយេន ចិត្តេន រាគំ បជហតិ ទោសំ បជហតិ មោហំ បជហតិ ។បេ។ អនោត្តប្បំ បជហតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៦៦២] សព្វា ឧបបត្តិយា អព្យាកតាតិ ។ អាមន្តា ។ ឧបបត្តេសិយំ ចិត្តំ មគ្គោ ។បេ។ សតិប្បដ្ឋានំ សម្មប្បធានំ ឥទ្ធិបាទោ ឥន្ទ្រិយំ ពលំ ។បេ។ ពោជ្ឈង្គោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៦៦៣] សព្វា ឧបបត្តិយា អព្យាកតាតិ ។

( ៤៤០ ) ក្រែងចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង មិនមែនជានិយ្យានិកៈ មិនដល់នូវការអស់ទៅ មិនដល់នូវការត្រាស់ដឹង មិនដល់នូវការមិនសន្សំ ប្រកបដោយអាសវៈ ។ បេ ។ ប្រកបដោយសេចក្តីសៅហ្មងឬ ។ អើ ។ បើចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង មិនមែនជានិយ្យានិកៈ មិនដល់នូវការអស់ទៅ មិនដល់នូវការត្រាស់ដឹង មិនដល់នូវការមិនសន្សំ ប្រកបដោយអាសវៈ ។ បេ ។ ប្រកបដោយសេចក្តីសៅហ្មង មាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

( ៤៤១ ) បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គល លះរាគៈ លះទោសៈ លះមោហៈ ។ បេ ។ លះអនោត្តប្បៈ ដោយចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៤២ ) បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ ចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង ជាមគ្គ ។ បេ ។ ជាសតិប្បដ្ឋាន ជាសម្មប្បធាន ជាឥទ្ធិបាទ ជាឥន្ទ្រិយ ជាពលៈ ។ បេ ។ ជាពោជ្ឈង្គៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៤៣ ) បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។

អាមន្តា ។ ឧបបត្តេសិយេន ចិត្តេន ទុក្ខំ បរិជានាតិ សមុទយំ បជហាតិ និរោធំ សច្ឆិករោតិ មគ្គំ ភាវេ-តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៤៤) សហ ឧបបត្តិយា អរហាតិ ។ អាម-ន្តា ។ ចុតិចិត្តំ មគ្គចិត្តំ ឧបបត្តេសិយំ ចិត្តំ ផល-ចិត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ឧបបត្តិកថា ។

# អនាសវកថា

(៤៤៥) អរហតោ សព្វេ ធម្មា អនាសវាតិ ។ អាមន្តា ។ មគ្គោ ផលំ និព្វានំ សោតាបត្តិមគ្គោ សោតាបត្តិផលំ សកទាគាមិមគ្គោ សកទាគាមិផលំ អនាគាមិមគ្គោ អនាគាមិផលំ អរហត្តមគ្គោ អរហត្ត-ផលំ សតិប្បដ្ឋានំ សម្មប្បធានំ ឥទ្ធិបាទោ ឥន្ទ្រិយំ ពលំ ពោជ្ឈង្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៤៦) អរហតោ សព្វេ ធម្មា អនាសវាតិ ។ អាមន្តា ។ អរហតោ ចក្ខុំ អនាសវន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហតោ ចក្ខុំ អនាសវន្តិ ។

អើ ។ បុគ្គល កំណត់ដឹងនូវទុក្ខសច្ច លះនូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ដោយចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៤៤) បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើង ឬ ។ អើ ។ ចុតិចិត្ត មគ្គចិត្ត ចិត្តដែលកំពុងស្វែងរកនូវការកើតឡើង ជាផលចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ឧបបត្តិកថា ។

## អនាសវកថា

(៤៤៥) ពួកធម៌ទាំងអស់ របស់ព្រះអរហន្ត មិនមានអាសវៈទេ ឬ ។ អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អរហត្តផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ (របស់ព្រះអរហន្ត ជាធម៌មិនមានអាសវៈ) ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៤៦) ពួកធម៌ទាំងអស់ របស់ព្រះអរហន្ត មិនមានអាសវៈទេ ឬ ។ អើ ។ ចក្ខុ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។

អាមន្តា ។ មគ្គោ ផលំ និព្វានំ សោតាបត្តិមគ្គោ សោតាបត្តិផលំ ។ បេ ។ ពោជ្ឈង្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហតោ សោតំ ។ បេ ។ អរហតោ ឃានំ ។ បេ ។ អរហតោ ជិវ្ហា ។ បេ ។ អរហតោ កាយោ អនាសវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៧) អរហតោ កាយោ អនាសវោតិ ។ អាមន្តា ។ មគ្គោ ផលំ និព្វានំ សោតាបត្តិមគ្គោ សោតាបត្តិផលំ ។ បេ ។ ពោជ្ឈង្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៨) អរហតោ កាយោ អនាសវោតិ ។ អាមន្តា ។ អរហតោ កាយោ បគ្គហនិគ្គហុបគោ ឆេទនភេទនុបគោ កាកេហិ គិជ្ឈេហិ កុលលេហិ សាធារណោតិ ។ អាមន្តា ។ អនាសវោ ធម្មោ បគ្គហនិគ្គហុបគោ ឆេទនភេទនុបគោ កាកេហិ គិជ្ឈេហិ កុលលេហិ សាធារណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៩) អរហតោ កាយេ វិសំ កមេយ្យ សត្ថំ កមេយ្យ អគ្គិ កមេយ្យាតិ ។ អាមន្តា ។

អើ ៗ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល ។បេ។ ពោជ្ឈង្គៈ (របស់ព្រះអរហន្ត ជាធម៌មិនមានអាសវៈ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ត្រចៀក របស់ព្រះអរហន្ត ។បេ។ ច្រមុះ របស់ព្រះអរហន្ត ។បេ។ អណ្តាត របស់ព្រះអរហន្ត ។បេ។ កាយ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៤៧) កាយ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ៗ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល ។បេ។ ពោជ្ឈង្គៈ (របស់ព្រះអរហន្ត ជាធម៌មិនមានអាសវៈ) ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៤៨) កាយ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ៗ កាយ របស់ព្រះអរហន្ត គួរដល់នូវការផ្គងឡើងនិងការសង្កត់សង្កិន គួរដល់នូវការដាច់និងការបែកធ្លាយ ជាសាធារណៈ ដល់ពួកក្អែក ត្មាត ខ្លែងដែរឬ ។ អើ ។ ធម៌ មិនមានអាសវៈ គួរដល់នូវការផ្គងឡើងនិងការសង្កត់សង្កិន គួរដល់នូវការដាច់និងការបែកធ្លាយ ជាសាធារណៈ ដល់ពួកក្អែក ត្មាត ខ្លែងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៤៩) ថ្នាំពិស គួរបែបលទៅ គ្រឿងសស្ត្រា គួរមុតភ្លើង គួរឆេះ ចំពោះកាយ របស់ព្រះអរហន្តដែរឬ ។ អើ ។

## អនាសវកថា

អនាសវេ ធម្មេ វិសំ កមេយ្យ សត្ថំ កមេយ្យ អគ្គិ កមេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៤៨០ ) លព្ភា អរហតោ កាយោ អន្ទុពន្ធនេន ពន្ធិតុំ រជ្ជុពន្ធនេន ពន្ធិតុំ សង្ខលិកពន្ធនេន ពន្ធិតុំ គាមពន្ធនេន ពន្ធិតុំ និគមពន្ធនេន ពន្ធិតុំ នគរពន្ធនេន ពន្ធិតុំ ជនបទពន្ធនេន ពន្ធិតុំ កណ្ឋបញ្ចមេហិ ពន្ធនេហិ ពន្ធិតុន្តិ ។ អាមន្តា ។ លព្ភា អនាសវោ ធម្មោ អន្ទុពន្ធនេន ពន្ធិតុំ រជ្ជុពន្ធនេន ពន្ធិតុំ សង្ខលិកពន្ធនេន ពន្ធិតុំ គាមពន្ធនេន និគមពន្ធនេន នគរពន្ធនេន ជនបទពន្ធនេន កណ្ឋបញ្ចមេហិ ពន្ធនេហិ ពន្ធិតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៤៨១ ) យទិ អរហា បុថុជ្ជនស្ស ចីវរំ ទេតិ អនាសវំ ហុត្វា សាសវំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនាសវំ ហុត្វា សាសវំ ហោតីតិ ។ អាមន្តា ។ តញ្ញេវ អនាសវំ តំ សាសវន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តញ្ញេវ អនាសវំ តំ សាសវន្តិ ។ អាមន្តា ។ មគ្គោ អនាសវោ ហុត្វា

ថ្នាំពិស គួរចូលទៅ គ្រឿងសស្ត្រា គួរមុត ភ្លើង គួរឆេះ ចំពោះធម៌ ដែលមិនមានអាសវៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៥០ ) កាយ របស់ព្រះអរហន្ត គួរដើម្បីជាប់ដោយចំណងគឺខ្នោះ ដើម្បីជាប់ដោយចំណងគឺខ្សែ ដើម្បីជាប់ដោយចំណងគឺប្រពក់ ដើម្បីជាប់ដោយចំណងគឺស្រុក ដើម្បីជាប់ដោយចំណងគឺនិគម ដើម្បីជាប់ដោយចំណងគឺនគរ ដើម្បីជាប់ដោយចំណងគឺជនបទ ដើម្បីជាប់ដោយចំណងមានកជាគម្រប់ ៥ ដែរឬ ។ អើ ។ ធម៌ មិនមានអាសវៈ គួរដើម្បីជាប់ដោយចំណងគឺខ្នោះ ដើម្បីជាប់ដោយចំណងគឺខ្សែ ដើម្បីជាប់ដោយចំណងគឺប្រពក់ ដោយចំណងគឺស្រុក ដោយចំណងគឺនិគម ដោយចំណងគឺនគរ ដោយចំណងគឺជនបទ ដើម្បីជាប់ដោយចំណងមានកជាគម្រប់ ៥ ដែរឬ ។ អ្នកមិ គួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៥១ ) បើព្រះអរហន្ត ឲ្យចីវរដល់បុថុជ្ជន ( ចីវរនោះ ) ជាវត្ថុមិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ( ចីវរ ) ជាវត្ថុមិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អើ ។ ចីវរនោះឯង មិនមានអាសវៈទេ តែចីវរនោះ ប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចីវរនោះ មិនមានអាសវៈទេ តែចីវរនោះ ប្រកបដោយអាសវៈ មានដែរឬ ។ អើ ។ មគ្គ ជាធម៌មិនមានអាសវៈ

សាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ផលំ សតិប្បដ្ឋានំ សម្មប្បធានំ ឥទ្ធិបាទោ ឥន្ទ្រិយំ ពលំ ពោជ្ឈង្គោ អនាសវោ ហុត្វា សាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៥២) យទិ អរហា បុថុជ្ជនស្ស បិណ្ឌបាតំ ទេតិ សេនាសនំ ទេតិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទេតិ អនាសវោ ហុត្វា សាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនាសវោ ហុត្វា សាសវោ ហោតីតិ ។ អាមន្តា ។ តញ្ញេវ អនាសវំ តំ សាសវន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តញ្ញេវ អនាសវំ តំ សាសវន្តិ ។ អាមន្តា ។ មគ្គោ អនាសវោ ហុត្វា សាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ផលំ សតិប្បដ្ឋានំ សម្មប្បធានំ ឥទ្ធិបាទោ ឥន្ទ្រិយំ ពលំ ពោជ្ឈង្គោ អនាសវោ ហុត្វា សាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

តែប្រកបដោយអាសវៈ មានវត្ថុ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ ជាធម៌មិនមានអាសវៈ តែប្រកបដោយអាសវៈ មានវត្ថុ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៥២ ) បើព្រះអរហន្ត ឲ្យបិណ្ឌបាត ឲ្យទីសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ដល់បុថុជ្ជន ( បច្ច័យមានបិណ្ឌបាតជាដើមនោះ ) ជាសភាពមិនមានអាសវៈ តែប្រកបដោយអាសវៈ មានវត្ថុ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (បច្ច័យមានបិណ្ឌបាតជាដើមនោះ ) ជាសភាពមិនមានអាសវៈ តែប្រកបដោយអាសវៈ មានវត្ថុ ។ អើ ។ បច្ច័យមានបិណ្ឌបាតជាដើមនោះឯង មិនមានអាសវៈទេ តែបច្ច័យមានបិណ្ឌបាតជាដើមនោះ ប្រកបដោយអាសវៈ មានវត្ថុ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បច្ច័យមានបិណ្ឌបាតជាដើមនោះឯង មិនមានអាសវៈទេ តែបច្ច័យមានបិណ្ឌបាតជាដើមនោះ ប្រកបដោយអាសវៈ មានវត្ថុ ។ អើ ។ មគ្គ ជាធម៌មិនមានអាសវៈ តែប្រកបដោយអាសវៈ មានវត្ថុ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ ជាធម៌មិនមានអាសវៈ តែប្រកបដោយអាសវៈ មានវត្ថុ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អនាសវកថា

(៤៩៣) យទិ បុថុជ្ជនោ អរហតោ ចីវរំ ទេតិ សា-
សវំ ហុត្វា អនាសវំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៩៤) សាសវំ ហុត្វា អនាសវំ ហោតីតិ ។ អាមន្តា ។ តញ្ញេវ សាសវំ តំ អនាសវន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តញ្ញេវ សាសវំ តំ អនាសវន្តិ ។ អាមន្តា ។ រាគោ សាសវោ ហុត្វា អនាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទោសោ មោហោ ។ បេ ។ អនោត្តប្បំ សាសវំ ហុត្វា អនាសវំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៩៥) យទិ បុថុជ្ជនោ អរហតោ បិណ្ឌបាតំ ទេតិ សេនាសនំ ទេតិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទេតិ សាសវោ ហុត្វា អនាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៩៦) សាសវោ ហុត្វា អនាសវោ ហោតីតិ ។

អនាសវកថា

[ ៤៩៣ ] បើបុគ្គលឱ្យចីវរដល់ព្រះអរហន្ត ( ចីវរនោះ ) ជាវត្ថុប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤៩៤ ] ( ចីវរ ) ជាវត្ថុប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អើ ។ ចីវរនោះឯង ប្រកបដោយអាសវៈ តែចីវរនោះ មិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចីវរនោះឯង ប្រកបដោយអាសវៈ តែចីវរនោះ មិនមានអាសវៈ មានដែរឬ ។ អើ ។ រាគៈ ជាធម៌ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទោសៈ មោហៈ ។ បេ ។ អនោត្តប្បៈ ជាធម៌ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤៩៥ ] បើបុគ្គលឱ្យបិណ្ឌបាត ឱ្យសេនាសនៈ ឱ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ដល់ព្រះអរហន្ត ( បច្ច័យមានបិណ្ឌបាតជាដើមនោះ ) ជាសភាពប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤៩៦ ] ( បច្ច័យមានបិណ្ឌបាតជាដើមនោះ ) ជាសភាពប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។

អាមន្តា ។ តញ្ញេវ សាសវំ តំ អនាសវន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តញ្ញេវ សាសវំ តំ អនាសវន្តិ ។ អាមន្តា ។ រាគោ សាសវោ ហុត្វា អនាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទោសោ ។ បេ ។ មោហោ ។ បេ ។ អនោត្តប្បំ សាសវំ ហុត្វា អនាសវំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៩៧) ន វត្តព្វំ អរហតោ សព្វេ ធម្មា អនាសវាតិ ។ អាមន្តា ។ ននុ អរហា អនាសវោតិ ។ អាមន្តា ។ ហញ្ចិ អរហា អនាសវោ តេន វត រេ វត្តព្វេ អរហតោ សព្វេ ធម្មា អនាសវាតិ ។

អនាសវកថា ។

## សមន្នាគតកថា

(៤៩៨) អរហា ចតូហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អរហា ចតូហិ ផស្សេហិ ចតូហិ វេទនាហិ ចតូហិ សញ្ញាហិ ចតូហិ ចេតនាហិ ចតូហិ ចិត្តេហិ ចតូហិ សទ្ធាហិ ចតូហិ វីរិយេហិ

អើ ។ បច្ច័យមានបិណ្ឌបាតជាដើមនោះ ប្រកបដោយអាសវៈ តែបច្ច័យមានបិណ្ឌបាតជាដើមនោះ មិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បច្ច័យមានបិណ្ឌបាតជាដើមនោះឯង ប្រកបដោយអាសវៈ តែបច្ច័យមានបិណ្ឌបាតជាដើមនោះ មិនមានអាសវៈ មានដែរឬ ។ អើ ។ រាគៈ ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទោសៈ ។ បេ ។ មោហៈ ។ បេ ។ អនោត្តប្បៈ ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៥៧ ) បុគ្គលមិនគួរនិយាយថា ពួកធម៌ទាំងអស់ របស់ព្រះអរហន្ត មិនអាសវៈទេឬ ។ អើ ។ ក្រែងព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ។ បើព្រះអរហន្ត មិនមានអាសវៈទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ពួកធម៌ទាំងអស់ របស់ព្រះអរហន្ត មិនមានអាសវៈទេ ។

ចប់ អនាសវកថា ។

# សមន្នាគតកថា

( ៤៥៨ ) ព្រះអរហន្ត ប្រកបដោយផល ៤ ឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយផស្សៈ ៤ ដោយវេទនា ៤ ដោយសញ្ញា ៤ ដោយចេតនា ៤ ដោយចិត្ត ៤ ដោយសទ្ធា ៤ ដោយវីរិយៈ ៤

## សមន្នាគតកថា

ចតូហិ សតីហិ ចតូហិ សមាធីហិ ចតូហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៥៩) អនាគាមី តីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អនាគាមី តីហិ ផស្សេហិ ។ បេ ។ តីហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៦០) សកទាគាមី ទ្វីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមី ទ្វីហិ ផស្សេហិ ។ បេ ។ ទ្វីហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៦១) អរហា សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ អរហា សោតាបន្នោ សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហា សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ អរហា សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហា អនាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ អរហា អនាគាមី អន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតោ អកនិដ្ឋគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ដោយសតិ ៤ ដោយសមាធិ ៤ ដោយបញ្ញា ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៥៩ ) អនាគាមិបុគ្គល ប្រកបដោយផល ៣ ឬ ។ អើ ។ អនាគាមិបុគ្គល ប្រកបដោយផស្សៈ ៣ ។ បេ ។ ដោយបញ្ញា ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៦០ ) សកទាគាមិបុគ្គល ប្រកបដោយផល ២ ឬ ។ អើ ។ សកទាគាមិបុគ្គល ប្រកបដោយផស្សៈ ២ ។ បេ ។ ដោយបញ្ញា ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៦១ ) ព្រះអរហន្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ព្រះអរហន្ត ជាសោតាបន្នបុគ្គល គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះអរហន្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ព្រះអរហន្ត ជាសកទាគាមិបុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះអរហន្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ ព្រះអរហន្ត ជាអនាគាមិបុគ្គល គឺអន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតៈ អកនិដ្ឋគាមីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ២៦២ ) អនាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ អនាគាមី សោតាបន្នោ សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនាគាមី សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ អនាគាមី សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ២៦៣ ) សកទាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមី សោតាបន្នោ សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ២៦៤ ) សោតាបត្តិផលេន សមន្នាគតោ សោតាបន្នោតិ វត្តព្វោតិ ។ អាមន្តា ។ អរហា សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ តេន្ហិ អរហា សោ សោតាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ២៦៥ ) សកទាគាមិផលេន សមន្នាគតោ សកទាគាមីតិ វត្តព្វោតិ ។ អាមន្តា ។ អរហា សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ តេន្ហិ អរហា សោ សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៤៦២ ] អនាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ អនាគាមិបុគ្គល ជាសោតាបន្នបុគ្គល គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អនាគាមិបុគ្គល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ អនាគាមិបុគ្គល ជាសកទាគាមិបុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤៦៣ ] សកទាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ សកទាគាមិបុគ្គល ជាសោតាបន្នបុគ្គល គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤៦៤ ] បុគ្គល ប្រកបដោយសោតាបត្តិផល គួរនិយាយថា សោតាបន្នបុគ្គលឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ព្រះអរហន្តនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤៦៥ ] បុគ្គល ប្រកបដោយសកទាគាមិផល គួរនិយាយថា សកទាគាមិបុគ្គលឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ព្រះអរហន្តនោះឯង គឺសកទាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## សមន្នាគតកថា

[៦៦៦] អនាគាមិផលេន សមន្នាគតោ អនាគាមីតិ ។ វត្តព្វោតិ ។ អាមន្តា ។ អរហា អនាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេ អរហា សោ អនាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៦៧] សោតាបត្តិផលេន សមន្នាគតោ សោតាបន្នោតិ វត្តព្វោតិ ។ អាមន្តា ។ អនាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេ អនាគាមី សោ សោតាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៦៨] សកទាគាមិផលេន សមន្នាគតោ សកទាគាមីតិ វត្តព្វោតិ ។ អាមន្តា ។ អនាគាមី សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេ អនាគាមី សោ សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៦៩] សោតាបត្តិផលេន សមន្នាគតោ សោតាបន្នោតិ វត្តព្វោតិ ។ អាមន្តា ។ សកទាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេ សកទាគាមី សោ សោតាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

សមន្នាគតកថា

( ៤៦៦ ) បុគ្គល ប្រកបដោយអនាគាមិផល គួរនិយាយថា អនាគាមិបុគ្គលឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ ព្រះអរហន្តនោះឯង គឺអនាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៦៧ ) បុគ្គល ប្រកបដោយសោតាបត្តិផល គួរនិយាយថា សោតាបន្នបុគ្គលឬ ។ អើ ។ អនាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ អនាគាមិបុគ្គលនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៦៨ ) បុគ្គល ប្រកបដោយសកទាគាមិផល គួរនិយាយថា សកទាគាមិបុគ្គលឬ ។ អើ ។ អនាគាមិបុគ្គល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ អនាគាមិបុគ្គលនោះឯង គឺសកទាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៦៩ ) បុគ្គល ប្រកបដោយសោតាបត្តិផល គួរនិយាយថា សោតាបន្នបុគ្គលឬ ។ អើ ។ សកទាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ សកទាគាមិបុគ្គលនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៧០] អរហា សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហា សោតាបត្តិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អរហា សោតាបត្តិផលំ វីតិវត្តោ នោ ច វត រេ វត្តព្វេ អរហា សោតាបត្តិផលេន សមន្នាគតោតិ ។

[៤៧១] អរហា សោតាបត្តិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អរហា សោតាបត្តិមគ្គំ វីតិវត្តោ សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ អបាយគមនិយំ រាគំ អបាយគមនិយំ ទោសំ អបាយគមនិយំ មោហំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៤៧២] អរហា សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហា សកទាគាមិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អរហា សកទាគាមិផលំ វីតិវត្តោ នោ ច វត រេ វត្តព្វេ អរហា សកទាគាមិផលេន សមន្នាគតោតិ ។

(៤៧០) ព្រះអរហន្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ប្រកបដោយសោតាបត្តិផលទេ ។

(៤៧១) ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ រាគៈ ដែលជាដំណើរទៅកាន់អបាយ ទោសៈ ដែលជាដំណើរទៅកាន់អបាយ និងមោហៈ ដែលជាដំណើរទៅកាន់អបាយ ហើយ ប្រកបដោយសោតាបត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៧២) ព្រះអរហន្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយឬ ។ អើ ។ បើព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ប្រកបដោយសកទាគាមិផលទេ ។

(៤៧៣) អរហា សកទាគាមិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អរហា សកទាគាមិមគ្គំ វីតិវត្តោ ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៧៤) អរហា អនាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហា អនាគាមិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អរហា អនាគាមិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អរហា អនាគាមិផលេន សមន្នាគតោតិ ។

(៤៧៥) អរហា អនាគាមិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អរហា អនាគាមិមគ្គំ វីតិវត្តោ អណុសហគតំ កាមរាគំ អណុសហគតំ ព្យាបាទំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៧៦) អនាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អនាគាមី សោតាបត្តិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អនាគាមី សោតាបត្តិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អនាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។

[ ៤៧៣ ] ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផល ហើយ ប្រកបដោយសកទាគាមិផលនោះឬ ។ អើ ។ ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសកទាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ហើយប្រកបដោយសកទាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤៧៤ ] ព្រះអរហន្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រព្រឹត្តកន្លងនូវអនាគាមិផលហើយឬ ។ អើ ។ បើព្រះអរហន្ត ប្រព្រឹត្តកន្លងនូវអនាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ប្រកបដោយអនាគាមិផលទេ ។

[ ៤៧៥ ] ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវអនាគាមិផល ហើយប្រកបដោយអនាគាមិផលនោះឬ ។ អើ ។ ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវអនាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏ស្រាលស្ដើង ព្យាបាទដ៏ស្រាលស្ដើង ហើយប្រកបដោយអនាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤៧៦ ] អនាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អនាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលទេ ។

(៤៧៧) អនាគាមី សោតាបត្តិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អនាគាមី សោតាបត្តិមគ្គំ វីតិវត្តោ សក្កាយទិដ្ឋឹ ។ បេ ។ អបាយគមនិយំ មោហំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៧៨) អនាគាមី សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អនាគាមី សកទាគាមិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អនាគាមី សកទាគាមិផលំ វីតិវត្តោ នោ ច វត រេ វត្តព្វេ អនាគាមី សកទាគាមិផលេន សមន្នាគតោតិ ។

(៤៧៩) អនាគាមី សកទាគាមិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អនាគាមី សកទាគាមិមគ្គំ វីតិវត្តោ ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៤៧៧ ) អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផល ហើយប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ ។ បេ ។ មោហៈដែលជាដំណើរទៅកាន់អបាយ ហើយប្រកបដោយសោតាបត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៧៨ ) អនាគាមិបុគ្គល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ក្រែងអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយឬ ។ អើ ។ បើអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អនាគាមិបុគ្គល ប្រកបដោយសកទាគាមិផលទេ ។

( ៤៧៩ ) អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិផល ហើយប្រកបដោយសកទាគាមិផលនោះឬ ។ អើ ។ អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ហើយប្រកបដោយសកទាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## សមន្នាគតកថា

(៤៨០) សកទាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ សកទាគាមី សោតាបត្តិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ សកទាគាមី សោតាបត្តិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ សកទាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។

(៤៨១) សកទាគាមី សោតាបត្តិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមី សោតាបត្តិមគ្គំ វីតិវត្តោ សក្កាយទិដ្ឋឹ ។ បេ ។ អបាយគមនិយំ មោហំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៨២) ន វត្តព្វំ អរហា ចតូហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហតា ចត្តារិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អាមន្តា ។ ហញ្ចិ អរហតា ចត្តារិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោ តេន វត រេ វត្តព្វេ អរហា ចតូហិ ផលេហិ សមន្នាគតោតិ ។

សមន្តាគតកថា

( ៤៨០ ) សកទាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងសកទាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលៈហើយឬ ។ អើ ។ បើសកទាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សកទាគាមិបុគ្គលប្រកបដោយសោតាបត្តិផលទេ ។

( ៤៨១ ) សកទាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ សកទាគាមិបុគ្គលប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ ។ បេ ។ និងមោហៈ ដែលជាដំណើរទៅកាន់អបាយ ហើយប្រកបដោយសោតាបត្តិ-មគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤៨២ ) បុគ្គលមិនគួរនិយាយថា ព្រះអរហន្ត ប្រកបដោយផល ៤ទេឬ ។ អើ ។ ក្រែងព្រះអរហន្ត បានចំពោះនូវផល ៤ ហើយមិនសាបសូន្យចាកផល ៤ នោះទេឬ ។ អើ ។ បើព្រះអរហន្ត បានចំពោះនូវផល ៤ មិនសាបសូន្យចាកផល ៤ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះអរហន្ត ប្រកបដោយផល៤ដែរ ។

(៤៨៣) ន វត្តព្វំ អនាគាមី តីហិ ឋានេហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ អនាគាមិនា តី-ណិ ឋានានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អាមន្តា ។ ហញ្ចិ អនាគាមិនា តីណិ ឋានានិ បដិ-លទ្ធានិ តេហិ ច អបរិហីនោ តេន វត រេ វត្តព្វេ អនាគាមី តីហិ ឋានេហិ សមន្នាគតោតិ ។

(៤៨៤) ន វត្តព្វំ សកទាគាមី ទ្វីហិ ឋានេហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ សកទាគាមិនា ទ្វេ ឋានានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អាមន្តា ។ ហញ្ចិ សកទាគាមិនា ទ្វេ ឋានានិ បដិ-លទ្ធានិ តេហិ ច អបរិហីនោ តេន វត រេ វត្តព្វេ សកទាគាមី ទ្វីហិ ឋានេហិ សមន្នាគតោតិ ។

(៤៨៥) អរហតា ចត្តារិ ឋានានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អរហា ចតូហិ ឋានេហិ ស-មន្នាគតោតិ ។ អាមន្តា ។ អរហតា ចត្តារោ មគ្គា បដិលទ្ធា តេហិ ច អបរិហីនោតិ ។ អរហា ចតូហិ មគ្គេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ ។

[ ៤៨៣ ] បុគ្គលមិនគួរនិយាយថា អនាគាមិបុគ្គល ប្រកប ដោយផល ៣ ទេឬ ។ អើ ។ ក្រែងអនាគាមិបុគ្គល បានចំពោះនូវ ផល ៣ ហើយមិនសាបសូន្យចាកផលនោះទេឬ ។ អើ ។ បើអនា-គាមិបុគ្គល បានចំពោះនូវផល ៣ ហើយមិនសាបសូន្យចាកផល ៣ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អនាគា-មិបុគ្គល ប្រកបដោយផល ៣ ដែរ ។

[ ៤៨៤ ] បុគ្គលមិនគួរនិយាយថា សកទាគាមិបុគ្គល ប្រកប ដោយផល ២ ទេឬ ។ អើ ។ ក្រែងសកទាគាមិបុគ្គល បានចំពោះ នូវផល ២ ហើយមិនសាបសូន្យចាកផល ២ នោះទេឬ ។ អើ ។ បើ សកទាគាមិបុគ្គល បានចំពោះនូវផល ២ ហើយមិនសាបសូន្យចាកផល ២ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សក-ទាគាមិបុគ្គល ប្រកបដោយផល ២ ដែរ ។

[ ៤៨៥ ] ព្រះអរហន្ត បានចំពោះនូវផល ៤ ហើយមិនសាប-សូន្យចាកផល ៤ នោះទេឬ ។ ព្រះអរហន្ត ប្រកបដោយផល ៤ ឬ ។ អើ ។ ព្រះអរហន្ត បានចំពោះនូវមគ្គ ៤ ហើយមិនសាបសូន្យចាកមគ្គ ៤ នោះទេឬ ។ ព្រះអរហន្ត ប្រកបដោយមគ្គ ៤ ឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[ ៤៨៦ ] អនាគាមិនា តីណិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អនាគាមី តីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អនាគាមិនា តយោ មគ្គា បដិលទ្ធា តេហិ ច អបរិហីនោតិ ។ អនាគាមី តីហិ មគ្គេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៤៨៧ ] សកទាគាមិនា ទ្វេ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ សកទាគាមី ទ្វីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមិនា ទ្វេ មគ្គា បដិលទ្ធា តេហិ ច អបរិហីនោតិ ។ សកទាគាមី ទ្វីហិ មគ្គេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

សមន្នាគតកថា ។

# ឧបេក្ខាសមន្នាគតកថា

[ ៤៨៨ ] អរហា ឆហិ ឧបេក្ខាហិ សមន្នាគតោតិ ។ អាមន្តា ។ អរហា ឆហិ ផស្សេហិ ឆហិ វេទនាហិ ឆហិ សញ្ញាហិ ។ បេ ។ ឆហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៤៨៦ ] អនាគាមិបុគ្គល បានបំពោះនូវផល ៣ ហើយមិនសាបសូន្យចាកផល ៣ នោះទេឬ ។ អនាគាមិបុគ្គល ប្រកបដោយផល ៣ ឬ ។ អើ ។ អនាគាមិបុគ្គល បានបំពោះនូវមគ្គ ៣ ហើយមិនសាបសូន្យចាកមគ្គ ៣ នោះទេឬ ។ អនាគាមិបុគ្គល ប្រកបដោយមគ្គ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៨៧ ] សកទាគាមិបុគ្គល បានបំពោះនូវផល ២ ហើយមិនសាបសូន្យចាកផល ២ នោះទេឬ ។ សកទាគាមិបុគ្គល ប្រកបដោយផល ២ ឬ ។ អើ ។ សកទាគាមិបុគ្គល បានបំពោះនូវមគ្គ ២ ហើយមិនសាបសូន្យចាកមគ្គ ២ នោះទេឬ ។ សកទាគាមិបុគ្គល ប្រកបដោយមគ្គ ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ចប់ សមន្នាគតកថា ។

## ឧបេក្ខាសមន្នាគតកថា

[ ៤៨៨ ] ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយផស្សៈ ៦ ដោយវេទនា ៦ ដោយសញ្ញា ៦ ។បេ។ ដោយបញ្ញា ៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

( ៤៨៩ ) អរហា ឆហិ ឧបេក្ខាហិ សមន្នាគតោតិ ។ អាមន្តា ។ អរហា ចក្ខុនា រូបំ បស្សន្តោ សោតេន សទ្ទំ សុណាតិ ឃានេន គន្ធំ ឃាយតិ ជិវ្ហាយ រសំ សាយតិ កាយេន ផោដ្ឋព្វំ ផុសតិ មនសា ធម្មំ វិជានាតិ ។ បេ ។ មនសា ធម្មំ វិជានន្តោ ចក្ខុនា រូបំ បស្សតិ សោតេន សទ្ទំ សុណាតិ ឃានេន គន្ធំ ឃាយតិ ជិវ្ហាយ រសំ សាយតិ កាយេន ផោដ្ឋព្វំ ផុសតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៤៩០ ) អរហា ឆហិ ឧបេក្ខាហិ សមន្នាគតោតិ ។ អាមន្តា ។ សតតំ សមិតំ អព្វោកិណ្ណំ ឆហិ ឧបេក្ខាហិ សមន្នាគតោ សមាហិតោ ឆ ឧបេក្ខាយោ បច្ចុបដ្ឋិតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៤៩១ ) ន វត្តព្វំ អរហា ឆហិ ឧបេក្ខាហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហា ឆឡុបេក្ខោតិ ។ អាមន្តា ។ ហញ្ចិ អរហា ឆឡុបេក្ខោ តេន វត រេ វត្តព្វេ អរហា ឆហិ ឧបេក្ខាហិ សមន្នាគតោតិ ។

ឧបេក្ខាសមន្នាគតកថា ។

(៤៨៩) ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ឬ ។ អើ ។ ព្រះអរហន្ត កាលឃើញរូបដោយចក្ខុ រមែងឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សរសដោយអណ្តាត ពាល់ត្រូវផ្សព្វដោយកាយ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ។ បេ ។ កាលដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត រមែងឃើញរូបដោយចក្ខុ ឮសំឡេងដោយត្រ-ចៀក ធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សរសដោយអណ្តាត ពាល់ត្រូវផ្សព្វដោយកាយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៩០) ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ឬ ។ អើ ។ (ព្រះអរហន្ត) ប្រកបដោយឧបេក្ខា ៦ មានចិត្តខាប់ខ្ជួន ទៀងទាត់ មិនភាយមាយ ចុះឧបេក្ខាទាំង ៦ តាំងឡើងប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៩១) បុគ្គលមិនគួរនិយាយថា ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ទេឬ ។ អើ ។ ក្រែងព្រះអរហន្ត មានឧបេក្ខា ៦ ឬ ។ អើ ។ បើព្រះអរហន្ត មានឧបេក្ខា ៦ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ។

ចប់ ឧបេក្ខាសមន្នាគតកថា ។

# ពោធិយា ពុទ្ធោតិកថា

(៤៩២) ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ ពោធិយា និរុទ្ធាយ វិគតាយ បដិប្បស្សទ្ធាយ អពុទ្ធោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៩៣) ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ អតីតាយ ពោធិយា ពុទ្ធោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៩៤) អតីតាយ ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៩៥) តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ តាយ ពោធិយា ទុក្ខំ បរិជានាតិ សមុទយំ បជហាតិ និរោធំ សច្ឆិករោតិ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៩៦) ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ អនាគតាយ ពោធិយា ពុទ្ធោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# ពោធិយា ពុទ្ធោតិកថា

(៤៩២) បុគ្គលជាព្រះពុទ្ធ ដោយពោធិញាណ (ចតុមគ្គញាណ និងសព្វញ្ញុតញ្ញាណឬ) ។ អើ ។ បុគ្គល កាលបើពោធិញាណ រលត់ហើយ ទៅប្រាសហើយ ស្ងប់រម្ងាប់ហើយ មិនឈ្មោះថាព្រះពុទ្ធទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៩៣) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញាណឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញាណជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៩៤) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញាណជាអតីតឬ ។ អើ ។ ព្រះពុទ្ធ ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៩៥) ព្រះពុទ្ធ ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញាណនោះឬ ។ អើ ។ ព្រះពុទ្ធ កំណត់ដឹងនូវទុក្ខសច្ច លះបង់នូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ដោយពោធិញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៩៦) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញាណឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញាណជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៩៧] អនាគតាយ ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩៨] តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩៩] បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ អតីតាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៥០០] បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ទុក្ខំ បរិជានាតិ សមុទយំ បជហាតិ និរោធំ សច្ឆិករោតិ មគ្គំ ភាវេតីតិ ។ អាមន្តា ។ អតីតាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៩៧) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត ឬ ។ អើ ។ ព្រះពុទ្ធ ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៩៨) ព្រះពុទ្ធ ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ ព្រះពុទ្ធ កំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៩៩) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៥០០) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន កំណត់ដឹងនូវទុក្ខសច្ច លះបង់នូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត កំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## ពោធិយា ពុទ្ធោតិកថា

(៨០១) បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ អនាគតាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៨០២) បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ទុក្ខំ បរិជានាតិ ។បេ។ មគ្គំ ភាវេតីតិ ។ អាមន្តា ។ អនាគតាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ទុក្ខំ បរិជានាតិ ។បេ។ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៨០៣) អតីតាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៨០៤) អតីតាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ទុក្ខំ បរិជានាតិ ។បេ។ មគ្គំ ភាវេតីតិ ។ អាមន្តា ។ បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ទុក្ខំ បរិជានាតិ ។បេ។ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

ពោធិយា ពុទ្ធោតិកថា

ទុក្ខសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយោ សង្ខតោតិ ។ អាមន្តា ។ សមុទយសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា សង្ខតាតិ ។ អាមន្តា ។ សមុទយសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មគ្គោ សង្ខតោតិ ។ អាមន្តា ។ មគ្គសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ សង្ខតោតិ ។ អាមន្តា ។ មគ្គសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦២៨) និរោធសច្ចំ អសង្ខតំ និរោធោ អសង្ខតោតិ ។ អាមន្តា ។ ទុក្ខសច្ចំ អសង្ខតំ ទុក្ខំ អសង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ និរោធសច្ចំ អសង្ខតំ និរោធោ អសង្ខតោតិ ។ អាមន្តា ។ សមុទយសច្ចំ អសង្ខតំ សមុទយោ អសង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ និរោធសច្ចំ អសង្ខតំ និរោធោ អសង្ខតោតិ ។ អាមន្តា ។ មគ្គសច្ចំ អសង្ខតំ មគ្គោ អសង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ទុក្ខសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សមុទយៈ ជាសង្ខតៈឬ ។ អើ ។ សមុទយសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ជាសង្ខតៈឬ ។ អើ ។ សមុទយសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មគ្គ ជាសង្ខតៈឬ ។ អើ ។ មគ្គសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ជាសង្ខតៈឬ ។ អើ ។ មគ្គសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៤៨) និរោធសច្ច ជាអសង្ខតៈ និរោធ ជាអសង្ខតៈដែរឬ ។ អើ ។ ទុក្ខសច្ច ជាអសង្ខតៈ ទុក្ខ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាអសង្ខតៈដែរឬ ។ អើ ។ សមុទយសច្ច ជាអសង្ខតៈ សមុទយៈ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាអសង្ខតៈដែរឬ ។ អើ ។ មគ្គសច្ច ជាអសង្ខតៈ មគ្គ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៤៩) ទុក្ខសច្ចំ អសង្ខតំ ទុក្ខំ សង្ខតន្តិ ។ អាមន្តា ។ និរោធសច្ចំ អសង្ខតំ និរោធោ សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយសច្ចំ អសង្ខតំ សមុទយោ សង្ខតោតិ ។ អាមន្តា ។ និរោធសច្ចំ អសង្ខតំ និរោធោ សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មគ្គសច្ចំ អសង្ខតំ មគ្គោ សង្ខតោតិ ។ អាមន្តា ។ និរោធសច្ចំ អសង្ខតំ និរោធោ សង្ខតោ-តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៥០) ន វត្តព្វំ ចត្តារិ សច្ចានិ អសង្ខតា-នីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ចត្តារិមានិ ភិក្ខវេ តថានិ អវិតថានិ អនញ្ញថានិ ។ កតមានិ ចត្តារិ ។ ឥទំ ទុក្ខន្តិ ភិក្ខវេ តថមេតំ អវិតថមេតំ អនញ្ញថមេតំ ។ បេ ។ អយំ ទុក្ខសមុទយោតិ ។ បេ ។ អយំ ទុក្ខនិរោធោតិ ។ បេ ។ អយំ ទុក្ខនិរោធគា-មិនី បដិបទាតិ តថមេតំ អវិតថមេតំ អនញ្ញថមេតំ ឥមានិ ខោ ភិក្ខវេ ចត្តារិ តថានិ អវិតថានិ អនញ្ញ-ថានីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ចត្តារិ សច្ចានិ អសង្ខតានីតិ ។

សច្ចកថា ។

[ ៦៤៩ ] ទុក្ខសច្ច ជាអសង្ខតៈ ទុក្ខ ជាសង្ខតៈដែរឬ ។ អើ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សមុទយសច្ច ជាអសង្ខតៈ សមុទយៈ ជាសង្ខតៈដែរឬ ។ អើ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មគ្គសច្ច ជាអសង្ខតៈ មគ្គ ជាសង្ខតៈដែរឬ ។ អើ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៦៥០ ] បុគ្គលមិនគួរនិយាយថា សច្ចៈទាំង ៤ ជាអសង្ខតៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីពិត សេចក្តីមិនឃ្លៀងឃ្លាត សេចក្តីមិនប្រែប្រួល នោះ មាន ៤ យ៉ាង ។ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិត សេចក្តីមិនឃ្លៀងឃ្លាត សេចក្តីមិនប្រែប្រួលថា នេះ ជាទុក្ខ ១ ។ បេ ។ ថា នេះ ជាទុក្ខសមុទយៈ ១ ។ បេ ។ ថា នេះ ជាទុក្ខនិរោធ ១ ។ បេ ។ សេចក្តីពិត សេចក្តីមិនឃ្លៀងឃ្លាត សេចក្តីមិនប្រែប្រួលថា នេះ ជាទុក្ខនិរោធគាមិនីបដិបទា ១ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិត សេចក្តីមិនឃ្លៀងឃ្លាត សេចក្តីមិនប្រែប្រួល មាន ៤ យ៉ាង នេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សច្ចៈទាំង ៤ ជាអសង្ខតៈ ។

ចប់ សច្ចកថា ។

# អារុប្បកថា

[ ៦៨១ ] អាកាសានញ្ចាយតនំ អសង្ខតន្តិ ។ អាមន្តា ។ និព្វានំ តាណំ លេណំ សរណំ បរាយណំ អច្ចុតំ អមតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អាកាសានញ្ចាយតនំ អសង្ខតំ និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។ បេ ។ អន្តរិកា វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អាកាសានញ្ចាយតនំ អសង្ខតន្តិ ។ អាមន្តា ។ អាកាសានញ្ចាយតនំ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ អសង្ខតំ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អាកាសានញ្ចាយតនូបគំ កម្មន្តិ ។ អាមន្តា ។ អត្ថិ អសង្ខតូបគំ កម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អាកាសានញ្ចាយតនូបគា សត្តាតិ ។ អាមន្តា ។ អត្ថិ អសង្ខតូបគា សត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# អារុប្បកថា

( ៦៤១ ) អាកាសានញ្ចាយតនៈ ជាអសង្ខតឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រកកោន ជាទីការពារ ជាទីប្រព្រឹត្តទៅខាងមុខ ជាទីមិនច្យុត ជាទីមិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាកាសានញ្ចាយតនៈ ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មាន ២ ឬ ។ អើ ។ ទីពឹង មាន ២ ។បេ។ ការវិនាសទៅក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាកាសានញ្ចាយតនៈ ជាអសង្ខតៈឬ ។ អើ ។ អាកាសានញ្ចាយតនៈ គឺជាភព ជាគតិ ជាសត្តាវាសៈ ជាសំសារ ជាកំណើត ជាវិញ្ញាណដ្ឋិតិ ជាការបានចំពោះនូវអត្តភាពឬ ។ អើ ។ អសង្ខតៈ គឺជាភព ជាគតិ ជាសត្តាវាសៈ ជាសំសារ ជាកំណើត ជាវិញ្ញាណដ្ឋិតិ ជាការបានចំពោះនូវអត្តភាពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្ម ដែលចូលទៅកាន់អាកាសានញ្ចាយតនៈ មានឬ ។ អើ ។ កម្ម ដែលចូលទៅកាន់អសង្ខតៈ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វដែលចូលទៅកាន់អាកាសានញ្ចាយតនៈ មានឬ ។ អើ ។ ពួកសត្វដែលចូលទៅកាន់អសង្ខតៈ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៥២) អាកាសានញ្ចាយតនេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ អាមន្តា ។ អសង្ខតេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៥៣) អាកាសានញ្ចាយតនេ អត្ថិ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ អាមន្តា ។ អសង្ខតេ អត្ថិ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អាកាសានញ្ចាយតនំ ចតុវោការភវោតិ ។ អាមន្តា ។ អសង្ខតំ ចតុវោការភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៥៤) ន វត្តព្វំ ចត្តារោ អារុប្បា អសង្ខតាតិ ។ អាមន្តា ។ ននុ ចត្តារោ អារុប្បា អនេញ្ជា វុត្តា ភគវតាតិ ។ អាមន្តា ។ ហញ្ចិ ចត្តារោ អារុប្បា អនេញ្ជា វុត្តា ភគវតា តេន វត រេ វត្តព្វេ ចត្តារោ អារុប្បា អសង្ខតាតិ ។

អារុប្បកថា ។

(៦៥២) ពួកសត្វ រមែងកើត ចាស់ ស្លាប់ ច្យុត កើតឡើង ក្នុងអាកាសានញ្ចាយតនៈឬ ។ អើ ។ ពួកសត្វ រមែងកើត ចាស់ ស្លាប់ ច្យុត កើតឡើង ក្នុងអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៥៣) វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងអាកាសានញ្ចាយតនៈឬ ។ អើ ។ វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាកាសានញ្ចាយតនៈ គឺចតុវោការភពឬ ។ អើ ។ អសង្ខតៈ គឺចតុវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៥៤) បុគ្គលមិនគួរនិយាយថា អារុប្បៈ ៤ ជាអសង្ខតៈឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អារុប្បៈ ៤ ជាធម៌មិនញាប់ញ័រឬ ។ អើ ។ បើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អារុប្បៈ ៤ ជាធម៌មិនញាប់ញ័រ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អារុប្បៈ ៤ ជាអសង្ខតៈ ។

ចប់ អារុប្បកថា ។

# និរោធសមាបត្តិកថា

[៦៥៥] និរោធសមាបត្តិ អសង្ខតាតិ ។ អាមន្តា ។ និព្វានំ តាណំ លេណំ សរណំ បរាយណំ អច្ចុតំ អមតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ និរោធសមាបត្តិ អសង្ខតា និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។ បេ ។ អន្តរិកា វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ និរោធសមាបត្តិ អសង្ខតាតិ ។ អាមន្តា ។ អត្ថិ កេចិ និរោធំ សមាបជ្ជន្តិ បដិលភន្តិ ឧប្បាទេន្តិ សមុប្បាទេន្តិ ឧដ្ឋាបេន្តិ សមុដ្ឋាបេន្តិ និព្វត្តេន្តិ អភិនិព្វត្តេន្តិ ជនេន្តិ សញ្ជនេន្តីតិ ។ អាមន្តា ។ អត្ថិ កេចិ អសង្ខតំ សមាបជ្ជន្តិ បដិលភន្តិ ឧប្បាទេន្តិ សមុប្បាទេន្តិ ឧដ្ឋាបេន្តិ សមុដ្ឋាបេន្តិ និព្វត្តេន្តិ អភិនិព្វត្តេន្តិ ជនេន្តិ សញ្ជនេន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ និរោធា វោទានំ វុដ្ឋានំ បញ្ញាយតីតិ ។ អាមន្តា ។ អសង្ខតា វោទានំ វុដ្ឋានំ បញ្ញាយតីតិ ។ ន ហេវំ វត្តព្វេ

# និរោធសមាបត្តិកថា

( ៦៥៤ ) និរោធសមាបត្តិ ជាអសង្ខតៈឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រកកោន ជាទីការពារ ជាទីប្រព្រឹត្តទៅខាងមុខ ជាទីមិនច្យុត ជាទីមិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ និរោធសមាបត្តិ ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មាន ២ ឬ ។ អើ ។ ទីពឹង មាន ២ ។ បេ ។ ការវិនាសទៅក្ដីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ និរោធសមាបត្តិ ជាអសង្ខតៈឬ ។ អើ ។ មានបុគ្គលពួកខ្លះ ចូលកាន់និរោធ បានចំពោះនូវនិរោធ ញុំាងនិរោធ ឲ្យកើតឡើង ឲ្យកើតឡើងព្រម ឲ្យតាំងឡើង ឲ្យតាំងឡើងព្រម ឲ្យលូតឡើង ឲ្យលាស់ឡើង ឲ្យដុះឡើង ឲ្យដុះដាលឡើងឬ ។ អើ ។ មានបុគ្គលពួកខ្លះ ចូលកាន់អសង្ខតៈ បានចំពោះនូវអសង្ខតធម៌ ញុំាងអសង្ខតធម៌ ឲ្យកើតឡើង ឲ្យកើតឡើងព្រម ឲ្យតាំងឡើង ឲ្យតាំងឡើងព្រម ឲ្យលូតឡើង ឲ្យលាស់ឡើង ឲ្យដុះឡើង ឲ្យដុះដាលឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការចូលផង ការចេញ ព្រោះនិរោធ រមែងប្រាកដឬ ។ អើ ។ ការចូលផង ការចេញ ព្រោះអសង្ខតៈ រមែងប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ

។ បេ ។ និរោធំ សមាបជ្ជន្តស្ស បឋមំ និរុជ្ឈតិ វចីសង្ខារោ តតោ កាយសង្ខារោ តតោ ចិត្តសង្ខារោតិ ។ អាមន្តា ។ អសង្ខតំ សមាបជ្ជន្តស្ស បឋមំ និរុជ្ឈតិ វចីសង្ខារោ តតោ កាយសង្ខារោ តតោ ចិត្តសង្ខារោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ និរោធា វុដ្ឋហន្តស្ស បឋមំ ឧប្បជ្ជតិ ចិត្តសង្ខារោ តតោ កាយសង្ខារោ តតោ វចីសង្ខារោតិ ។ អាមន្តា ។ អសង្ខតា វុដ្ឋហន្តស្ស បឋមំ ឧប្បជ្ជតិ ចិត្តសង្ខារោ តតោ កាយសង្ខារោ តតោ វចីសង្ខារោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៤៦) និរោធា វុដ្ឋិតំ តយោ ផស្សា ផុសន្តិ សុញ្ញតោ ផស្សោ អនិមិត្តោ ផស្សោ អប្បណិហិតោ ផស្សោតិ ។ អាមន្តា ។ អសង្ខតា វុដ្ឋិតំ តយោ ផស្សា ផុសន្តិ សុញ្ញតោ ផស្សោ អនិមិត្តោ ផស្សោ អប្បណិហិតោ ផស្សោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

។ បេ ។ កាលបុគ្គលចូលកាន់និរោធ វចីសង្ខាររលត់មុន តទៅ ទើបកាយសង្ខាររលត់ តទៅ ទើបចិត្តសង្ខាររលត់ឬ ។ អើ ។ កាលបុគ្គលចូលកាន់អសង្ខតៈ វចីសង្ខាររលត់មុន តទៅ ទើបកាយសង្ខាររលត់ តទៅ ទើបចិត្តសង្ខាររលត់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាលបុគ្គលចេញចាកនិរោធ ចិត្តសង្ខារកើតឡើងមុន តទៅ ទើបកាយសង្ខារកើត តទៅ ទើបវចីសង្ខារកើតឬ ។ អើ ។ កាល-បុគ្គលចេញចាកអសង្ខតៈ ចិត្តសង្ខារកើតឡើងមុន តទៅ ទើបកាយ-សង្ខារកើត តទៅ ទើបវចីសង្ខារកើតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៩៦) ផស្សៈ ៣ គឺ សុញ្ញតផស្សៈ ១ អនិមិត្តផស្សៈ ១ អប្បណិហិតផស្សៈ ១ រមែងពាល់ត្រូវ នូវបុគ្គលដែលចេញអំពីនិរោធឬ ។ អើ ។ ផស្សៈ ៣ គឺ សុញ្ញតផស្សៈ ១ អនិមិត្តផស្សៈ ១ អប្បណិហិត-ផស្សៈ ១ រមែងពាល់ត្រូវ នូវបុគ្គលដែលចេញអំពីអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៦៥៧ ] និរោធា វុដ្ឋិតស្ស វិវេកនិន្នំ ចិត្តំ ហោតិ វិវេកបោណំ វិវេកបព្ភារន្តិ ។ អាមន្តា ។ អសង្ខតា វុដ្ឋិតស្ស វិវេកនិន្នំ ចិត្តំ ហោតិ វិវេកបោណំ វិវេកបព្ភារន្តិ ។ ន ហេវំ វត្តព្វេ ។បេ ។

[ ៦៥៨ ] ន វត្តព្វំ និរោធសមាបត្តិ អសង្ខតាតិ ។ អាមន្តា ។ អសង្ខតាតិ ។ ន ហេវំ វត្តព្វេ ។បេ ។ តេន ហិ និរោធសមាបត្តិ អសង្ខតាតិ ។

**និរោធសមាបត្តិកថា ។**

## អាកាសកថា

[ ៦៥៩ ] អាកាសោ អសង្ខតោតិ ។ អាមន្តា ។ និព្វានំ តាណំ លេណំ សរណំ បរាយណំ អច្ចុតំ អមតន្តិ ។ ន ហេវំ វត្តព្វេ ។បេ ។

[ ៦៦០ ] អាកាសោ អសង្ខតោ និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។បេ ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។បេ ។ អន្តរិកា វាតិ ។ ន ហេវំ វត្តព្វេ ។បេ ។

( ៦៥៧ ) ចិត្ត របស់បុគ្គលដែលចេញអំពីនិរោធ នុនទៅកាន់វិវេក ឈមទៅកាន់វិវេក ផ្ទាកទៅកាន់វិវេកដែរឬ ។ អើ ។ ចិត្ត របស់បុគ្គលដែលចេញអំពីអសង្ខត: នុនទៅកាន់វិវេក ឈមទៅកាន់វិវេក ផ្ទាកទៅកាន់វិវេកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៥៨ ) បុគ្គលមិនគួរនិយាយថា និរោធសមាបត្តិ ជាអសង្ខត:ទេឬ ។ អើ ។ និរោធសមាបត្តិ ជាអសង្ខត:ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ និរោធសមាបត្តិ ជាអសង្ខត: ។

ចប់ និរោធសមាបត្តិកថា ។

# អាកាសកថា

( ៦៥៩ ) អាកាស ជាអសង្ខត:ឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រកកោន ជាទីការពារ ជាទីប្រព្រឹត្តទៅខាងមុខ ជាទីមិនច្យុត ជាទីមិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៦០ ) អាកាស ជាអសង្ខត: ចុះនិព្វាន ជាអសង្ខត:ដែរឬ ។ អើ ។ អសង្ខត: មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខត: មាន ២ ឬ ។ អើ ។ ទីពឹង មាន ២ ។ បេ ។ ការវិនាស ទៅក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៦១] អាកាសោ អសង្ខតោតិ ។ អាមន្តា ។ អត្ថិ កោចិ អនាកាសំ អាកាសំ ករោន្តីតិ ។ អាមន្តា ។ អត្ថិ កោចិ សង្ខតំ អសង្ខតំ ករោន្តីតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៦៦២] អត្ថិ កោចិ អាកាសំ អនាកាសំ ករោន្តីតិ ។ អាមន្តា ។ អត្ថិ កោចិ អសង្ខតំ សង្ខតំ ករោន្តីតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៦៦៣] អាកាសេ បក្ខិនោ គច្ឆន្តិ ចន្ទិមសុរិយោ គច្ឆន្តិ តារករូបានិ គច្ឆន្តិ ឥទ្ធី វិកុព្វន្តិ ពាហុំ ចាលេន្តិ ហត្ថំ ចាលេន្តិ លេឌ្ឌុំ ខិបន្តិ លគុឡំ ខិបន្តិ ឥទ្ធី ខិបន្តិ ឧសុំ ខិបន្តីតិ ។ អាមន្តា ។ អសង្ខតេ បក្ខិនោ គច្ឆន្តិ ចន្ទិមសុរិយា គច្ឆន្តិ តារករូបានិ គច្ឆន្តិ ឥទ្ធី វិកុព្វន្តិ ពាហុំ ចាលេន្តិ ហត្ថំ ចាលេន្តិ លេឌ្ឌុំ ខិបន្តិ លគុឡំ ខិបន្តិ ឥទ្ធី ខិបន្តិ ឧសុំ ខិបន្តីតិ ។ ន ហេវំ វត្តព្វេ ។បេ។

( ៦៦១ ) អាកាស ជាអសង្ខតៈឬ ។ អើ ។ មាន បុគ្គលពួកខ្លះ ធ្វើនូវទីមិនមែនជាអាកាស ឲ្យជាអាកាសឬ ។ អើ ។ មាន បុគ្គលពួកខ្លះ ធ្វើនូវសង្ខតៈ ឲ្យជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៦២ ) មាន បុគ្គលពួកខ្លះ ធ្វើនូវអាកាស ឲ្យទៅជាមិនមែនអាកាសឬ ។ អើ ។ មាន បុគ្គលពួកខ្លះ ធ្វើនូវអសង្ខតៈ ឲ្យជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៦៣ ) ពួកសត្វស្លាប តែងហើរទៅ ព្រះចន្ទ្រនិងព្រះអាទិត្យ តែងចរទៅ ពួកផ្កាយ តែងចរទៅ ពួកជន តែងសម្តែងឫទ្ធិ តែងញុំាងដើមដៃឲ្យកម្រើក ញុំាងបាតដៃឲ្យកម្រើក បោះដុំដី បោះដំបង បោះឫទ្ធិ បោះកូនសរ ទៅក្នុងអាកាសបានឬ ។ អើ ។ ពួកសត្វស្លាប តែងហើរទៅ ព្រះចន្ទ្រនិងព្រះអាទិត្យ តែងចរទៅ ពួកផ្កាយ តែងចរទៅ ពួកជន តែងសម្តែងឫទ្ធិ តែងញុំាងដើមដៃឲ្យកម្រើក ញុំាងបាតដៃឲ្យកម្រើក បោះដុំដី បោះដំបង បោះឫទ្ធិ បោះកូនសរ ទៅក្នុងអសង្ខតៈបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## អាកាសកថា

( ៦៦៤ ) អាកាសំ បរិវារេត្វា ឃរានិ ករោន្តិ កោដ្ឋានិ ករោន្តីតិ ។ អាមន្តា ។ អសង្ខតំ បរិវារេត្វា ឃរានិ ករោន្តិ កោដ្ឋានិ ករោន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៦៦៥ ) ឧទបានេ ខញ្ញមានេ អនាកាសោ អាកាសោ ហោតីតិ ។ អាមន្តា ។ សង្ខតំ អសង្ខតំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៦៦៦ ) តុច្ឆឧទបានេ បូរិយមានេ តុច្ឆកោដ្ឋេ បូរិយមានេ តុច្ឆកុម្ភិយា បូរិយមានាយ អាកាសោ អន្តរធាយតីតិ ។ អាមន្តា ។ អសង្ខតំ អន្តរធាយតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៦៦៧ ) ន វត្តព្វំ អាកាសោ អសង្ខតោតិ ។ អាមន្តា ។ អាកាសោ សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ អាកាសោ អសង្ខតោតិ ។

អាកាសកថា ។

## អាកាសកថា

( ៦៦៤ ) ពួកជន បិទបាំងនូវអាកាស ហើយធ្វើផ្ទះទាំងឡាយ ធ្វើជង្រុកទាំងឡាយបានឬ ។ អើ ។ ពួកជន បិទបាំង នូវអសង្ខតៈ ហើយធ្វើផ្ទះទាំងឡាយ ធ្វើជង្រុកទាំងឡាយបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៦៥ ) កាលអណ្តូង ដែលគេជីក អាកាស ទៅជាមិនមែនអាកាសឬ ។ អើ ។ សង្ខតៈ ទៅជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៦៦ ) កាលអណ្តូងទទេ ដែលគេដាក់ទឹកពេញ កាលជង្រុកទទេ ដែលគេដាក់ស្រូវពេញ កាលក្អមទទេ ដែលគេដាក់ទឹកពេញ អាកាស រមែងបាត់ឬ ។ អើ ។ អសង្ខតៈ រមែងបាត់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៦៧ ) បុគ្គលមិនគួរនិយាយថា អាកាស ជាអសង្ខតៈឬ ។ អើ ។ អាកាស ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ អាកាស ជាអសង្ខតៈ ។

ចប់ អាកាសកថា ។

## អាកាសោ សនិទស្សនោតិកបាឋ

(៦៦៨) អាកាសោ សនិទស្សនោតិ ។ អាមន្តា ។ រូបំ រូបាយតនំ រូបធាតុ នីលំ បីតកំ លោហិតកំ ឱទាតំ ចក្ខុវិញ្ញេយ្យំ ចក្ខុស្មឹ បដិហញ្ញតិ ចក្ខុស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៩) អាកាសោ សនិទស្សនោតិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច អាកាសញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៧០) ចក្ខុញ្ច បដិច្ច អាកាសញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច អាកាសញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ តេន វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច អាកាសញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

# អាកាសសនិទស្សនោតិកថា

(៦៦៨) អាកាស ជាសនិទស្សនៈ (ប្រកបដោយការមើលឃើញ) ឬ ។ អើ ។ រូប រូបាយតនៈ រូបធាតុ ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ដែលបុគ្គលគប្បីដឹងបានដោយចក្ខុ រមែងប៉ះពាល់ក្នុងចក្ខុ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៦៩) អាកាស ជាសនិទស្សនៈឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៧០) ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផងឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុ-វិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផងទេ ។

(៦៧១) ន វត្តព្វំ អាកាសោ សនិទស្សនោតិ ។ អាមន្តា ។ ននុ បស្សសិ ទ្វិន្នំ រុក្ខានំ អន្តរំ ទ្វិន្នំ ថម្ភានំ អន្តរំ តាឡច្ឆិទ្ទំ វាតបានច្ឆិទ្ទន្តិ ។ អាមន្តា ។ ហញ្ចិ បស្សសិ ទ្វិន្នំ រុក្ខានំ អន្តរំ ទ្វិន្នំ ថម្ភានំ អន្តរំ តាឡច្ឆិទ្ទំ វាតបានច្ឆិទ្ទំ តេន វត រេ វត្តព្វេ អាកាសោ សនិទស្សនោតិ ។

អាកាសោ សនិទស្សនោតិកថា ។

## បឋវីធាតុ សនិទស្សនាត្យាទិកថា

(៦៧២) បឋវីធាតុ សនិទស្សនាតិ ។ អាមន្តា ។ រូបំ រូបាយតនំ រូបធាតុ នីលំ បីតកំ លោហិតកំ ឱទាតំ ចក្ខុវិញ្ញេយ្យំ ចក្ខុស្មឹ បដិហញ្ញតិ ចក្ខុស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៧៣) បឋវីធាតុ សនិទស្សនាតិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច បឋវីធាតុញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៧១) បុគ្គលមិនគួរនិយាយថា អាកាស ជាសនិទស្សនៈទេ ឬ ។ អើ ។ ក្រែងអ្នក ឃើញ នូវចន្លោះនៃដើមឈើពីរ នូវចន្លោះនៃសសរពីរ នូវប្រហោងនៃកូនសោ នូវប្រហោងនៃបង្អួចដែរឬ ។ អើ ។ បើអ្នក ឃើញ នូវចន្លោះនៃដើមឈើពីរ នូវចន្លោះនៃសសរពីរ នូវប្រហោងនៃកូនសោ នូវប្រហោងនៃបង្អួចដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាកាស ជាសនិទស្សនៈដែរ ។

ចប់ អាកាសសនិទស្សនោតិកថា ។

## បឋវីធាតុសនិទស្សនាត្យាទិកថា

(៦៧២) បឋវីធាតុ ជាសនិទស្សនៈឬ ។ អើ ។ រូប រូបា-យតនៈ រូបធាតុ ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ដែលបុគ្គលគប្បីដឹងបានដោយចក្ខុ រមែងប៉ះពាល់កងចក្ខុ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៧៣) បឋវីធាតុ ជាសនិទស្សនៈឬ ។ អើ ។ ចក្ខុ-វិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីធាតុផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៧៤ ) ចក្ខុញ្ច បដិច្ច បឋវីធាតុញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច បឋវីធាតុញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ នោ វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច បឋវីធាតុញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

( ៦៧៥ ) ន វត្តព្វំ បឋវីធាតុ សនិទស្សនាតិ ។ អាមន្តា ។ ននុ បស្សសិ ភូមឹ បាសាណំ បព្វតន្តិ ។ អាមន្តា ។ ហញ្ចិ បស្សសិ ភូមឹ បាសាណំ បព្វតំ តេន វត រេ វត្តព្វេ បឋវីធាតុ សនិទស្សនាតិ ។បេ។ ន វត្តព្វំ អាបោធាតុ សនិទស្សនាតិ ។ អាមន្តា ។ ននុ បស្សសិ ឧទកន្តិ ។ អាមន្តា ។ ហញ្ចិ បស្សសិ ឧទកំ តេន វត រេ វត្តព្វេ អាបោធាតុ សនិទស្សនាតិ ។បេ។ ន វត្តព្វំ តេជោធាតុ សនិទស្សនាតិ ។ អាមន្តា ។ ននុ បស្សសិ អគ្គឹ ជលន្តន្តិ ។ អាមន្តា ។

( ៦៧៨ ) ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីធាតុផងឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីធាតុផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីធាតុផងទេ ។

( ៦៧៩ ) បុគ្គលមិនគួរនិយាយថា បឋវីធាតុ ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នក ឃើញផែនដី ថ្ម ភ្នំ ដែរឬ ។ អើ ។ បើអ្នក ឃើញផែនដី ថ្ម ភ្នំដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បឋវីធាតុ ជាសនិទស្សនៈដែរ ។ បេ ។ បុគ្គលមិនគួរនិយាយថា អាបោធាតុ ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នក ឃើញទឹកដែរឬ ។ អើ ។ បើអ្នក ឃើញទឹកដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាបោធាតុ ជាសនិទស្សនៈដែរ ។ បេ ។ បុគ្គលមិនគួរនិយាយថា តេជោធាតុ ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នក ឃើញភ្លើងកំពុងឆេះដែរឬ ។ អើ ។

ហញ្ចិ បស្សសិ អគ្គឹ ជលន្តំ តេន វត រេ វត្តព្វេ តេជោធាតុ សនិទស្សនាតិ ។បេ។ ន វត្តព្វំ វាយោធាតុ សនិទស្សនាតិ ។ អាមន្តា ។ ននុ បស្សសិ វាតេន រុក្ខេ សញ្ចាលិយមានេតិ ។ អាមន្តា ។ ហញ្ចិ បស្សសិ វាតេន រុក្ខេ សញ្ចាលិយមានេ តេន វត រេ វត្តព្វេ វាយោធាតុ សនិទស្សនាតិ ។បេ។

បឋវីធាតុ សនិទស្សនាត្យាទិកថា ។

## ចក្ខុន្ទ្រិយំ សនិទស្សនន្តិអាទិកថា

( ៦៧៦ ) ចក្ខុន្ទ្រិយំ សនិទស្សនន្តិ ។ អាមន្តា ។ រូបំ រូបាយតនំ រូបធាតុ ។បេ។ ចក្ខុស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

( ៦៧៧ ) ចក្ខុន្ទ្រិយំ សនិទស្សនន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច ចក្ខុន្ទ្រិយញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

( ៦៧៨ ) ចក្ខុញ្ច បដិច្ច ចក្ខុន្ទ្រិយញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច ចក្ខុន្ទ្រិយញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។

បើអ្នក ឃើញភ្លើងកំពុងឆេះដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា តេជោធាតុ ជាសនិទស្សនៈដែរ ។ បេ ។ បុគ្គលមិនគួរនិយាយថា វាយោធាតុ ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នកឃើញដើមឈើ ដែលរញ្ជួយដោយខ្យល់ដែរឬ ។ អើ ។ បើអ្នកឃើញដើមឈើ ដែលរញ្ជួយដោយខ្យល់ដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វាយោធាតុ ជាសនិទស្សនៈដែរ ។ បេ ។

ចប់ បឋវីធាតុសនិទស្សនាត្យាទិកថា ។

## ចក្ខុន្ទ្រិយំ សនិទស្សនន្តិអាទិកថា

(៦៧៦) ចក្ខុន្ទ្រិយ ជាសនិទស្សនៈឬ ។ អើ ។ រូប រូបាយតនៈ រូបធាតុ ។ បេ ។ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៧៧) ចក្ខុន្ទ្រិយ ជាសនិទស្សនៈឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវចក្ខុន្ទ្រិយផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៧៨) ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវចក្ខុន្ទ្រិយផងឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវចក្ខុន្ទ្រិយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។

ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ តេន វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច ចក្ខុន្ទ្រិយញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

[៦៧៩] ន វត្តព្វំ បញ្ចិន្ទ្រិយានិ សនិទស្សនានីតិ ។ អាមន្តា ។ ននុ បស្សតិ ចក្ខុំ សោតំ ឃានំ ជិវ្ហំ កាយន្តិ ។ អាមន្តា ។ ហញ្ចិ បស្សតិ ចក្ខុំ សោតំ ឃានំ ជិវ្ហំ កាយំ តេន វត រេ វត្តព្វេ បញ្ចិន្ទ្រិយានិ សនិទស្សនានីតិ ។ បេ ។

ចក្ខុន្ទ្រិយំ សនិទស្សនន្តិអាទិកថា ។

## កាយកម្មំ សនិទស្សនន្តិកថា

[៦៨០] កាយកម្មំ សនិទស្សនន្តិ ។ អាមន្តា ។ រូបំ រូបាយតនំ រូបធាតុ នីលំ បីតកំ លោហិតកំ ឱទាតំ ចក្ខុវិញ្ញេយ្យំ ចក្ខុស្មឹ បដិហញ្ញតិ ចក្ខុស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាយកម្មំ សនិទស្សនន្តិ ។ អាមន្តា ។

ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវចក្ខុន្ទ្រិយផងទេ ។

( ៦៧៩ ) បុគ្គលមិនគួរនិយាយថា បញ្ចិន្ទ្រិយ ( ឥន្ទ្រិយ ៥ ) ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នក ឃើញភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយដែរឬ ។ អើ ។ បើអ្នកឃើញភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បញ្ចិន្ទ្រិយ ជាសនិទស្សនៈដែរ ។ បេ ។

ចប់ បញ្ចិន្ទ្រិយំ សនិទស្សនន្តិអាទិកថា ។

# កាយកម្មំ សនិទស្សនន្តិកថា

( ៦៨០ ) កាយកម្ម ជាសនិទស្សនៈឬ ។ អើ ។ រូប រូបាយតនៈ រូបធាតុ ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ដែលបុគ្គលគួរដឹងបានដោយចក្ខុ រមែងប៉ះពាល់ក្នុងចក្ខុ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាយកម្ម ជាសនិទស្សនៈឬ ។ អើ ។

ចក្ខុញ្ច បដិច្ច កាយកម្មញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចក្ខុញ្ច បដិច្ច កាយកម្មញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច កាយកម្មញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ ឆោ វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច កាយកម្មញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

(៦៨១) ន វត្តព្វំ កាយកម្មំ សនិទស្សនន្តិ ។ អាមន្តា ។ ននុ បស្សសិ អភិក្កមន្តំ បដិក្កមន្តំ អាលោកេន្តំ វិលោកេន្តំ សម្មិញ្ជេន្តំ បសារេន្តន្តិ ។ អាមន្តា ។ ហញ្ចិ បស្សសិ អភិក្កមន្តំ បដិក្កមន្តំ អាលោកេន្តំ វិលោកេន្តំ សម្មិញ្ជេន្តំ បសារេន្តំ តេន វត រេ វត្តព្វេ កាយកម្មំ សនិទស្សនន្តិ ។

កាយកម្មំ សនិទស្សនន្តិកថា ។

ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវកាយកម្មផង ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវកាយកម្មផងឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវកាយកម្មផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវកាយកម្មផងទេ ។

[ ៦៨១ ] បុគ្គលមិនគួរនិយាយថា កាយកម្ម ជាសនិទស្សនៈទេ ឬ ។ អើ ។ ក្រែងអ្នក ឃើញបុគ្គលដែលកំពុងដើរទៅមុខ ថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកមើលទៅទិសផ្សេងៗ បត់អវយវៈ លាអវយវៈដែរឬ ។ អើ ។ បើអ្នក ឃើញបុគ្គលដែលកំពុងដើរទៅមុខ ថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកមើលទៅទិសផ្សេងៗ បត់អវយវៈ លាអវយវៈដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កាយកម្ម ជាសនិទស្សនៈដែរ ។

ចប់ កាយកម្មំ សនិទស្សនត្តិកថា ។

បឋវីធាតុ សនិទស្សនាតិអាទី កថា

កាយកម្មំ សនិទស្សនន្តិ បរិយោសានកថា ។

ឆដ្ឋោ វគ្គោ ។

## តស្ស ឧទ្ទានំ

និយាមោ អសង្ខតោ បដិច្ចសមុប្បាទោ
អសង្ខតោ ចត្តារិ សច្ចានិ អសង្ខតានិ
ចត្តារោ អារុប្បា អសង្ខតា និរោធ-
សមាបត្តិ អសង្ខតា អាកាសោ អសង្ខតោ
អាកាសោ សនិទស្សនោ ចត្តារោ មហាភូតា
បញ្ចិន្ទ្រិយានិ តថេវ កាយកម្មន្តិ ។

---

និយាយពីបបរីធាតុសនិទស្សនៈជាដើម

និងកាយកម្មសនិទស្សនៈជាទីបំផុត ។

ចប់ ឆដ្ឋវគ្គ ។

## ឧទ្ទាន នៃឆដ្ឋវគ្គនោះ គឺ

និយាយអំពី និយាមៈ ជាអសង្ខតៈ ១ បដិច្ចសមុប្បាទ ជាអសង្ខតៈ ១ សច្ចៈទាំង ៤ ជាអសង្ខតៈ ១ អារុប្បៈ ៤ ជាអសង្ខតៈ ១ និរោធសមាបត្តិ ជាអសង្ខតៈ ១ អាកាស ជាអសង្ខតៈ ១ អាកាស ជាសនិទស្សនៈ ១ មហាភូតរូប ៤ ជាសនិទស្សនៈ ១ បញ្ចិន្ទ្រិយ ជាសនិទស្សនៈ ១ កាយកម្ម ជាសនិទស្សនៈ ១ ។

---

# សង្គហិតកថា

( ៦៨២ ) នត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សង្គហិតាតិ ។ អាមន្តា ។ ននុ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ គណនំ គច្ឆន្តិ ឧទ្ទេសំ គច្ឆន្តិ បរិយាបន្នាតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ គណនំ គច្ឆន្តិ ឧទ្ទេសំ គច្ឆន្តិ បរិយាបន្នា នោ វត រេ វត្តព្វេ នត្ថិ កេចិ ធម្មា កេកិចិ ធម្មេហិ សង្គហិតាតិ ។

( ៦៨៣ ) ចក្ខាយតនំ កតមក្ខន្ធគណនំ គច្ឆតីតិ ។ រូបក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ ចក្ខាយតនំ រូបក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ ចក្ខាយតនំ រូបក្ខន្ធេន សង្គហាហិតន្តិ ។ សោតាយតនំ ។បេ។ ឃានាយតនំ ។បេ។ ជិវ្ហាយតនំ ។បេ។ កាយាយតនំ កតមក្ខន្ធគណនំ គច្ឆតីតិ ។ រូបក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ កាយាយតនំ រូបក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ កាយាយតនំ រូបក្ខន្ធេន សង្គហិតន្តិ ។

# សង្គហិតកថា

( ៦៨២ ) ពួកធម៌ទីមួយ សង្គ្រោះ ដោយពួកធម៌ទីមួយ មិនមានទេ ឬ ។ អើ ។ ក្រែងពួកធម៌ទីមួយ ដល់នូវការរាប់ ដល់នូវឧទ្ទេស រាប់បញ្ចូល ដោយពួកធម៌ទីមួយ មានឬ ។ អើ ។ បើពួកធម៌ទីមួយ ដល់នូវការរាប់ ដល់នូវឧទ្ទេស រាប់បញ្ចូល ដោយពួកធម៌ទីមួយ មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ពួកធម៌ទីមួយ សង្គ្រោះ ដោយពួកធម៌ទីមួយ មិនមានទេ ។

( ៦៨៣ ) អាយតនៈគឺភ្នែក ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយរូបក្ខន្ធ ។ បើអាយតនៈគឺភ្នែក ដល់នូវការរាប់ ដោយរូបក្ខន្ធយ៉ាងនេះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាយតនៈគឺភ្នែក សង្គ្រោះ ដោយរូបក្ខន្ធ ។ អាយតនៈគឺត្រចៀក ។ បេ ។ អាយតនៈគឺច្រមុះ ។ បេ ។ អាយតនៈគឺអណ្តាត ។ បេ ។ អាយតនៈគឺកាយ ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយរូបក្ខន្ធ ។ បើអាយតនៈគឺកាយ ដល់នូវការរាប់ដោយរូបក្ខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាយតនៈគឺកាយ សង្គ្រោះ ដោយរូបក្ខន្ធ ។

[ ២៨៤ ] រូបាយតនំ ។ បេ ។ សទ្ទាយតនំ ។ បេ ។ គន្ធាយតនំ ។ បេ ។ រសាយតនំ ។ បេ ។ ផោដ្ឋព្វាយតនំ កតមក្ខន្ធគណនំ គច្ឆតីតិ ។ រូបក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ ផោដ្ឋព្វាយតនំ រូបក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ ផោដ្ឋព្វាយតនំ រូបក្ខន្ធេន សង្គហិតន្តិ ។

[ ២៨៥ ] សុខា វេទនា កតមក្ខន្ធគណនំ គច្ឆតីតិ ។ វេទនាក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ សុខា វេទនា វេទនាក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ សុខា វេទនា វេទនាក្ខន្ធេន សង្គហិតាតិ ។ ទុក្ខា វេទនា ។ បេ ។ អទុក្ខមសុខា វេទនា កតមក្ខន្ធគណនំ គច្ឆតីតិ ។ វេទនាក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ អទុក្ខមសុខា វេទនា វេទនាក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ អទុក្ខមសុខា វេទនា វេទនាក្ខន្ធេន សង្គហិតាតិ ។

[ ៦៨៤ ] អាយតនៈគឺរូប ។បេ។ អាយតន គឺសំឡេង ។បេ។ អាយតនៈគឺក្លិន ។បេ។ អាយតនៈគឺរស ។បេ។ អាយតនៈគឺសម្ផស្ស ដល់នូវការកប់ដោយខន្ធណា ។ ដល់នូវការកប់ដោយរូបក្ខន្ធ ។ បើអាយតនៈគឺសម្ផស្ស ដល់នូវការកប់ដោយរូបក្ខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាយតនៈគឺសម្ផស្ស សង្គ្រោះ ដោយរូបក្ខន្ធ ។

[ ៦៨៥ ] សុខវេទនា ដល់នូវការកប់ដោយខន្ធណា ។ ដល់នូវការកប់ដោយវេទនាខន្ធ ។ បើសុខវេទនា ដល់នូវការកប់ដោយវេទនា-ខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សុខវេទនា សង្គ្រោះ ដោយវេទនាខន្ធ ។ ទុក្ខវេទនា ។បេ។ អទុក្ខ-មសុខវេទនា ដល់នូវការកប់ដោយខន្ធណា ។ ដល់នូវការកប់ដោយវេទនាខន្ធ ។ បើអទុក្ខមសុខវេទនា ដល់នូវការកប់ដោយវេទនាខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អទុក្ខមសុខវេទនា សង្គ្រោះ ដោយវេទនាខន្ធ ។

សង្គហិតកថា

[ ៦៨៦ ] ចក្ខុសម្ផស្សជា សញ្ញា កតមក្ខន្ធគណនំ គច្ឆតីតិ ។ សញ្ញាក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ ចក្ខុសម្ផស្សជា សញ្ញា សញ្ញាក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ ចក្ខុសម្ផស្សជា សញ្ញា សញ្ញាក្ខន្ធេន សង្គហិតាតិ ។ សោតសម្ផស្សជា សញ្ញា ។ បេ ។ មនោសម្ផស្សជា សញ្ញា កតមក្ខន្ធគណនំ គច្ឆតីតិ ។ សញ្ញាក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ មនោសម្ផស្សជា សញ្ញា សញ្ញាក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ មនោសម្ផស្សជា សញ្ញា សញ្ញាក្ខន្ធេន សង្គហិតាតិ ។

[ ៦៨៧ ] ចក្ខុសម្ផស្សជា ចេតនា ។ បេ ។ មនោសម្ផស្សជា ចេតនា កតមក្ខន្ធគណនំ គច្ឆតីតិ ។ សង្ខារក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ មនោសម្ផស្សជា ចេតនា សង្ខារក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ មនោសម្ផស្សជា ចេតនា សង្ខារក្ខន្ធេន សង្គហិតាតិ ។

សង្គហិតកថា

( ៦៨៦ ) សញ្ញា កើតអំពីចក្ខុសម្ផ័ស្ស ដល់នូវការរាប់ដោយខន្ធណា ៗ ដល់នូវការរាប់ដោយសញ្ញាខន្ធ ៗ បើសញ្ញា កើតអំពីចក្ខុ-សម្ផ័ស្ស ដល់នូវការរាប់ដោយសញ្ញាខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សញ្ញា កើតអំពីចក្ខុសម្ផ័ស្ស សង្គ្រោះ ដោយសញ្ញាខន្ធ ៗ សញ្ញា កើតអំពីសោតសម្ផ័ស្ស ។ បេ ។ សញ្ញា កើតអំពីមនោសម្ផ័ស្ស ដល់នូវការរាប់ដោយខន្ធណា ៗ ដល់នូវការរាប់ដោយសញ្ញាខន្ធ ៗ បើសញ្ញា កើតអំពីមនោសម្ផ័ស្ស ដល់នូវការរាប់ដោយសញ្ញាខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សញ្ញា កើតអំពីមនោសម្ផ័ស្ស សង្គ្រោះដោយសញ្ញាខន្ធ ៗ

( ៦៨៧ ) ចេតនា កើតអំពីចក្ខុសម្ផ័ស្ស ។ បេ ។ ចេតនា កើតអំពីមនោសម្ផ័ស្ស ដល់នូវការរាប់ដោយខន្ធណា ៗ ដល់នូវការរាប់ដោយសង្ខារក្ខន្ធ ៗ បើចេតនា កើតអំពីមនោសម្ផ័ស្ស ដល់នូវការរាប់ដោយសង្ខារក្ខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន អ្នកគួរពោលថា ចេតនា កើតអំពីមនោសម្ផ័ស្ស សង្គ្រោះ ដោយសង្ខារក្ខន្ធ ៗ

(៦៨៨) ចក្ខុវិញ្ញាណំ ។បេ។ មនោវិញ្ញាណំ កតមក្ខន្ធគណនំ គច្ឆតីតិ ។ វិញ្ញាណក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ មនោវិញ្ញាណំ វិញ្ញាណក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ មនោវិញ្ញាណំ វិញ្ញា-ណក្ខន្ធេន សង្គហិតន្តិ ។ យថា ទាមេន វា យោត្តេន វា ទ្វេ ពលិពទ្ទា សង្គហិតា សិក្កាយ បិណ្ឌបាតោ សង្គហិតោ សា គទ្ទុលេន សង្គហិតោ ឯវមេវ តេ ធម្មា តេហិ ធម្មេហិ សង្គហិតាតិ ។ ហញ្ចិ ទាមេន វា យោត្តេន វា ទ្វេ ពលិពទ្ទា សង្គហិតា សិក្កាយ បិណ្ឌបាតោ សង្គហិតោ សា គទ្ទុលេន សង្គហិតោ តេន វត រេ វត្តព្វេ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សង្គហិតាតិ ។

សង្គហិតកថា ។

# សម្បយុត្តកថា

(៦៨៩) អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សម្បយុត្តាតិ ។ អាមន្តា ។ ននុ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សហគតា សហជាតា សំសដ្ឋា

(៦៨៨) ចក្ខុវិញ្ញាណ ។បេ។ មនោវិញ្ញាណ ដល់នូវការរាប់ដោយខន្ធណា ៗ ដល់នូវការរាប់ដោយវិញ្ញាណក្ខន្ធ ៗ បើមនោវិញ្ញាណ ដល់នូវការរាប់ដោយវិញ្ញាណក្ខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា មនោវិញ្ញាណ សង្គ្រោះ ដោយវិញ្ញា-ណក្ខន្ធ ៗ គោបម្រើពីរ សង្គ្រោះ ដោយខ្សែទាម ឬដោយពួរ បិណ្ឌ-បាត សង្គ្រោះ (ដាក់បញ្ចូល) ក្នុងសង្រែក ឯសង្រែកនោះ សង្គ្រោះ ដោយឈើពុន យ៉ាងណា ធម៌ទាំងនោះ សង្គ្រោះ ដោយធម៌ទាំងនោះ ក៏យ៉ាងនោះដែរ ៗ បើគោបម្រើពីរ សង្គ្រោះ ដោយខ្សែទាម ឬដោយពួរ បិណ្ឌបាត សង្គ្រោះ (ដាក់បញ្ចូល) ក្នុងសង្រែក ឯសង្រែកនោះ សង្គ្រោះ ដោយឈើពុន (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ពួកធម៌ទីមួយ សង្គ្រោះ ដោយពួកធម៌ទីមួយ មានដែរ ៗ

ចប់ សង្គហិតកថា ។

# សម្បយុត្តកថា

(៦៨៩) ពួកធម៌ទីមួយ ប្រកបដោយពួកធម៌ទីមួយ មានឬ ៗ

អើ ៗ ក្រែងពួកធម៌ទីមួយ ប្រព្រឹត្តទៅមួយអន្លើ កើតមួយអន្លើ ប្រឡំព្រម

ឯកុប្បាទា ឯកនិរោធា ឯកវត្ថុកា ឯការម្មណាតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សហគតា សហជាតា សំសដ្ឋា ឯកុប្បាទា ឯក-និរោធា ឯកវត្ថុកា ឯការម្មណា នោ វត រេ វត្តព្វេ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សម្បយុត្តាតិ ។

[៦៩០] វេទនាក្ខន្ធោ សញ្ញាក្ខន្ធេន សហជា-តោតិ ។ អាមន្តា ។ ហញ្ចិ វេទនាក្ខន្ធោ សញ្ញាក្ខន្ធេន សហជាតោ តេន វត រេ វត្តព្វេ វេទនាក្ខន្ធោ សញ្ញា-ក្ខន្ធេន សម្បយុត្តោតិ ។ វេទនាក្ខន្ធោ សង្ខារក្ខន្ធេន វិញ្ញាណក្ខន្ធេន សហជាតោតិ ។ អាមន្តា ។ ហញ្ចិ វេទនាក្ខន្ធោ វិញ្ញាណក្ខន្ធេន សហជាតោ តេន វត រេ វត្តព្វេ វេទនាក្ខន្ធោ វិញ្ញាណក្ខន្ធេន សម្បយុត្តោតិ ។ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ វេទនា-ក្ខន្ធេន សញ្ញាក្ខន្ធេន សង្ខារក្ខន្ធេន សហជាតោតិ ។ អាមន្តា ។ ហញ្ចិ វិញ្ញាណក្ខន្ធោ សង្ខារក្ខន្ធេន សហជាតោ តេន វត រេ វត្តព្វេ វិញ្ញាណក្ខន្ធោ សង្ខារក្ខន្ធេន សម្បយុត្តោតិ ។ យថា តិលម្ហិ តេលំ អនុគតំ អនុបវិដ្ឋំ ឧច្ឆុម្ហិ រសោ អនុគតោ អនុបវិដ្ឋោ

កើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយពួកធម៌នីមួយឬ ។ អើ ។ បើពួកធម៌នីមួយ ប្រព្រឹត្តទៅជាមួយ កើតជាមួយ ប្រុំព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយពួកធម៌នីមួយ មាន (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ពួកធម៌នីមួយ ប្រកបដោយពួកធម៌នីមួយ មិនមានទេ ។

(៦៩០) វេទនាខន្ធ កើតជាមួយ នឹងសញ្ញាខន្ធឬ ។ អើ ។ បើវេទនាខន្ធ កើតជាមួយ នឹងសញ្ញាខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វេទនាខន្ធ ប្រកបដោយសញ្ញាខន្ធ (មាន) ។ វេទនាខន្ធ កើតជាមួយ នឹងសង្ខារក្ខន្ធ នឹងវិញ្ញាណក្ខន្ធឬ ។ អើ ។ បើវេទនាខន្ធ កើតជាមួយ នឹងវិញ្ញាណក្ខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វេទនាខន្ធ ប្រកបដោយវិញ្ញាណក្ខន្ធ (មាន) ។ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ កើតជាមួយ នឹងវេទនាខន្ធ នឹងសញ្ញាខន្ធ នឹងសង្ខារក្ខន្ធឬ ។ អើ ។ បើវិញ្ញាណក្ខន្ធ កើតជាមួយ នឹងសង្ខារក្ខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វិញ្ញាណក្ខន្ធ ប្រកបដោយសង្ខារក្ខន្ធ (មាន) ។ ប្រេងល្ង ឋិតនៅស៊ប់ ចូលទៅស៊ប់ ក្នុងគ្រាប់ល្ង រសអំពៅ ឋិតនៅស៊ប់ ចូលទៅស៊ប់ ក្នុងដើមអំពៅ យ៉ាងណា

ឯវមេវ តេ ធម្មា តេហិ ធម្មេហិ អនុគតា អនុបរិវត្តាតិ ។ ន ហេវំ វត្តព្វេ ។បេ។

សម្បយុត្តកថា ។

# ចេតសិកកថា

(៦៩១) នត្ថិ ចេតសិកោ ធម្មោតិ ។ អាមន្តា ។ ននុ អត្ថិ កេចិ ធម្មា ចិត្តេន សហគតា សហជាតា សំសដ្ឋា សម្បយុត្តា ឯកុប្បាទា ឯកនិរោធា ឯកវត្ថុកា ឯការម្មណាតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កេចិ ធម្មា ចិត្តេន សហគតា សហជាតា សំសដ្ឋា សម្បយុត្តា ឯកុប្បាទា ឯកនិរោធា ឯកវត្ថុកា ឯការម្មណា តេ វត រេ វត្តព្វេ នត្ថិ ចេតសិកោ ធម្មោតិ ។

(៦៩២) ផស្សោ ចិត្តេន សហជាតោតិ ។ អាមន្តា ។ ហញ្ចិ ផស្សោ ចិត្តេន សហជាតោ តេន វត រេ វត្តព្វេ ផស្សោ ចេតសិកោតិ ។ វេទនា ។បេ។ សញ្ញា ចេតនា ។បេ។ សទ្ធា វិរិយំ សតិ សមាធិ បញ្ញា រាគោ ទោសោ មោហោ ។បេ។ អនោត្តប្បំ ចិត្តេន សហជាតន្តិ ។ អាមន្តា ។

ធម៌ទាំងនោះ បិតនៅស៊ប់ ចូលទៅស៊ប់ ដោយធម៌ទាំងនោះ ក៏យ៉ាង នោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ សម្បយុត្តកថា ។

# ចេតសិកកថា

( ៦៩១ ) ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត មិនមានឬ ។ អើ ។ ក្រែង ពួកធម៌ទីមួយ ប្រព្រឹត្តទៅជាមួយ កើតជាមួយ ប្រឡំព្រម ប្រកបព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្ត មានដែរឬ ។ អើ ។ បើពួកធម៌ទីមួយ ប្រព្រឹត្តទៅជាមួយ កើតជាមួយ ប្រឡំព្រម ប្រកបព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្ត មាន ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត មិនមានទេ ។

( ៦៩២ ) ផស្សៈ កើតជាមួយនឹងចិត្តឬ ។ អើ ។ បើផស្សៈ កើតជាមួយនឹងចិត្ត ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ផស្សៈ ជាចេតសិក ។ វេទនា ។ បេ ។ សញ្ញា ចេតនា ។ បេ ។ សទ្ធា វីរិយៈ សតិ សមាធិ បញ្ញា រាគៈ ទោសៈ មោហៈ ។ បេ ។ អនោត្តប្បៈ កើតជាមួយនឹងចិត្តឬ ។ អើ ។

## ចេតសិកកថា

រិកំ អនោត្តប្បំ ចិត្តេន សហជាតំ តេន វត រេ វត្តព្វេ អនោត្តប្បំ ចេតសិកន្តិ ។ ចិត្តេន សហជាតាតិ កត្វា ចេតសិកាតិ ។ អាមន្តា ។ ផស្សេន សហជាតាតិ កត្វា ផស្សសិកាតិ ។ អាមន្តា ។ ចិត្តេន សហជាតាតិ កត្វា ចេតសិកាតិ ។ អាមន្តា ។ វេទនាយ ។ បេ ។ សញ្ញាយ ចេតនាយ សទ្ធាយ វីរិយេន សតិយា សមា-ធិនា បញ្ញាយ រាគេន ទោសេន មោហេន ។ បេ ។ អនោត្តប្បេន សហជាតាតិ កត្វា អនោត្តប្បសិកាតិ ។ អាមន្តា ។ នត្ថិ ចេតសិកោ ធម្មោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

ចិត្តមិទំ ចេតសិកា ច ធម្មា<br>
អនត្តតោ សំវិទិតស្ស ហោន្តិ<br>
ហីនប្បណីតំ តទុភយេ វិទិត្វា<br>
សម្មទ្ទសោ វេទិ បលោកធម្មន្តិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អត្ថិ ចេតសិកោ ធម្មោតិ ។

## ចេតសិកកថា

បើអនោត្តប្បៈ កើតជាមួយនឹងចិត្ត (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អនោត្តប្បៈ ជាចេតសិក ។ ពួកធម៌ ជាចេតសិក ព្រោះធ្វើសេចក្តីចូលចិត្តថា កើតជាមួយនឹងចិត្តឬ ។ អើ ។ ពួកធម៌ ប្រព្រឹត្តទៅក្នុងផស្សៈ ព្រោះធ្វើសេចក្តីចូលចិត្តថា កើតជាមួយនឹងផស្សៈឬ ។ អើ ។ ពួកធម៌ ជាចេតសិក ព្រោះធ្វើសេចក្តីចូលចិត្តថា កើតជាមួយនឹងចិត្តឬ ។ អើ ។ ពួកធម៌ នឹងវេទនា ។ បេ ។ នឹងសញ្ញា នឹងចេតនា នឹងសទ្ធា នឹងវីរិយៈ នឹងសតិ នឹងសមាធិ នឹងបញ្ញា នឹងរាគៈ នឹងទោសៈ នឹងមោហៈ ។ បេ ។ ពួកធម៌ ប្រព្រឹត្តទៅក្នុងអនោត្តប្បៈ ព្រោះធ្វើសេចក្តីចូលចិត្តថា កើតជាមួយនឹងអនោត្តប្បៈឬ ។ អើ ។ ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

> ចិត្តនេះក្តី ចេតសិកធម៌ទាំងឡាយក្តី របស់បុគ្គលដែលដឹងច្បាស់ ដោយអនត្តលក្ខណៈ កើតប្រាកដ បុគ្គលឃើញដោយប្រពៃ នូវធម៌ ដ៏ថោកទាបនឹងប្រសើរ ក៏ព្រោះដឹងច្បាស់ នូវធម៌ទាំងពីរនោះ ទើបទទួលលោកធម៌ (ធម៌ដែលបាក់បែកទ្រុឌទ្រោមទៅ)

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត មាន ។

( ៦៩៣ ) នត្ថិ ចេតសិកោ ធម្មោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥធ កេវដ្ដ ភិក្ខុ បរសត្តានំ បរបុគ្គលានំ ចិត្តម្បិ អាទិសតិ ចេតសិកម្បិ អាទិសតិ វិតក្កិតម្បិ អាទិសតិ វិចារិតម្បិ អាទិសតិ ឯវម្បិ តេ មនោ ឥត្ថម្បិ តេ មនោ ឥតិបិ តេ ចិត្តន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អត្ថិ ចេតសិកោ ធម្មោតិ ។

ចេតសិកកថា ។

## ញាណកថា

( ៦៩៤ ) ចេតសិកោ ធម្មោ ញាណន្តិ ។ អាមន្តា ។ លព្ភា ចេតសិកោ ធម្មោ បរេសំ ញាតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ លព្ភា ចេតសិកោ ធម្មោ បរេសំ ញាតុន្តិ ។ អាមន្តា ។ លព្ភា ផស្សោ បរេសំ ញាតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ លព្ភា វេទនា ។ បេ ។ សញ្ញា ចេតនា សទ្ធា វីរិយំ សតិ សមាធិ ។ បេ ។ បញ្ញា បរេសំ ញាតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៩៣) ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលកេវដ្ដៈ ភិក្ខុក្នុងធម្មវិន័យនេះ តែងចង្អុលបង្ហាញចិត្តផង ចង្អុលបង្ហាញធម៌ដែលប្រព្រឹត្តទៅក្នុងចិត្តផង ចង្អុលបង្ហាញធម៌ដែលខ្លួនត្រិះរិះហើយផង ចង្អុលបង្ហាញធម៌ដែលខ្លួនពិចារណាហើយផង ដល់ពួកសត្វដទៃ ដល់ពួកបុគ្គលដទៃថា ចិត្តរបស់អ្នក យ៉ាងនេះខ្លះ ចិត្តរបស់អ្នក មានប្រការយ៉ាងនេះខ្លះ ចិត្តរបស់អ្នក ដូច្នេះខ្លះ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត មាន ។

ចប់ ចេតសិកកថា ។

## ទានកថា

(៦៩៤) ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ជាទានឬ ។ អើ ។ ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ដែលបុគ្គលបាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។ បេ ។ ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ដែលបុគ្គល បាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អើ ។ ផស្សៈ ដែលបុគ្គលបាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ចេតនា សទ្ធា វីរិយៈ សតិ សមាធិ ។ បេ ។ បញ្ញា ដែលបុគ្គលបាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ទានកថា

( ៦៩៥ ) ន វត្តព្វំ ចេតសិកោ ធម្មោ ទានន្តិ ។ អាមន្តា ។ ទានំ អនិដ្ឋផលំ អកន្តផលំ អមនុញ្ញផលំ សេចនកផលំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ ននុ ទានំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកន្តិ ។ អាមន្តា ។ ហញ្ចិ ទានំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកំ តេន វត រេ វត្តព្វេ ចេតសិកោ ធម្មោ ទានន្តិ ។ ទានំ ឥដ្ឋផលំ វុត្តំ ភគវតា ចីវរំ ទានន្តិ ។ អាមន្តា ។ ចីវរំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ ទានំ ឥដ្ឋផលំ វុត្តំ ភគវតា បិណ្ឌបាតោ សេនាសនំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ ទានន្តិ ។ អាមន្តា ។ គិលានប្បច្ចយភេសជ្ជបរិក្ខារោ ឥដ្ឋផលោ កន្តផលោ មនុញ្ញផលោ អសេចនកផលោ សុខុទ្រយោ សុខវិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៦៩៨] បុគ្គលមិនគួរនិយាយថា ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ជាទានទេឬ ។ អើ ។ ទាន មានផលមិនជាទីប្រាថ្នា មានផលមិនជាទីត្រេកអរ មានផលមិនជាទីគាប់ចិត្ត មានផលប្រឡូកប្រឡំ ចម្រើនដោយទុក្ខ មានវិបាកជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងទាន មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អើ ។ បើទាន មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខ(យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ចាត់ជាទាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទាន មានផលជាទីប្រាថ្នា ចុះចីវរ ជាទានឬ ។ អើ ។ ចីវរ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទាន មានផលជាទីប្រាថ្នា ចុះបិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ចាត់ជាទានឬ ។ អើ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៩៦) ន វត្តព្វំ ចេតសិកោ ធម្មោ ទានន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

សទ្ធា ហិរិយំ កុសលញ្ច ទានំ
ធម្មា ឯតេ សប្បុរិសានុយាតា
ឯតំ ហិ មគ្គំ ទិវិយំ វទន្តិ
ឯតេន ហិ គច្ឆតិ ទេវលោកន្តិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ចេតសិកោ ធម្មោ ទានន្តិ ។

(៦៩៧) ន វត្តព្វំ ចេតសិកោ ធម្មោ ទានន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា បញ្ចិមានិ ភិក្ខវេ ទានានិ មហាទានានិ អគ្គញ្ញានិ រត្តញ្ញានិ វំសញ្ញានិ ពោរាណានិ អសង្កិណ្ណានិ អសង្កិណ្ណបុព្វានិ ន សង្កិយន្តិ ន សង្កិយិស្សន្តិ អប្បដិក្កុដ្ឋានិ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ កតមានិ បញ្ច ។ ឥធ ភិក្ខវេ អរិយសាវកោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ បាណាតិបាតា បដិវិរតោ ភិក្ខវេ អរិយសាវកោ អបរិមាណានំ សត្តានំ អភយំ ទេតិ អវេរំ ទេតិ អព្យាបជ្ឈំ ទេតិ

[៦៩៦] បុគ្គលមិនគួរនិយាយថា ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ជាទានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

សទ្ធា ហិរិ និងកុសល ហៅថាទាន ធម៌ទាំងនុ៎ះ ជាទីប្រព្រឹត្តទៅរឿយៗនៃសប្បុរស ព្រោះថា អ្នកប្រាជ្ញទាំងឡាយ តែងពោលនូវធម៌នុ៎ះ ថាជាផ្លូវគួរប្រាថ្នា ព្រោះបុគ្គល ទៅកាន់ទេវលោក ដោយផ្លូវនុ៎ះ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ចាត់ជាទាន ។

[៦៩៧] បុគ្គលមិនគួរនិយាយថា ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ចាត់ជាទានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទាន ៥ យ៉ាងនេះ ជាមហាទាន ដែលបណ្ឌិតដឹងថាជាទានប្រសើរ ដឹងថាមានមកអស់កាលយូរហើយ ដឹងថាជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិតមិនដែលលះបង់ មិនធ្លាប់លះបង់ តែងមិនលះបោល នឹងមិនលះបោល ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនបោះបង់បោលឡើយ ។ ទាន ទាំង ៥ យ៉ាងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ក្នុងសាសនានេះ ជាអ្នកលះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក វៀរស្រឡះចាកបាណាតិបាតហើយ ឈ្មោះថាឲ្យអភ័យ ឲ្យនូវការមិនមានពៀរ ឲ្យនូវសេចក្តីមិនព្យាបាទ ដល់សត្វទាំងឡាយមានប្រមាណមិនបាន

អបរិមាណានំ សត្តានំ អភយំ ទត្វា អវេរំ ទត្វា
អព្យាបជ្ឈំ ទត្វា អបរិមាណស្ស អភយស្ស អវេរស្ស
អព្យាបជ្ឈស្ស ភាគី ហោតិ ឥទំ ភិក្ខវេ បឋមំ
ទានំ មហាទានំ អគ្គញ្ញំ រត្តញ្ញំ វំសញ្ញំ បោរាណំ
អសង្កិណ្ណំ អសង្កិណ្ណបុព្វំ ន សង្កិយតិ ន សង្កិ-
យិស្សតិ អប្បដិក្កុដ្ឋំ សមណេហិ ព្រាហ្មណេហិ
វិញ្ញូហិ បុន ចបរំ ភិក្ខវេ អរិយសាវកោ អទិន្នាទានំ
បហាយ ។បេ។ កាមេសុ មិច្ឆាចារំ បហាយ ។បេ។
មុសាវាទំ បហាយ ។បេ។ សុរាមេរយមជ្ជប្បមា-
ទដ្ឋានំ បហាយ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិ-
វិរតោ ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ
ភិក្ខវេ អរិយសាវកោ អបរិមាណានំ សត្តានំ អភយំ
ទេតិ អវេរំ ទេតិ អព្យាបជ្ឈំ ទេតិ អបរិមាណានំ
សត្តានំ អភយំ ទត្វា អវេរំ ទត្វា អព្យាបជ្ឈំ ទត្វា

លុះឲ្យអភ័យ ឲ្យនូវការមិនមានពៀរ ឲ្យនូវសេចក្តីមិនព្យាបាទ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ រមែងជាអ្នកមានចំណែកដោយសេចក្តីមិនមានភ័យ មិនមានពៀរ មិនមានព្យាបាទ មានប្រមាណមិនបាន ម្នាលភិក្ខុទាំងឡាយ នេះ ជាទានទី ១ ជាមហាទាន ដែលបណ្ឌិតដឹងថាជាទានប្រសើរ ដឹងថាមានមកអស់ កាលយូរហើយ ដឹងថាជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិតមិនដែលលះបង់ មិនធ្លាប់លះបង់ រមែងមិនលះបោល ទាំងមិ លះបោល ដែលសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនបោះបង់បោលឡើយ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវ័ក លះបង់នូវអទិន្នាទាន ។ បេ ។ លះបង់នូវការប្រព្រឹត្តិខុស ក្នុងកាមទាំងឡាយ ។ បេ ។ លះបង់នូវមុសាវាទ ។ បេ ។ លះបង់នូវហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ជាអ្នកវៀរស្រឡះ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក វៀរស្រឡះ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យហើយ ឈ្មោះថា ឲ្យនូវអភ័យ ឲ្យនូវការមិនមានពៀរ ឲ្យនូវសេចក្តីមិនព្យាបាទ ដល់សត្វទាំងឡាយ មានប្រមាណមិនបាន លុះឲ្យនូវអភ័យ ឲ្យនូវការមិ មានពៀរ ឲ្យនូវសេចក្តីមិនព្យាបាទ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ

អបរិមាណស្ស អភយស្ស អវេរស្ស អព្យាបជ្ឈស្ស ភាគី ហោតិ ឥទំ ភិក្ខវេ បញ្ចមំ ទានំ មហាទានំ អគ្គញ្ញំ រត្តញ្ញំ វំសញ្ញំ បោរាណំ អសង្កិណ្ណំ អសង្កិណ្ណបុព្វំ ន សង្កិយតិ ន សង្កិយិស្សតិ អប្បដិក្កុដ្ឋំ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ឥមានិ ខោ ភិក្ខវេ បញ្ច ទានានិ មហាទានានិ អគ្គញ្ញានិ រត្តញ្ញានិ វំសញ្ញានិ បោរាណានិ អសង្កិណ្ណានិ អសង្កិណ្ណបុព្វានិ ន សង្កិយន្តិ ន សង្កិយិស្សន្តិ អប្បដិក្កុដ្ឋានិ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ចេតសិកោ ធម្មោ ទានន្តិ ។

( ៦៩៨ ) ន វត្តព្វំ ទេយ្យធម្មោ ទានន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥធេកច្ចោ អន្នំ ទេតិ បានំ ទេតិ វត្ថំ ទេតិ យានំ ទេតិ មាលំ ទេតិ គន្ធំ ទេតិ វិលេបនំ ទេតិ សេយ្យំ ទេតិ អាវសថំ ទេតិ បទីបេយ្យំ ទេតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ទេយ្យធម្មោ ទានន្តិ ។

រមែងជាអ្នកមានចំណែក ដោយការមិនមានភ័យ មិនមានពៀរ មិនមានព្យាបាទ មានប្រមាណមិនបាន ម្នាលភិក្ខុទាំងឡាយ នេះ ជាទានទី ៥ ជាមហាទាន ដែលបណ្ឌិតដឹងថាជាទានប្រសើរ ដឹងថាមានមកអស់កាលយូរហើយ ដឹងថាជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិត មិនដែលលះបង់ មិនធ្លាប់លះបង់ រមែងមិនលះបោល នឹងមិនលះបោល ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនបោះបង់បោលឡើយ ម្នាលភិក្ខុទាំងឡាយ ទាន ៥ យ៉ាងនេះឯង ជាមហាទាន ដែលបណ្ឌិត ដឹងថាជាទានប្រសើរ ដឹងថាមានមក អស់កាលយូរហើយ ដឹងថាជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិត មិនដែលលះបង់ មិនធ្លាប់លះបង់ រមែងមិនលះបោល នឹងមិនលះបោល ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនបោះបង់បោលឡើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ចាត់ជាទាន ។

( ៦៩៨ ) បុគ្គលមិនត្រូវនិយាយថា ទេយ្យធម៌ ជាទានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យបាយ ឲ្យទឹក ឲ្យសំពត់ ឲ្យយាន ឲ្យផ្កាកម្រង ឲ្យគ្រឿងក្រអូប ឲ្យគ្រឿងលាប ឲ្យទីដេក ឲ្យទីសំណាក់អាស្រ័យ ឲ្យគ្រឿងប្រទីប ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ទេយ្យធម៌ ចាត់ជាទាន ។

(៦៩៩) ទេយ្យធម្មោ ទានន្តិ ។ អាមន្តា ។ ទេយ្យធម្មោ ឥដ្ឋផលោ កន្តផលោ មនុញ្ញផលោ អសេចនកផលោ សុខុទ្រយោ សុខវិបាកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទានំ ឥដ្ឋផលំ វុត្តំ ភគវតា ចីវរំ ទានន្តិ ។ អាមន្តា ។ ចីវរំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទានំ ឥដ្ឋផលំ វុត្តំ ភគវតា បិណ្ឌបាតោ ទានំ សេនាសនំ ទានំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ ទានន្តិ ។ អាមន្តា ។ គិលានប្បច្ចយភេសជ្ជបរិក្ខារោ ឥដ្ឋផលោ កន្តផលោ មនុញ្ញផលោ អសេចនកផលោ សុខុទ្រយោ សុខវិបាកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ ន វត្តព្វំ ទេយ្យធម្មោ ទានន្តិ ។

ទានកថា ។

## បរិភោគមយបុញ្ញកថា

(៧០០) បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។

(៦៩៩) ទេយ្យធម៌ ឈ្មោះថាជាទានឬ ។ អើ ។ ទេយ្យធម៌ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទាន មានផលជាទីប្រាថ្នា (យ៉ាងនេះ) ចុះចីវរ ជាទានឬ ។ អើ ។ ចីវរ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទាន មានផលជាទីប្រាថ្នា (យ៉ាងនេះ) ចុះ បិណ្ឌបាត ជាទាន សេនាសនៈ ជាទាន គិលានប្បច្ច័យភេសជ្ជបរិក្ខារ ជាទានដែរឬ ។ អើ ។ គិលានប្បច្ច័យភេសជ្ជបរិក្ខារ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ទេយ្យធម៌ ជាទានទេ ។

ចប់ ទានកថា ។

## បរិភោគមយបុញ្ញកថា

(៧០០) បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។

បរិភោគមយោ ផស្សោ វឌ្ឍតិ វេទនា វឌ្ឍតិ សញ្ញា
វឌ្ឍតិ ចេតនា វឌ្ឍតិ ចិត្តំ វឌ្ឍតិ សទ្ធា វឌ្ឍតិ វីរិយំ
វឌ្ឍតិ សតិ វឌ្ឍតិ សមាធិ វឌ្ឍតិ បញ្ញា វឌ្ឍតីតិ ។
ន ហេវំ វត្តព្វេ ។ បេ ។

(៧០១) បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។
លតា វិយ វឌ្ឍតិ មាលុវា វិយ វឌ្ឍតិ រុក្ខោ វិយ
វឌ្ឍតិ តិណំ វិយ វឌ្ឍតិ មុញ្ជបុញ្ជោ វិយ វឌ្ឍតីតិ ។
ន ហេវំ វត្តព្វេ ។ បេ ។

(៧០២) បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។
ទាយកោ ទានំ ទត្វា ន សមន្នាហរតិ ហោតិ បុញ្ញន្តិ ។
អាមន្តា ។ អនាវជ្ជន្តស្ស ហោតិ អនាភោគស្ស ហោតិ
អសមន្នាហរន្តស្ស ហោតិ អមនសិករោន្តស្ស ហោតិ
អចេតយន្តស្ស ហោតិ អបត្ថយន្តស្ស ហោតិ អប្បណិ-
ទហន្តស្ស ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ
អាវជ្ជន្តស្ស ហោតិ អាភោគស្ស ហោតិ សមន្នាហរន្តស្ស
ហោតិ មនសិករោន្តស្ស ហោតិ ចេតយន្តស្ស
ហោតិ បត្ថយន្តស្ស ហោតិ បណិទហន្តស្ស ហោតីតិ ។

ផស្សៈ សម្រេចដោយការបរិភោគ តែងចម្រើន វេទនា តែងចម្រើន សញ្ញា តែងចម្រើន ចេតនា តែងចម្រើន ចិត្ត តែងចម្រើន សទ្ធា តែងចម្រើន វីរិយៈ តែងចម្រើន សតិ តែងចម្រើន សមាធិ តែងចម្រើន បញ្ញា តែងចម្រើនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧០១) បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ បុណ្យ តែងចម្រើន ដូចជាវល្លិ (ឡើងដើមឈើ) ចម្រើនដូចជាពួរជ្រៃ ចម្រើនដូចជាដើមឈើ ចម្រើនដូចជាស្មៅ ចម្រើនដូចជាបាច់នៃស្មៅយាប្លងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧០២) បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ ទាយក ឲ្យទាន មិនពិចារណាទេ បុណ្យ មានដែរឬ ។ អើ ។ បុណ្យ របស់បុគ្គល កាលមិននឹកនា មិនអើពើ មិនពិចារណា មិនធ្វើទុកក្នុងចិត្ត មិនគិត មិនប្រាថ្នា មិនតំកល់ចិត្តមាំ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងបុណ្យ របស់បុគ្គល កាលនឹក-នា អើពើ ពិចារណា ធ្វើទុកក្នុងចិត្ត គិត ប្រាថ្នា តំកល់ចិត្តមាំ មានឬ ។

អាមន្តា ។ ហញ្ចិ អាវជ្ជន្តស្ស ហោតិ អាភោគស្ស ហោតិ សមន្នាហរន្តស្ស ហោតិ មនសិការោន្តស្ស ហោតិ ចេតយន្តស្ស ហោតិ បត្ថយន្តស្ស ហោតិ បណិទហន្តស្ស ហោតិ នោ វត រេ វត្តព្វេ បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។

(៧០៣) បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។ ទាយកោ ទានំ ទត្វា កាមវិតក្កំ វិតក្កេតិ ព្យាបាទវិតក្កំ វិតក្កេតិ វិហឹសាវិតក្កំ វិតក្កេតិ ហោតិ បុញ្ញន្តិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ។បេ។ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ទ្វិន្នំ ផស្សានំ ។បេ។ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ អាមន្តា ។ កុសលាកុសលា សាវជ្ជានវជ្ជា ហីនប្បណីតា កណ្ហសុក្កសប្បដិភាគា ធម្មា សម្មុខីភាវំ អាគច្ឆន្តីតិ ។ ន ហេវំ វត្តព្វេ ។បេ។ កុសលាកុសលា សាវជ្ជានវជ្ជា ហីនប្បណីតា កណ្ហសុក្កសប្បដិភាគា ធម្មា សម្មុខីភាវំ អាគច្ឆន្តីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ចត្តារិមានិ ភិក្ខវេ សុវិទូរវិទូរានិ ។ កតមានិ ចត្តារិ ។ នភញ្ច ភិក្ខវេ បថវី ច

បរិភោគមយបុញ្ញកថា

អើ ។ បើបុណ្យ របស់បុគ្គល កាលទឹកនា អើពៅ ពិចារណា ធ្វើទុកក្នុងចិត្ត គិត ប្រាថ្នា តំកល់ចិត្តមាំ មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនទេ ។

(៧០៣) បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ ទាយក ឲ្យទាន ហើយត្រិះរិះនូវកាមវិតក្កៈ ត្រិះរិះនូវព្យាបាទវិតក្កៈ ត្រិះរិះនូវវិហឹសាវិតក្កៈ បុណ្យ មានដែរឬ ។ អើ ។ ការប្រជុំចុះ នៃផស្សៈទាំងពីរ ។បេ។ នៃចិត្តទាំងពីរ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការប្រជុំចុះ នៃផស្សៈទាំងពីរ ។បេ។ នៃចិត្តទាំងពីរ មានឬ ។ អើ ។ ពួកធម៌ ជាកុសលនិងអកុសល មានទោសនិងមិនមានទោស ថោកទាបនិងឧត្តម មានចំណែកខ្មៅនិងចំណែកស មកកាន់ភាវៈចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកធម៌ ជាកុសលនិងអកុសល មានទោសនិងមិនមានទោស ថោកទាបនិងឧត្តម មានចំណែកខ្មៅនិងចំណែកស មកកាន់ភាវៈចំពោះមុខឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មជាត ឆ្ងាយក្រៃលែងណាស់នេះ មាន ៤ យ៉ាង ។ ធម្មជាតឆ្ងាយក្រៃលែងណាស់ ទាំង ៤ នោះ តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មេឃនិងប្រឹថពី

ឥទំ បឋមំ សុវិទូរវិទូរំ ឱរិមញ្ច ភិក្ខវេ តីរំ សមុទ្ទស្ស បារិមញ្ច តីរំ ឥទំ ទុតិយំ សុវិទូរវិទូរំ យតោ ច ភិក្ខវេ វេរោចនោ អព្ភុទេតិ យត្ថ ច អត្ថមេតិ ឥទំ តតិយំ សុវិទូរវិទូរំ សតញ្ច ភិក្ខវេ ធម្មោ អសតញ្ច ធម្មោ ឥទំ ចតុត្ថំ សុវិទូរវិទូរំ ឥមានិ ខោ ភិក្ខវេ ចត្តារិ សុវិទូរ-វិទូរានីតិ

នភញ្ច ទូរេ បឋវី ច ទូរេ
បារំ សមុទ្ទស្ស តទាហុ ទូរេ
យតោ ច វេរោចនោ អព្ភុទេតិ
បភង្ករោ យត្ថ ច អត្ថមេតិ
តតោ ហវេ ទូរតរំ វទន្តិ
សតញ្ច ធម្មំ អសតញ្ច ធម្មំ
អព្យាយិកោ ហោតិ សតំ សមាគមោ
យាវម្បិ តិដ្ឋេយ្យ តថេវ ហោតិ
ខិប្បំ ហិ វេតិ អសតំ សមាគមោ
តស្មា សតំ ធម្មោ អសព្ភិ អារកាតិ

នេះ ជាធម្មជាតឆ្ងាយក្រៃលែងណាស់ទី ១ ម្នាលភិក្ខុទាំងឡាយ ត្រើយខាងអាយ និងត្រើយខាងនាយនៃសមុទ្រ នេះ ជាធម្មជាតឆ្ងាយក្រៃលែងណាស់ទី ២ ម្នាលភិក្ខុទាំងឡាយ ព្រះអាទិត្យ រះឡើងអំពីទីណា និងអស្តង្គតទៅក្នុងទីណា នេះ ជាធម្មជាតឆ្ងាយក្រៃលែងណាស់ទី ៣ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយរបស់ពួកសប្បុរស និងធម៌ទាំងឡាយរបស់ពួកអសប្បុរស នេះ ជាធម្មជាតឆ្ងាយក្រៃលែងណាស់ទី ៤ ម្នាលភិក្ខុទាំង-ឡាយ ធម្មជាតឆ្ងាយក្រៃងលែងណាស់ មាន ៤ យ៉ាងនេះឯង

ពពក (ឋិតនៅក្នុងទីឆ្ងាយ) ប្រឹថពី (ក៏ឋិតនៅ) ក្នុងទីឆ្ងាយពីគ្នា (អ្នកប្រាជ្ញ ពោល) នូវត្រើយសមុទ្រនោះ ថាឆ្ងាយ ព្រះអាទិត្យ រះឡើងអំពីទីណា ព្រះអាទិត្យ អស្តង្គតទៅក្នុងទីណា អ្នកប្រាជ្ញ ពោលនូវទីនោះ ថាជាទីឆ្ងាយក្រៃលែងអំពីទីនោះពិត បុគ្គលអ្នកសំដែង នូវធម៌របស់ពួកសប្បុរស និងធម៌របស់ពួកអសប្បុរស រមែងមាន សមាគម របស់សប្បុរសទាំងឡាយ ឋិតនៅដរាបណា (បុគ្គលអ្នកសំដែង) ក៏រមែងមាន ដរាបនោះ សមាគម របស់អសប្បុរសទាំងឡាយ រមែងសាបសូន្យទៅឆាប់រហ័ស ព្រោះហេតុនោះ ធម៌របស់សប្បុរសទាំងឡាយ ឆ្ងាយអំពីអសប្បុរសទាំងឡាយ

## បរិភោគមយបុញ្ញកថា

អត្ថិ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ កុសលាកុសលា សាវជ្ជានវជ្ជា ហីនប្បណីតា កណ្ហ-សុក្កសប្បដិភាគា ធម្មា សម្មុខីភាវំ អាគច្ឆន្តីតិ ។

(៧០៤) ន វត្តព្វំ បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

អារាមរោបា វនរោបា　　យេ ជនា សេតុការកា
បបញ្ច ឧទបានញ្ច　　យេ ទទន្តិ ឧបស្សយំ
តេសំ ទិវា ច រត្តោ ច　　សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា　　តេ ជនា សគ្គគាមិនោតិ

អត្ថិ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ បរិភោគ-មយំ បុញ្ញំ វឌ្ឍតីតិ ។

## បរិភោគមយបុញ្ញកថា

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គល មិនគួរនិយាយថា ពួកធម៌ ជាកុសលនិងអកុសល មានទោសនិងមិនមានទោស ថោកទាបនិងឧត្តម មានចំណែកខ្មៅនិងចំណែកស មកកាន់ការៈចំពោះមុខទេ ។

( ៨៩៤ ) ញាណំ អនារម្មណន្តិ ។ អាមន្តា ។ កតមក្ខន្ធបរិយាបន្នន្តិ ។ សង្ខារក្ខន្ធបរិយាបន្នន្តិ ។ សង្ខារក្ខន្ធោ អនារម្មណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សង្ខារក្ខន្ធោ អនារម្មណោតិ ។ អាមន្តា ។ វេទនាខន្ធោ សញ្ញាខន្ធោ វិញ្ញាណក្ខន្ធោ អនារម្មណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៨៩៥ ) ញាណំ សង្ខារក្ខន្ធបរិយាបន្នំ អនារម្មណន្តិ ។ អាមន្តា ។ បញ្ញា សង្ខារក្ខន្ធបរិយាបន្នា អនារម្មណាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បញ្ញា សង្ខារក្ខន្ធបរិយាបន្នា សារម្មណាតិ ។ អាមន្តា ។ ញាណំ សង្ខារក្ខន្ធបរិយាបន្នំ សារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៨៩៦ ) ញាណំ សង្ខារក្ខន្ធបរិយាបន្នំ អនារម្មណំ បញ្ញា សង្ខារក្ខន្ធបរិយាបន្នា សារម្មណាតិ ។ អាមន្តា ។ សង្ខារក្ខន្ធោ ឯកទេសោ សារម្មណោ ឯកទេសោ អនារម្មណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ញាណអនារម្មណន្តិកថា

ធម្មវិចយសម្ពោជ្ឈង្គៈ ប្រកបដោយអារម្មណ៍ឬ ។ អើ ។ ញាណ ប្រកបដោយអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨៩៤) ញាណ មិនមានអារម្មណ៍ទេឬ ។ អើ ។ (ញាណ) រាប់បញ្ចូលក្នុងខន្ធណា ។ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។ សង្ខារក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សង្ខារក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨៩៥) ញាណ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ មិនមានអា-រម្មណ៍ទេឬ ។ អើ ។ បញ្ញា ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បញ្ញា ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយអារម្មណ៍ឬ ។ អើ ។ ញាណ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨៩៦) ញាណ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ មិនមានអារម្មណ៍ទេ ចុះបញ្ញា ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយអារម្មណ៍ឬ ។ អើ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយអារម្មណ៍ ខ្លះ មិនមានអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

សង្ខារក្ខន្ធោ ឯកទេសោ សារម្មណោ ឯកទេសោ អនារម្មណោតិ ។ អាមន្តា ។ វេទនាខន្ធោ សញ្ញាខន្ធោ វិញ្ញាណក្ខន្ធោ ឯកទេសោ សារម្មណោ ឯកទេសោ អនារម្មណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨៩៧) ន វត្តព្វំ ញាណំ អនារម្មណន្តិ ។ អាមន្តា ។ អរហា ចក្ខុវិញ្ញាណសមង្គី ញាណីតិ វត្តព្វោតិ ។ អាមន្តា ។ អត្ថិ តស្ស ញាណស្ស អារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ ញាណំ អនារម្មណន្តិ ។ អរហា ចក្ខុវិញ្ញាណសមង្គី បញ្ញវាតិ វត្តព្វោតិ ។ អាមន្តា ។ អត្ថិ តាយ បញ្ញាយ អារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ បញ្ញា អនារម្មណាតិ ។

ញាណំ អនារម្មណន្តិកថា ។

# អតីតារម្មណកថា

(៨៩៨) អតីតារម្មណំ ចិត្តំ អនារម្មណន្តិ ។ អាមន្តា ។ ននុ អតីតារម្មណន្តិ ។ អាមន្តា ។

សង្ខារក្ខន្ធខ្លះ ប្រកបដោយអារម្មណ៍ ខ្លះ មិនមានអារម្មណ៍ឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ និងវិញ្ញាណក្ខន្ធខ្លះ ប្រកបដោយអារម្មណ៍ ខ្លះ មិនមានអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨៩៧) បុគ្គលមិនគួរនិយាយថា ញាណ មិនមានអារម្មណ៍ទេឬ ។ អើ ។ ព្រះអរហន្ត ព្រមព្រៀងដោយចក្ខុវិញ្ញាណ គួរនិយាយថា មានញាណឬ ។ អើ ។ អារម្មណ៍ របស់ញាណនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បើដូច្នោះ ញាណ មិនមានអារម្មណ៍ទេ ។ ព្រះអរហន្ត ព្រមព្រៀងដោយចក្ខុវិញ្ញាណ គួរនិយាយថា មានបញ្ញាឬ ។ អើ ។ អារម្មណ៍ របស់បញ្ញានោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បើដូច្នោះ បញ្ញា មិនមានអារម្មណ៍ទេ ។

ចប់ ញាណអនារម្មណន្តិកថា ។

## អតីតារម្មណកថា

(៨៩៨) ចិត្ត ជាអតីតារម្មណ៍ (មានអារម្មណ៍ជាអតីត) មិនមានអារម្មណ៍ទេឬ ។ អើ ។ ក្រែង មានអារម្មណ៍ជាអតីតឬ ។ អើ ។

ហញ្ចិ អតីតារម្មណំ នោ វត រេ វត្តព្វេ អតីតារម្មណំ ចិត្តំ អនារម្មណន្តិ អតីតារម្មណំ ចិត្តំ អនារម្មណន្តិ មិច្ឆា ហញ្ចិ វា បន អនារម្មណំ នោ វត រេ វត្តព្វេ អតីតារម្មណន្តិ អនារម្មណំ អតីតារម្មណន្តិ មិច្ឆា ។

( ៨៩៩ ) អតីតារម្មណំ ចិត្តំ អនារម្មណន្តិ ។ អាមន្តា ។ ននុ អតីតំ អារព្ភ អត្ថិ អាវជ្ជនា ។បេ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ អតីតំ អារព្ភ អត្ថិ អាវជ្ជនា ។បេ។ បណិធិ នោ វត រេ វត្តព្វេ អតីតារម្មណំ ចិត្តំ អនារម្មណន្តិ ។

អតីតារម្មណកថា ។

## អនាគតារម្មណកថា

( ៩០០ ) អនាគតារម្មណំ ចិត្តំ អនារម្មណន្តិ ។ អាមន្តា ។ ននុ អនាគតារម្មណន្តិ ។ អាមន្តា ។

### អតីតារម្មណកថា

ប្រសិនបើ ចិត្ត មានអារម្មណ៍ជាអតីត មាលអ្នកដំចម្រើន អ្នកមិនគួរពោលថា ចិត្ត ជាអតីតារម្មណ៍ មិនមានអារម្មណ៍ទេ (ព្រោះពាក្យថា) ចិត្ត មានអតីតារម្មណ៍ មិនមានអារម្មណ៍ដូច្នេះ ជាពាក្យខុសទេ មួយទៀត ប្រសិនបើ ចិត្ត មិនមានអារម្មណ៍ទេ មាលអ្នកដំចម្រើន អ្នកមិនគួរពោលថា ចិត្ត មានការម្មណ៍ជាអតីតទេ (ព្រោះពាក្យថា) ចិត្ត មិនមានអារម្មណ៍ និងមានអារម្មណ៍ជាអតីតដូច្នេះ ជាពាក្យខុស ។

(៨៩៩) ចិត្ត ជាអតីតារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អើ ។ ក្រែង ការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអតីតឬ ។ អើ ។ ប្រសិនបើ ការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអតីត មាលអ្នកដំចម្រើន អ្នកមិនគួរពោលថា ចិត្ត ជាអតីតារម្មណ៍ មិនមានអារម្មណ៍ទេ ។

ចប់ អតីតារម្មណកថា ។

## អនាគតារម្មណកថា

(៩០០) ចិត្ត ជាអនាគតារម្មណ៍ (មានអារម្មណ៍ជាអនាគត) មិនមានអារម្មណ៍ទេឬ ។ អើ ។ ក្រែង មានអារម្មណ៍ជាអនាគតឬ ។ អើ ។

ហញ្ចិ អនាគតារម្មណំ នោ វត រេ វត្តព្វេ អនាគតារម្មណំ ចិត្តំ អនារម្មណន្តិ អនាគតារម្មណំ ចិត្តំ អនារម្មណន្តិ មិច្ឆា ។ ហញ្ចិ វា បន អនារម្មណំ នោ វត រេ វត្តព្វេ អនាគតារម្មណន្តិ អនារម្មណំ អនាគតារម្មណន្តិ មិច្ឆា ។

(៩០១) អនាគតារម្មណំ ចិត្តំ អនារម្មណន្តិ ។ អាមន្តា ។ ននុ អនាគតំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ អនាគតំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ នោ វត រេ វត្តព្វេ អនាគតារម្មណំ ចិត្តំ អនារម្មណន្តិ ។

(៩០២) បច្ចុប្បន្នំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ បច្ចុប្បន្នារម្មណំ ចិត្តំ សារម្មណន្តិ ។ អាមន្តា ។ អតីតំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ អតីតារម្មណំ ចិត្តំ សារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ប្រសិនបើ ( ចិត្ត ) មានអារម្មណ៍ជាអនាគត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្ត ជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេ ( ព្រោះពាក្យថា ) ចិត្ត ជាអនាគតារម្មណ៍ មិនមានអារម្មណ៍ ដូច្នេះ ជាពាក្យខុស មួយទៀត ប្រសិនបើ ចិត្ត មិនមានអារម្មណ៍ទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្ត មានអារម្មណ៍ជាអនាគតទេ (ព្រោះពាក្យថា) មិនមានអារម្មណ៍ និងមានអារម្មណ៍ជាអនាគត ដូច្នេះ ជាពាក្យខុស ។

[៩០១] ចិត្ត ជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អើ ។ ការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអនាគត ឬ ។ អើ ។ ប្រសិនបើ ការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអនាគត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្ត ជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេ ។

[៩០២] ការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវបច្ចុប្បន្ន ចុះចិត្ត ជាបច្ចុប្បន្នារម្មណ៍ ( មានអារម្មណ៍ជាបច្ចុប្បន្ន) ប្រកបដោយអារម្មណ៍ឬ ។ អើ ។ ការពិចារណា ។បេ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអតីត ចុះចិត្ត ជាអតីតារម្មណ៍ ប្រកបដោយអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

អនាគតារម្មណកថា

[៩០៣] បច្ចុប្បន្នំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ បច្ចុប្បន្នារម្មណំ ចិត្តំ សារម្មណន្តិ ។ អាមន្តា ។ អនាគតំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ អនាគតារម្មណំ ចិត្តំ សារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩០៤] អតីតំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ អតីតារម្មណំ ចិត្តំ អនារម្មណន្តិ ។ អាមន្តា ។ បច្ចុប្បន្នំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ បច្ចុប្បន្នារម្មណំ ចិត្តំ អនារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩០៥] អនាគតំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ អនាគតារម្មណំ ចិត្តំ អនារម្មណន្តិ ។ អាមន្តា ។ បច្ចុប្បន្នំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ បច្ចុប្បន្នារម្មណំ ចិត្តំ អនារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩០៦] ន វត្តព្វំ អតីតានាគតារម្មណំ ចិត្តំ អនារម្មណន្តិ ។ អាមន្តា ។ ននុ អតីតានាគតំ នត្ថីតិ ។ អាមន្តា ។ ហញ្ចិ អតីតានាគតំ នត្ថិ

អនាគតារម្មណកថា

[ ៩០៣ ] ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវបច្ចុប្បន្ន ចុះចិត្ត ជាបច្ចុប្បន្នារម្មណ៍ ប្រកបដោយអារម្មណ៍ឬ ។ អើ ។ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអនាគត ចុះចិត្ត ជាអនាគតារម្មណ៍ ប្រកបដោយអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៩០៤ ] ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអតីត ចុះចិត្ត ជាអតីតារម្មណ៍ មិនមានអារម្មណ៍ទេឬ អើ ។ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវបច្ចុប្បន្ន ចុះចិត្ត ជាបច្ចុប្បន្នារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៩០៥ ] ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអនាគត ចុះចិត្ត ជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អើ ។ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវបច្ចុប្បន្ន ចុះចិត្ត ជាបច្ចុប្បន្នារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៩០៦ ] បុគ្គលមិនគួរនិយាយថា ចិត្ត ជាអតីតារម្មណ៍ និងជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អើ ។ ក្រែងអតីត និងអនាគត មិនមានទេឬ ។ អើ ។ ប្រសិនបើ អតីតនិងអនាគត មិនមានទេ

នេច វត វេ វត្តព្វេ អតីតានាគតារម្មណំ ចិត្តំ អនារម្មណន្តិ ។ បេ ។

អនាគតារម្មណកថា ។

# វិតក្កានុបតិតកថា

(៩០៧) សព្វំ ចិត្តំ វិតក្កានុបតិតន្តិ ។ អាមន្តា ។ សព្វំ ចិត្តំ វិចារានុបតិតំ បីតានុបតិតំ សុខានុបតិតំ ទុក្ខានុបតិតំ សោមនស្សានុបតិតំ ទោមនស្សានុបតិតំ ឧបេក្ខានុបតិតំ សទ្ធានុបតិតំ វីរិយានុបតិតំ សតានុបតិតំ សមាធានុបតិតំ បញ្ញានុបតិតំ រាគានុបតិតំ ទោសានុបតិតំ ។ បេ ។ អនោត្តប្បានុបតិតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៩០៨) សព្វំ ចិត្តំ វិតក្កានុបតិតន្តិ ។ អាមន្តា ។ ននុ អត្ថិ អវិតក្កោ វិចារមត្តោ សមាធីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ អវិតក្កោ វិចារមត្តោ សមាធិ នោ វត វេ វត្តព្វេ សព្វំ ចិត្តំ វិតក្កានុបតិតន្តិ ។

(៩០៩) សព្វំ ចិត្តំ វិតក្កានុបតិតន្តិ ។ អាមន្តា ។ ននុ អត្ថិ អវិតក្កោ អវិចារោ សមាធីតិ ។ អាមន្តា ។

ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ចិត្ត ជាអតីតារម្មណ៍ និងជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេ ។ បេ ។

ចប់ អនាគតារម្មណកថា ។

# វិតក្កានុបតិតកថា

( ៩០៧ ) ចិត្តទាំងអស់ ដែលវិតក្កៈជាប់តាមឬ ។ អើ ។ ចិត្តទាំងអស់ ដែលវិចារៈជាប់តាម ដែលបីតិជាប់តាម ដែលសុខជាប់តាម ដែលទុក្ខជាប់តាម ដែលសោមនស្សជាប់តាម ដែលទោមនស្សជាប់តាម ដែលឧបេក្ខាជាប់តាម ដែលសទ្ធាជាប់តាម ដែលវីរិយៈជាប់តាម ដែលសតិជាប់តាម ដែលសមាធិជាប់តាម ដែលបញ្ញាជាប់តាម ដែលរាគៈជាប់តាម ដែលទោសៈជាប់តាម ។ បេ ។ ដែលអនោត្តប្បៈជាប់តាមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៩០៨ ) ចិត្តទាំងអស់ ដែលវិតក្កៈជាប់តាមឬ ។ អើ ។ ក្រែងសមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មានដែរឬ ។ អើ ។ ប្រសិនបើ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្តទាំងអស់ ដែលវិតក្កៈជាប់តាមទេ ។

( ៩០៩ ) ចិត្តទាំងអស់ ដែលវិតក្កៈជាប់តាមឬ ។ អើ ។ ក្រែងសមាធិ មិនមានវិតក្កៈ មិនមានវិចារៈ មានដែរឬ ។ អើ ។

ហញ្ចិ អត្ថិ អវិតក្កោ អវិចារោ សមាធិ តេន វត រេ វត្តព្វេ សព្វំ ចិត្តំ វិតក្កានុបតិតន្តិ ។

[៩១០] សព្វំ ចិត្តំ វិតក្កានុបតិតន្តិ ។ អាមន្តា ។ ននុ តយោ សមាធី វុត្តា ភគវតា សវិតក្កោ សវិចារោ សមាធិ អវិតក្កោ វិចារមត្តោ សមាធិ អវិតក្កោ អវិចា-រោ សមាធីតិ ។ អាមន្តា ។ ហញ្ចិ តយោ សមាធី វុត្តា ភគវតា សវិតក្កោ សវិចារោ សមាធិ អវិតក្កោ វិចារមត្តោ សមាធិ អវិតក្កោ អវិចារោ សមាធិ តេន វត រេ វត្តព្វេ សព្វំ ចិត្តំ វិតក្កានុបតិតន្តិ ។

**វិតក្កានុបតិតកថា ។**

# វិតក្កវិប្ផារសទ្ទកថា

[៩១១] សព្វសោ វិតក្កយតោ វិចារយតោ វិតក្កវិប្ផារោ សទ្ទោតិ ។ អាមន្តា ។ សព្វសោ ផុស-យតោ ផស្សវិប្ផារោ សទ្ទោ សព្វសោ វេទយតោ វេទ-នាវិប្ផារោ សទ្ទោ សព្វសោ សញ្ជានតោ សញ្ញាវិប្ផារោ

ប្រសិនបើ សមាធិ មិនមានវិតក្កៈ មិនមានវិចារៈ មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្តទាំងអស់ ដែលវិតក្កៈជាប់តាមទេ ។

( ៩១០ ) ចិត្តទាំងអស់ ដែលវិតក្កៈជាប់តាមឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា សមាធិ មាន ៣ គឺសមាធិ មានវិតក្កៈ មានទាំងវិចារៈ ១ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ១ សមាធិ មិនមានវិតក្កៈ មិនមានទាំងវិចារៈ ១ ឬ ។ អើ ។ ប្រសិនបើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា សមាធិ មាន ៣ គឺសមាធិ មានវិតក្កៈ មានទាំងវិចារៈ ១ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ១ សមាធិ មិនមានវិតក្កៈ មិនមានទាំងវិចារៈ ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្តទាំងអស់ ដែលវិតក្កៈជាប់តាមទេ ។

**ចប់ វិតក្កានុបតិតកថា ។**

# វិតក្កវិប្ផារសទ្ទកថា

( ៩១១ ) សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្កៈ របស់បុគ្គលកាលត្រិះរិះ កាលពិចារណា ដោយសព្វគ្រប់ឬ ។ អើ ។ សំឡេង ជាគ្រឿងផ្សាយចេញនៃផស្សៈ របស់បុគ្គលកាលពាល់ត្រូវ ដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃវេទនា របស់បុគ្គលកាលទទួលអារម្មណ៍ ដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃសញ្ញា របស់បុគ្គល

សទ្ទោ សព្វសោ ចេតយតោ ចេតនាវិប្ផារោ សទ្ទោ សព្វសោ ចិន្តយតោ ចិត្តវិប្ផារោ សទ្ទោ សព្វសោ សរតោ សតិវិប្ផារោ សទ្ទោ សព្វសោ បជានតោ បញ្ញាវិប្ផារោ សទ្ទោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៩១២) សព្វសោ វិតក្កយតោ វិចារយតោ វិតក្ក-វិប្ផារោ សទ្ទោតិ ។ អាមន្តា ។ វិតក្កវិប្ផារោ សទ្ទោ សោតវិញ្ញេយ្យោ សោតស្មឹ បដិហញ្ញតិ សោតស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ននុ វិតក្កវិប្ផារោ សទ្ទោ ន សោតវិញ្ញេយ្យោ ន សោតស្មឹ បដិហញ្ញតិ ន សោតស្ស អាបាថំ អាគច្ឆតីតិ ។ អា-មន្តា ។ ហញ្ចិ វិតក្កវិប្ផារោ សទ្ទោ ន សោតវិញ្ញេយ្យោ ន សោតស្មឹ បដិហញ្ញតិ ន សោតស្ស អាបាថំ អា-គច្ឆតិ នោ វត រេ វត្តព្វេ សព្វសោ វិតក្កយតោ វិចារយតោ វិតក្កវិប្ផារោ សទ្ទោតិ ។

វិតក្កវិប្ផារសទ្ទកថា ។

កាលចំណាំបាន ដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃចេតនា របស់បុគ្គលកាលនឹក ដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃចិត្ត របស់បុគ្គលកាលគិត ដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃសតិ របស់បុគ្គលកាលរឭក ដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃបញ្ញា របស់បុគ្គលកាលដឹង ដោយសព្វគ្រប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩១២] សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្កៈ របស់បុគ្គលកាលត្រិះរិះ កាលពិចារណា ដោយសព្វគ្រប់ឬ ។ អើ ។ សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្កៈ ជាសំឡេង ដែលគួរដឹងបានដោយត្រចៀក ប៉ះទង្គិចកន្ត្រចៀក មកកាន់គន្លងនៃត្រចៀកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែង សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្កៈ ជាសំឡេង មិនគួរដឹងដោយត្រចៀក មិនប៉ះទង្គិចកន្ត្រចៀក មិនមកកាន់គន្លងនៃត្រចៀកទេឬ ។ អើ ។ ប្រសិនបើ សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្កៈ ជាសំឡេង ដែលមិនគួរដឹងដោយត្រចៀក មិនប៉ះទង្គិចកន្ត្រចៀក មិនមកកាន់គន្លងនៃត្រចៀកទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្កៈ របស់បុគ្គលកាលត្រិះរិះ កាលពិចារណា ដោយសព្វគ្រប់ទេ ។

ចប់ វិតក្កវិប្ផារសទ្ទកថា ។

# នយជាចិត្តស្ស ហោតិកថា

(៩១៣) នយជាចិត្តស្ស ហោតិ ៗ អាមន្តា ៗ អផស្សកស្ស ហោតិ អវេទនកស្ស ហោតិ អសញ្ញកស្ស ហោតិ អចេតនកស្ស ហោតិ អចិត្តកស្ស ហោតីតិ ៗ ន ហេវំ វត្តព្វេ ៗ បេ ៗ ននុ សផស្សកស្ស ហោតិ សវេទនកស្ស ហោតិ សសញ្ញកស្ស ហោតិ សចេតនកស្ស ហោតិ សចិត្តកស្ស ហោតីតិ ៗ អាមន្តា ៗ ហញ្ចិ សផស្សកស្ស ហោតិ ៗ បេ ៗ សចិត្តកស្ស ហោតិ នោ វត រេ វត្តព្វេ នយជាចិត្តស្ស ហោតីតិ ៗ

(៩១៤) នយជាចិត្តស្ស ហោតីតិ ៗ អាមន្តា ៗ អនាវដ្ដន្តស្ស ហោតិ អនាភោគស្ស ហោតិ ៗ បេ ៗ អបណិទហន្តស្ស ហោតីតិ ៗ ន ហេវំ វត្តព្វេ ៗ បេ ៗ ននុ អាវដ្ដន្តស្ស ហោតិ អាភោគស្ស ហោតិ ៗ បេ ៗ បណិទហន្តស្ស ហោតីតិ ៗ អាមន្តា ៗ ហញ្ចិ អាវដ្ដន្តស្ស ហោតិ អាភោគស្ស ហោតិ ៗ បេ ៗ បណិទហន្តស្ស ហោតិ នោ វត រេ វត្តព្វេ នយជាចិត្តស្ស ហោតីតិ ៗ

# ឥយហាបិត្តស្ស វាចាតិកហា

(៩១៣) វាចា របស់បុគ្គលមិនពោលតាមចិត្តទេឬ ។ អើ ។ វាចា របស់បុគ្គលមិនមានផស្សៈ វាចា របស់បុគ្គលមិនមានវេទនា វាចា របស់បុគ្គលមិនមានសញ្ញា វាចា របស់បុគ្គលមិនមានចេតនា វាចា របស់បុគ្គលមិនមានចិត្តឬ ។ មិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងវាចា របស់បុគ្គលប្រកបដោយផស្សៈ វាចា របស់បុគ្គលប្រកបដោយវេទនា វាចា របស់បុគ្គលប្រកបដោយសញ្ញា វាចា របស់បុគ្គលប្រកបដោយចេតនា វាចា របស់បុគ្គលប្រកបដោយចិត្តឬ ។ អើ ។ ប្រសិនបើ វាចា របស់បុគ្គលប្រកបដោយផស្សៈ ។ បេ ។ វាចា របស់បុគ្គលប្រកបដោយចិត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វាចា របស់បុគ្គលមិនពោលតាមចិត្តទេ ។

(៩១៤) វាចា របស់បុគ្គលមិនពោលតាមចិត្តទេឬ ។ អើ ។ វាចា របស់បុគ្គលកាលមិនពិចារណា វាចា របស់បុគ្គលកាលមិនសង្រួម ។ បេ ។ វាចា របស់បុគ្គលកាលមិនតាំងចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែង វាចា របស់បុគ្គលកាលពិចារណា វាចា របស់បុគ្គលកាលសង្រួម ។ បេ ។ វាចា របស់បុគ្គលកាលតាំងចិត្តឬ ។ អើ ។ ប្រសិនបើ វាចា របស់បុគ្គលកាលពិចារណា វាចា របស់បុគ្គលកាលសង្រួម ។ បេ ។ វាចា របស់បុគ្គលកាលតាំងចិត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វាចា របស់បុគ្គលមិនពោលតាមចិត្តទេ ។

(៩១៥) នយថាចិត្តស្ស ភាសតីតិ ។ អាមន្តា ។ ននុ ភាសា ចិត្តសមុដ្ឋានា ចិត្តេន សហជាតា ចិត្តេន សហ ឯកុប្បន្នាតិ ។ អាមន្តា ។ ហញ្ចិ ភាសា ចិត្តសមុដ្ឋានា ចិត្តេន សហជាតា ចិត្តេន សហ ឯកុប្បន្នា នោ វត រេ វត្តព្វេ នយថាចិត្តស្ស ភាសតីតិ ។

(៩១៦) នយថាចិត្តស្ស ភាសតីតិ ។ អាមន្តា ។ ន ភណិតុកាមោ ភណតិ ន កថេតុកាមោ កថេតិ ន អាលបិតុកាមោ អាលបតិ ន វោហរិតុកាមោ វោហរតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ននុ ភណិតុកាមោ ភណតិ កថេតុកាមោ កថេតិ អាលបិតុកាមោ អាលបតិ វោហរិតុកាមោ វោហរតីតិ ។ អាមន្តា ។ ហញ្ចិ ភណិតុកាមោ ភណតិ កថេតុកាមោ កថេតិ អាលបិតុកាមោ អាលបតិ វោហរិតុកាមោ វោហរតិ នោ វត រេ វត្តព្វេ នយថាចិត្តស្ស ភាសតីតិ ។

(៩១៧) ន វត្តព្វំ នយថាចិត្តស្ស ភាសតីតិ ។ អាមន្តា ។ ននុ អត្ថិ កោចិ អញ្ញំ ភណិស្សាមីតិ

( ៩១៥ ) វាចា របស់បុគ្គលមិនពោលតាមចិត្តទេឬ ។ អើ ។ ក្រែងវាចា តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត កើតឡើងព្រមគ្នានឹងចិត្តឬ ។ អើ ។ ប្រសិនបើ វាចា តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត កើតឡើងព្រមគ្នានឹងចិត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វាចា របស់បុគ្គលមិនពោលតាមចិត្តទេ ។

( ៩១៦ ) វាចា របស់បុគ្គលមិនពោលតាមចិត្តទេឬ ។ អើ ។ បុគ្គល ចង់និយាយ តែមិននិយាយ ចង់ពោល តែមិនពោល ចង់ហៅ តែមិនហៅ ចង់ចរចា តែមិនចរចាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងបុគ្គល ចង់និយាយ តែងនិយាយបាន ចង់ពោល តែងពោលបាន ចង់ហៅ តែងហៅបាន ចង់ចរចា តែងចរចាបានឬ ។ អើ ។ ប្រសិនបើ បុគ្គល ចង់និយាយ តែងនិយាយបាន ចង់ពោល តែងពោលបាន ចង់ហៅ តែងហៅបាន ចង់ចរចា តែងចរចាបាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វាចា របស់បុគ្គលមិនពោលតាមចិត្តទេ ។

( ៩១៧ ) បុគ្គលមិនគួរនិយាយថា វាចា របស់បុគ្គលមិនពោលតាមចិត្តទេឬ ។ អើ ។ ក្រែងបុគ្គលនីមួយ គិតថា អាត្មាអញ នឹងនិយាយពាក្យដទៃ

អញ្ញំ ភណតិ អញ្ញំ កថេស្សាមីតិ អញ្ញំ កថេតិ អញ្ញំ អាលបិស្សាមីតិ អញ្ញំ អាលបតិ អញ្ញំ វោហរិស្សាមីតិ អញ្ញំ វោហរតីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កោចិ អញ្ញំ ភណិស្សាមីតិ អញ្ញំ ភណតិ ។ បេ ។ អញ្ញំ វោហរិស្សាមីតិ អញ្ញំ វោហរតិ តេន វត រេ វត្តព្វេ នយថាចិត្តស្ស វាចាតិ ។

នយថាចិត្តស្ស វាចាតិកថា ។

## នយថាចិត្តស្ស កាយកម្មន្តិកថា

(៩១៨) នយថាចិត្តស្ស កាយកម្មន្តិ ។ អា-មន្តា ។ អផស្សកស្ស កាយកម្មំ ។ បេ ។ អចិត្ត-កស្ស កាយម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ សផស្សកស្ស កាយកម្មំ ។ បេ ។ សចិត្តកស្ស កាយកម្មន្តិ ។ អាមន្តា ។ ហញ្ចិ សផស្សកស្ស កាយកម្មំ ។ បេ ។ សចិត្តកស្ស កាយកម្មំ នោ វត រេ វត្តព្វេ នយថាចិត្តស្ស កាយកម្មន្តិ ។

រមែងនិយាយពាក្យដទៃវិញ គិតថា អាត្មាអញ នឹងពោលពាក្យដទៃ រមែងពោលពាក្យដទៃវិញ គិតថា អាត្មាអញ នឹងហៅពាក្យដទៃ រមែងហៅពាក្យដទៃវិញ គិតថា អាត្មាអញ នឹងចរចាពាក្យដទៃ រមែងចរចាពាក្យដទៃវិញ មានឬ ។ អើ ។ ប្រសិនបើ បុគ្គលនីមួយ គិតថា អាត្មាអញ នឹងនិយាយពាក្យដទៃ រមែងនិយាយពាក្យដទៃវិញ ។ បេ ។ គិតថា អាត្មាអញ នឹងចរចាពាក្យដទៃ រមែង ចរចាពាក្យដទៃវិញ មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វាចា របស់បុគ្គល មិនពោលតាមចិត្ត ។

ចប់ នយថាចិត្តស្ស វាចាតិកថា ។

## នយថាចិត្តស្ស កាយកម្មន្តិកថា

(៩១៨) កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេឬ ។ អើ ។ កាយកម្ម របស់បុគ្គលមិនមានផស្សៈ ។ បេ ។ កាយកម្ម របស់បុគ្គល មិនមានចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងកាយកម្ម របស់បុគ្គលប្រកបដោយផស្សៈ ។ បេ ។ កាយកម្ម របស់បុគ្គលប្រកប ដោយចិត្តឬ ។ អើ ។ ប្រសិនបើ កាយកម្ម របស់បុគ្គលប្រកបដោយ ផស្សៈ ។ បេ ។ កាយកម្ម របស់បុគ្គលប្រកបដោយចិត្ត ម្នាលអ្នក ដ៏ចម្រើន អ្នកមិនគួរពោលថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេ ។

(៩១៩) ន យថាចិត្តស្ស កាយកម្មន្តិ ។ អាមន្តា ។ អនាវជ្ជន្តស្ស កាយកម្មំ ។បេ។ អបណិទហន្តស្ស កាយកម្មន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ ននុ អាវជ្ជន្តស្ស កាយកម្មំ ។បេ។ បណិទហន្តស្ស កាយកម្មន្តិ ។ អាមន្តា ។ ហញ្ចិ អាវជ្ជន្តស្ស កាយកម្មំ ។បេ។ បណិទហន្តស្ស កាយកម្មំ តេន វត រេ វត្តព្វេ ន យថាចិត្តស្ស កាយកម្មន្តិ ។

(៩២០) ន យថាចិត្តស្ស កាយកម្មន្តិ ។ អាមន្តា ។ ននុ កាយកម្មំ ចិត្តសមុដ្ឋានំ ចិត្តេន សហជាតំ ចិត្តេន សហ ឯកុប្បាទន្តិ ។ អាមន្តា ។ ហញ្ចិ កាយកម្មំ ចិត្តសមុដ្ឋានំ ចិត្តេន សហជាតំ ចិត្តេន សហ ឯកុប្បាទំ តេន វត រេ វត្តព្វេ ន យថាចិត្តស្ស កាយកម្មន្តិ ។

(៩២១) ន យថាចិត្តស្ស កាយកម្មន្តិ ។ អាមន្តា ។ ន អភិក្កមិតុកាមោ អភិក្កមតិ ន បដិក្កមិតុកាមោ បដិក្កមតិ ន អាលោកេតុកាមោ អាលោកេតិ ន វិលោកេតុកាមោ វិលោកេតិ ន សម្មិញ្ជិតុកាមោ សម្មិញ្ជេតិ ន បសារេតុកាមោ បសារេតិ ។ ន ហេវំ

[ ៩១៩ ] កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តឬ ។ អើ ។ កាយកម្ម របស់បុគ្គលកាលមិនពិចារណា ។ បេ ។ កាយកម្ម របស់បុគ្គលកាលមិនបានតាំងចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងកាយកម្ម របស់បុគ្គលកាលពិចារណា ។ បេ ។ កាយកម្ម របស់បុគ្គលកាលតាំងចិត្តឬ ។ អើ ។ ប្រសិនបើ កាយកម្ម របស់បុគ្គលកាលពិចារណា ។ បេ ។ កាយកម្ម របស់បុគ្គលកាលតាំងចិត្ត (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេ ។

[ ៩២០ ] កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តឬ ។ អើ ។ ក្រែងកាយកម្ម តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត កើតព្រមជាមួយនឹងចិត្តឬ ។ អើ ។ ប្រសិនបើ កាយកម្ម តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត កើតព្រមជាមួយនឹងចិត្ត ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេ ។

[ ៩២១ ] កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តឬ ។ អើ ។ បុគ្គល ចង់ឈានទៅមុខ តែឈានទៅមុខមិនកើត ចង់ឈានថយក្រោយ តែឈានថយក្រោយមិនកើត ចង់ក្រឡេកទៅមុខ តែក្រឡេកទៅមុខមិនកើត ចង់ក្រឡេកទៅទិសផ្សេង ៗ តែក្រឡេកទៅទិសផ្សេង ៗ មិនកើត ចង់បត់អវយវៈចូល តែបត់អវយវៈចូលមិនកើត ចង់លាអវយវៈចេញ តែលាអវយវៈចេញមិនកើតឬ ។ អ្នកមិនគួរពោលយ៉ាង

វត្តព្វេ ។ បេ ។ ននុ អភិក្កមិតុកាមោ អភិក្កមតិ បដិក្កមិតុកាមោ បដិក្កមតិ អាលោកេតុកាមោ អាលោកេតិ វិលោកេតុកាមោ វិលោកេតិ សម្មិញ្ជិតុកាមោ សម្មិញ្ជេតិ បសារេតុកាមោ បសារេតីតិ ។ អាមន្តា ។ ហញ្ចិ អភិក្កមិតុកាមោ អភិក្កមតិ ។ បេ ។ បសារេតុកាមោ បសារេតិ នោ វត រេ វត្តព្វេ នយថាចិត្តស្ស កាយកម្មន្តិ ។

(៩២២) ន វត្តព្វំ នយថាចិត្តស្ស កាយកម្មន្តិ ។ អាមន្តា ។ ននុ អត្ថិ កោចិ អញ្ញត្រ គច្ឆិស្សាមីតិ អញ្ញត្រ គច្ឆតិ ។ បេ ។ អញ្ញំ បសារេស្សាមីតិ អញ្ញំ បសារេតីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កោចិ អញ្ញត្រ គច្ឆិស្សាមីតិ អញ្ញត្រ គច្ឆតិ ។ បេ ។ អញ្ញំ បសារេស្សាមីតិ អញ្ញំ បសារេតិ តេន វត រេ វត្តព្វេ នយថាចិត្តស្ស កាយកម្មន្តិ ។

នយថាចិត្តស្ស កាយកម្មន្តិកថា ។

នេះទេ ។ បេ ។ ក្រែងបុគ្គល ចង់ឈានទៅមុខ តែងឈានទៅមុខបាន ចង់ឈានថយក្រោយ តែងឈានថយក្រោយបាន ចង់ក្រឡេកទៅមុខ តែងក្រឡេកទៅមុខបាន ចង់ក្រឡេកទៅទិសផ្សេង ៗ តែងក្រឡេកទៅទិសផ្សេង ៗ បាន ចង់បត់អវយវៈចូល តែងបត់អវយវៈចូលបាន ចង់លាអវយវៈចេញ តែងលាអវយវៈចេញបានដែរឬ ។ អើ ។ ប្រសិនបើបុគ្គល ចង់ឈានទៅមុខ តែងឈានទៅមុខបាន ។ បេ ។ ចង់លាអវយវៈចេញ តែងលាអវយវៈចេញបាន (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេ ។

(៩២២) បុគ្គលមិនគួរនិយាយថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេឬ ។ អើ ។ ក្រែងបុគ្គលទីមួយ គិតថា អាត្មាអញ នឹងទៅក្នុងទិសដទៃ តែត្រឡប់ជាទៅក្នុងទិសដទៃវិញ ។ បេ ។ គិតថា អាត្មាអញ នឹងលានូវអវយវៈដទៃ តែត្រឡប់ជាលានូវអវយវៈដទៃវិញ មានដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលទីមួយ គិតថា អាត្មាអញ នឹងទៅក្នុងទិសដទៃ តែត្រឡប់ជាទៅក្នុងទិសដទៃវិញ ។ បេ ។ គិតថា អាត្មាអញ នឹងលានូវអវយវៈដទៃ តែត្រឡប់ជាលានូវអវយវៈដទៃវិញ មានដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្ត ។

ចប់ នយថាចិត្តកាយកម្មន្តិកថា ។

# អតីតានាគតប្បច្ចុប្បន្នកថា

(៩២៣) អតីតេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អតីតំ និរុទ្ធំ វិគតំ វិបរិណតំ អត្ថង្គតំ អព្ភត្ថង្គតន្តិ ។ អាមន្តា ។ ហញ្ចិ អតីតំ និរុទ្ធំ វិគតំ វិបរិណតំ អត្ថង្គតំ អព្ភត្ថង្គតំ នោ ច វត រេ វត្តព្វេ អតីតេន សមន្នាគតោតិ ។

(៩២៤) អនាគតេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អនាគតំ អជាតំ អភូតំ អសញ្ជាតំ អនិព្វត្តំ អនភិនិព្វត្តំ អបាតុភូតន្តិ ។ អាមន្តា ។ ហញ្ចិ អនាគតំ អជាតំ អភូតំ អសញ្ជាតំ អនិព្វត្តំ អនភិនិព្វត្តំ អបាតុភូតំ នោ ច វត រេ វត្តព្វេ អនាគតេន សមន្នាគតោតិ ។

(៩២៥) អតីតេន រូបក្ខន្ធេន សមន្នាគតោ អនាគតេន រូបក្ខន្ធេន សមន្នាគតោ បច្ចុប្បន្នេន រូបក្ខន្ធេន សមន្នាគតោតិ ។ អាមន្តា ។ តីហិ រូបក្ខន្ធេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# អតីតានាគតប្បច្ចុប្បន្នកថា

(៩២៣) បុគ្គល ប្រកបដោយអតីតឬ ។ អើ ។ ក្រែងអតីត រលត់ហើយ ទៅប្រាសហើយ ប្រែប្រួលហើយ អស់ហើយ បាត់ហើយ ឬ ។ អើ ។ ប្រសិនបើ អតីត រលត់ហើយ ទៅប្រាសហើយ ប្រែប្រួលហើយ អស់ហើយ បាត់ហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រកបដោយអតីតទេ ។

(៩២៤) បុគ្គល ប្រកបដោយអនាគតឬ ។ អើ ។ ក្រែងអនាគត មិនទាន់កើត មិនទាន់មាន មិនទាន់លូតលាស់ មិនទាន់ដុះ មិនទាន់ដុះដាល មិនទាន់កើតប្រាកដទេឬ ។ អើ ។ ប្រសិនបើ អនាគត មិនទាន់កើត មិនទាន់មាន មិនទាន់លូតលាស់ មិនទាន់ដុះ មិនទាន់ដុះដាល មិនទាន់កើតប្រាកដទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រកបដោយអនាគតទេ ។

(៩២៥) បុគ្គល ប្រកបដោយរូបក្ខន្ធជាអតីត ប្រកបដោយរូបក្ខន្ធជាអនាគត ប្រកបដោយរូបក្ខន្ធជាបច្ចុប្បន្នដែរឬ ។ អើ ។ មានតែបុគ្គល ប្រកបដោយរូបក្ខន្ធ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## អតីតានាគតបច្ចុប្បន្នកថា

អតីតេហិ បញ្ចហិ ខន្ធេហិ សមន្នាគតោ អនាគតេហិ បញ្ចហិ ខន្ធេហិ សមន្នាគតោ បច្ចុប្បន្នេហិ បញ្ចហិ ខន្ធេហិ សមន្នាគតោតិ ។ អាមន្តា ។ បន្នរសហិ ខន្ធេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ ។

[៩២៦] អតីតេន ចក្ខាយតនេន សមន្នាគតោ អនាគតេន ចក្ខាយតនេន សមន្នាគតោ បច្ចុប្បន្នេន ចក្ខាយតនេន សមន្នាគតោតិ ។ អាមន្តា ។ តីហិ ចក្ខាយតនេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ ។ អតីតេហិ ទ្វាទសហិ អាយតនេហិ សមន្នាគតោ អនាគតេហិ ទ្វាទសហិ អាយតនេហិ សមន្នាគតោ បច្ចុប្បន្នេហិ ទ្វាទសហិ អាយតនេហិ សមន្នាគតោតិ ។ អាមន្តា ។ ឆត្តឹសាយតនេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ ។

[៩២៧] អតីតាយ ចក្ខុធាតុយា សមន្នាគតោ អនាគតាយ ចក្ខុធាតុយា សមន្នាគតោ បច្ចុប្បន្នាយ ចក្ខុធាតុយា សមន្នាគតោតិ ។ អាមន្តា ។ តីហិ ចក្ខុធាតូហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ ។

បុគ្គល ប្រកបដោយខន្ធ ៥ ជាអតីត ប្រកបដោយខន្ធ ៥ ជាអនាគត ប្រកបដោយខន្ធ ៥ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គល ប្រកបដោយខន្ធ ១៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៩២៦ ) បុគ្គល ប្រកបដោយចក្ខាយតនៈ ជាអតីត ប្រកបដោយចក្ខាយតនៈ ជាអនាគត ប្រកបដោយចក្ខាយតនៈ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គល ប្រកបដោយចក្ខាយតនៈ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលប្រកបដោយអាយតនៈ ១២ ជាអតីត ប្រកបដោយអាយតនៈ ១២ ជាអនាគត ប្រកបដោយអាយតនៈ ១២ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គល ប្រកបដោយអាយតនៈ ៣៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៩២៧ ) បុគ្គល ប្រកបដោយចក្ខុធាតុ ជាអតីត ប្រកបដោយចក្ខុធាតុ ជាអនាគត ប្រកបដោយចក្ខុធាតុ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គលប្រកបដោយចក្ខុធាតុ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អតីតាហិ អដ្ឋារសហិ ធាតូហិ សមន្នាគតោ អនាគតាហិ អដ្ឋារសហិ ធាតូហិ សមន្នាគតោ បច្ចុប្បន្នាហិ អដ្ឋារសហិ ធាតូហិ សមន្នាគតោតិ ។ អាមន្តា ។ ចតុប្បញ្ញាសធាតូហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៩២៨) អតីតេន ចក្ខុន្ទ្រិយេន សមន្នាគតោ អនាគតេន ចក្ខុន្ទ្រិយេន សមន្នាគតោ បច្ចុប្បន្នេន ចក្ខុន្ទ្រិយេន សមន្នាគតោតិ ។ អាមន្តា ។ តីហិ ចក្ខុន្ទ្រិយេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អតីតេហិ ពាវីសតិន្ទ្រិយេហិ សមន្នាគតោ អនាគតេហិ ពាវីសតិន្ទ្រិយេហិ សមន្នាគតោ បច្ចុប្បន្នេហិ ពាវីសតិន្ទ្រិយេហិ សមន្នាគតោតិ ។ អាមន្តា ។ ឆសដ្ឋិន្ទ្រិយេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៩២៩) ន វត្តព្វំ អតីតានាគតេហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ អត្ថិ អដ្ឋវិមោក្ខឈាយី ចតុន្នំ ឈានានំ និកាមលាភី នវន្នំ អនុបុព្វវិហារសមាបត្តីនំ លាភីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ អដ្ឋវិមោក្ខឈាយី

បុគ្គល ប្រកបដោយធាតុ ១៨ ជាអតីត ប្រកបដោយធាតុ ១៨ ជាអនាគត ប្រកបដោយធាតុ ១៨ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គល ប្រកបដោយធាតុ ៥៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩២៨) បុគ្គល ប្រកបដោយចក្ខុន្ទ្រិយ ជាអតីត ប្រកបដោយចក្ខុន្ទ្រិយ ជាអនាគត ប្រកបដោយចក្ខុន្ទ្រិយ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គល ប្រកបដោយចក្ខុន្ទ្រិយ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ប្រកបដោយឥន្ទ្រិយ ២២ ជាអតីត ប្រកបដោយឥន្ទ្រិយ ២២ ជាអនាគត ប្រកបដោយឥន្ទ្រិយ ២២ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គល ប្រកបដោយឥន្ទ្រិយ ៦៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩២៩) បុគ្គលមិនគួរនិយាយថា បុគ្គល ប្រកបដោយអតីតនិងអនាគតទេឬ ។ អើ ។ ក្រែងបុគ្គល ជាអ្នកចម្រើននូវវិមោក្ខ ៨ ជាអ្នកបានដោយមិនបាច់ប្រាថ្នា នូវឈានទាំង៤ បាននូវអនុបុព្វវិហារសមាបត្តិទាំង ៩ មានឬ ។ អើ ។ ប្រសិនបើ បុគ្គល ជាអ្នកចម្រើននូវវិមោក្ខ ៨

### តស្ស ឧទ្ទានំ

ចតុន្នំ ឈានានំ និកាមលាភី នវន្នំ អនុបុព្វវិហារសមាបត្តីនំ លាភី តេន វត រេ វត្តព្វេ អតីតានាគតេហិ សមន្នាគតោតិ ។

អតីតានាគតប្បច្ចុប្បន្នកថា ។

នវមោ វគ្គោ ។

## តស្ស ឧទ្ទានំ

អានិសំសទស្សាវិស្ស សញ្ញោជនានំ បហានំ អមតារម្មណំ សញ្ញោជនំ រូបំ សារម្មណំ អនុសយា អនារម្មណា ឃវមេវ ញាណំ អតីតានាគតារម្មណំ ចិត្តំ សព្វំ ចិត្តំ វិតក្កានុបតិតំ សព្វសោ វិតក្កយតោ វិចារយតោ វិតក្កវិប្ផារោ សទ្ទោ នយថាចិត្តស្ស វាចា តថេវ កាយកម្មំ អតីតានាគតេហិ សមន្នាគតោតិ ។

ឧទ្ទាន នៃនវមវគ្គ

ជាអ្នកបានដោយមិនបាច់ប្រាថ្នា នូវឈានទាំង ៤ បាននូវអនុបុព្វវិហារ-សមាបត្តិទាំង ៩ មាន (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល ប្រកបដោយអតីតនិងអនាគត ។

ចប់ អតីតានាគតប្បច្ចុប្បន្នកថា ។

ចប់ នវមវគ្គ ។

## ឧទ្ទាននៃនវមវគ្គនោះ គឺ

និយាយអំពី ការលះបង់ពួកសញ្ញោជនៈ របស់បុគ្គលអ្នកឃើញនូវអានិសង្ស ១ សញ្ញោជនៈ មានអមត ជាអារម្មណ៍ ១ រូប ប្រកបដោយអារម្មណ៍ ១ ពួកអនុស័យ មិនមានអារម្មណ៍ ១ ញាណ មិនមានអារម្មណ៍យ៉ាងនោះដែរ ១ ចិត្ត ជាអតីតារម្មណ៍ និងអនាគតារម្មណ៍ ១ ចិត្តទាំងអស់ មានវិតក្កៈជាប់តាម ១ សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្កៈ របស់បុគ្គលកាលត្រិះរិះ កាលពិចារណា ដោយសព្វគ្រប់ ១ វាចា របស់បុគ្គល មិនពោលតាមចិត្ត ១ កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្ត ដូច្នោះ ១ បុគ្គល ប្រកបដោយអតីតនិងអនាគត ១ ។

---

# និរោធកថា

[៩៣០] ឧបបត្តេសិយេ បញ្ចក្ខន្ធេ អនិរុទ្ធេ កិរិយា បញ្ច ខន្ធា ឧប្បជ្ជន្តីតិ ។ អាមន្តា ។ ទសន្នំ ខន្ធានំ សមោធានំ ហោតិ ទស ខន្ធា សម្មុខីភាវំ អាគច្ឆន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទសន្នំ ខន្ធានំ សមោធានំ ហោតិ ទស ខន្ធា សម្មុខីភាវំ អាគច្ឆន្តីតិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ។ បេ ។ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩៣១] ឧបបត្តេសិយេ បញ្ចក្ខន្ធេ អនិរុទ្ធេ កិរិយា ចត្តារោ ខន្ធា ឧប្បជ្ជន្តីតិ ។ អាមន្តា ។ នវន្នំ ខន្ធានំ សមោធានំ ហោតិ នវ ខន្ធា សម្មុខីភាវំ អាគច្ឆន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ នវន្នំ ខន្ធានំ សមោធានំ ហោតិ នវ ខន្ធា សម្មុខីភាវំ អាគច្ឆន្តីតិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ។ បេ ។ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩៣២] ឧបបត្តេសិយេ បញ្ចក្ខន្ធេ អនិរុទ្ធេ កិរិយា ញាណំ ឧប្បជ្ជតីតិ ។ អាមន្តា ។ ឆន្នំ ខន្ធានំ សមោធានំ ហោតិ ឆ ខន្ធា

# និរោធកថា

[៩៣០] កាលបញ្ចក្ខន្ធ ស្វែងរកកំណើត មិនទាន់រលត់ ខន្ធ ៥ ជាកិរិយា កើតឡើងឬ ៗ អើ ៗ ការប្រជុំ នៃខន្ធទាំង ១០ មាន ខន្ធទាំង ១០ មកកាន់ភាពចំពោះមុខឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ ការប្រជុំ នៃខន្ធទាំង ១០ មាន ខន្ធទាំង ១០ មកកាន់ភាពចំពោះមុខឬ ៗ អើ ៗ ការប្រជុំ នៃផស្សៈទាំងពីរ ៗ បេ ៗ នៃចិត្តទាំងពីរ មានឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ

[៩៣១] កាលបញ្ចក្ខន្ធ ស្វែងរកកំណើត មិនទាន់រលត់ ខន្ធទាំង ៤ ជាកិរិយា កើតឡើងឬ ៗ អើ ៗ ការប្រជុំ នៃខន្ធទាំង ៩ មាន ខន្ធទាំង ៩ មកកាន់ភាពចំពោះមុខឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ ការប្រជុំ នៃខន្ធទាំង ៩ មាន ខន្ធទាំង ៩ មកកាន់ភាពចំពោះមុខឬ ៗ អើ ៗ ការប្រជុំ នៃផស្ស ទាំងពីរ ៗ បេ ៗ នៃចិត្តទាំងពីរ មានឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ

[៩៣២] កាលបញ្ចក្ខន្ធ ស្វែងរកកំណើត មិនទាន់រលត់ ញាណ ជាកិរិយា កើតឡើងឬ ៗ អើ ៗ ការប្រជុំ នៃខន្ធទាំង ៦ មាន ខន្ធទាំង ៦

សម្មុខីភាវំ អាគច្ឆន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ នន្នំ ខន្ធានំ សមោធានំ ហោតិ ន ខន្ធា សម្មុខីភាវំ អាគច្ឆន្តីតិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ។ បេ ។ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៩៣៣) ឧបបត្តេសិយេ បញ្ចក្ខន្ធេ និរុទ្ធេ មគ្គោ ឧប្បជ្ជតីតិ ។ អាមន្តា ។ មតោ មគ្គំ ភាវេតិ កាល-កតោ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

និរោធកថា ។

# រូបំ មគ្គោតិកថា

(៩៣៤) មគ្គសមង្គិស្ស រូបំ មគ្គោតិ ។ អា-មន្តា ។ សារម្មណំ អត្ថិ តស្ស អាវដ្ដនា អាភោគោ សមន្នាហារោ មនសិការោ ចេតនា បត្ថនា បណិ-ធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អនារម្មណំ នត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ អា-មន្តា ។ ហញ្ចិ អនារម្មណំ នត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធិ នោ វត រេ វត្តព្វេ មគ្គសមង្គិស្ស រូបំ មគ្គោតិ ។

មកកាន់ភាពចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការ
ប្រជុំ នៃខន្ធទាំង ៦ មាន ខន្ធទាំង ៦ មកកាន់ភាពចំពោះមុខឬ ។ អើ ។
ការប្រជុំ នៃផស្សៈទាំងពីរ ។ បេ ។ នៃចិត្តទាំងពីរ មានឬ ។ អ្នកមិន
គួរពោលយ៉ាងនេះទេ ។ បេ ។

(៩៣៣) កាលបញ្ចក្ខន្ធ ស្វែងរកកំណើត រលត់ហើយ មគ្គ
កើតឡើងឬ ។ អើ ។ បុគ្គលស្លាប់ ទើបចម្រើនមគ្គ បុគ្គលធ្វើមរណ-
កាល ទើបចម្រើនមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ និរោធកថា ។

## រូបមគ្គិកថា

(៩៣៤) រូប របស់បុគ្គលព្រមព្រៀងដោយមគ្គ ជាមគ្គឬ ។
អើ ។ រូប ប្រកបដោយអារម្មណ៍ ការពិចារណា ការសង្ឃឹម ការ
ប្រមូលមក ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងចិត្តទុក
ចំពោះរូបនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែង
រូប មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះ
រូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ រូប មិនមានអារម្មណ៍
ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេ
ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប របស់បុគ្គលព្រមព្រៀង
ដោយមគ្គ ជាមគ្គទេ ។

[៩៣៥] សម្មាវាចា មគ្គោតិ ។ អាមន្តា ។ សារម្មណា អត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អនារម្មណា នត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ អនារម្មណា នត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធិ តេន វត រេ វត្តព្វេ សម្មាវាចា មគ្គោតិ ។

[៩៣៦] សម្មាកម្មន្តោ ។ បេ ។ សម្មាអាជីវោ មគ្គោតិ ។ អាមន្តា ។ សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធិ តេន វត រេ វត្តព្វេ សម្មាអាជីវោ មគ្គោតិ ។

[៩៣៧] សម្មាទិដ្ឋិ មគ្គោ សា ច សារម្មណា អត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។

[៩៣៥] សម្មាវាចា ជាមគ្គឬ ។ អើ ។ (សម្មាវាចា) ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាវាចានោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងសម្មាវាចា មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាវាចានោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ (សម្មាវាចា) មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាវាចានោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សម្មាវាចា ជាមគ្គទេ ។

[៩៣៦] សម្មាកម្មន្តៈ ។ បេ ។ សម្មាអាជីវៈ ជាមគ្គឬ ។ អើ ។ (សម្មាអាជីវៈ) ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងសម្មាអាជីវៈ មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ សម្មាអាជីវៈ មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សម្មាអាជីវៈ ជាមគ្គទេ ។

[៩៣៧] សម្មាទិដ្ឋិ ជាមគ្គ សម្មាទិដ្ឋិនោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាទិដ្ឋិនោះ មានឬ ។

## រូបំ មគ្គោតិកថា

អាមន្តា ។ សម្មាវាចា មគ្គោ សោ ច សារម្មណោ អត្ថិ តាយ អាវដ្ដនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាទិដ្ឋិ មគ្គោ សោ ច សារម្មណោ អត្ថិ តាយ អាវដ្ដនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ សម្មាកម្មន្តោ ។ បេ ។ សម្មាអាជីវោ មគ្គោ សោ ច សារម្មណោ អត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាសង្កប្បោ ។ បេ ។ សម្មាវាយាមោ ។ បេ ។ សម្មាសតិ ។ បេ ។

[៩៣៨] សម្មាសមាធិ មគ្គោ សោ ច សារម្មណោ អត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ សម្មាវាចា មគ្គោ សោ ច សារម្មណោ អត្ថិ តាយ អាវដ្ដនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាសមាធិ មគ្គោ សោ ច សារម្មណោ អត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ សម្មាកម្មន្តោ ។ បេ ។ សម្មាអាជីវោ មគ្គោ សោ ច

អើ ។ សម្មាវាចា ជាមគ្គ សម្មាវាចានោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាវាចានោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាទិដ្ឋិ ជាមគ្គ សម្មាទិដ្ឋិនោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាទិដ្ឋិនោះ មានឬ ។ អើ ។ សម្មាកម្មន្តៈ ។ បេ ។ សម្មាអាជីវៈ ជាមគ្គ សម្មាអាជីវៈនោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាសង្កប្បៈ ។ បេ ។ សម្មាវាយាមៈ ។ បេ ។ សម្មាសតិ ។ បេ ។

[៩៣៨] សម្មាសមាធិ ជាមគ្គ សម្មាសមាធិនោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មា-សមាធិនោះ មានឬ ។ អើ ។ សម្មាវាចា ជាមគ្គ សម្មាវាចានោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាវាចានោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាសមាធិ ជាមគ្គ សម្មាសមាធិនោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាសមាធិនោះ មានឬ ។ អើ ។ សម្មាកម្មន្តៈ ។ បេ ។ សម្មាអាជីវៈ ជាមគ្គ សម្មាអាជីវៈនោះឯង

សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៩៣៩) សម្មាវាចា មគ្គោ សា ច អនារម្មណា អត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ សម្មាទិដ្ឋិ មគ្គោ សា ច អនារម្មណា អត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាវាចា មគ្គោ សា ច អនារម្មណា អត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ សម្មាសង្កប្បោ ។ បេ ។ សម្មាវាយាមោ ។ បេ ។ សម្មាសតិ ។ បេ ។ សម្មាសមាធិ មគ្គោ សោ ច អនារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៩៤០) សម្មាកម្មន្តោ ។ បេ ។ សម្មាអាជីវោ មគ្គោ សោ ច អនារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសង្កប្បោ សម្មាវាយាមោ សម្មាសតិ ។ បេ ។ សម្មាសមាធិ មគ្គោ សោ ច អនារម្មណោ អត្ថិ តស្ស អាវជ្ជនា

ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩៣៩) សម្មាវាចា ជាមគ្គ សម្មាវាចា នោះឯង មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មិនមានទេឬ ។ អើ ។ សម្មាទិដ្ឋិ ជាមគ្គ សម្មាទិដ្ឋិនោះឯង មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាទិដ្ឋិនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាវាចា ជាមគ្គ សម្មាវាចានោះឯង មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាវាចានោះ មិនមានទេឬ ។ អើ ។ សម្មាសង្កប្បៈ ។ បេ ។ សម្មាវាយាមៈ ។ បេ ។ សម្មាសតិ ។ បេ ។ សម្មាសមាធិ ជាមគ្គ សម្មាសមាធិនោះឯង មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាសមាធិនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩៤០) សម្មាកម្មន្តៈ ។ បេ ។ សម្មាអាជីវៈ ជាមគ្គ សម្មាអាជីវៈនោះឯង មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មិនមានទេឬ ។ អើ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ ។ បេ ។ សម្មាសមាធិ ជាមគ្គ សម្មាសមាធិនោះឯង មិនមានអារម្មណ៍ ការពិចារណា

។បេ។ បណីតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៩៦១) ន វត្តព្វំ មគ្គសមង្គិស្ស រូបំ មគ្គោតិ ។ អាមន្តា ។ ននុ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ មគ្គោតិ ។ អាមន្តា ។ ហញ្ចិ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ មគ្គោ តេន វត រេ វត្តព្វេ មគ្គសមង្គិស្ស រូបំ មគ្គោតិ ។

រូបំ មគ្គោតិកថា ។

## បញ្ចវិញ្ញាណសមង្គិស្ស មគ្គភាវនាកថា

(៩៦២) បញ្ចវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនាតិ ។ អាមន្តា ។ ននុ បញ្ចវិញ្ញាណា ឧប្បន្នវត្ថុកា ឧប្បន្នារម្មណាតិ ។ អាមន្តា ។ ហញ្ចិ បញ្ចវិញ្ញាណា ឧប្បន្នវត្ថុកា ឧប្បន្នារម្មណា នោ វត រេ វត្តព្វេ បញ្ចវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនាតិ ។

(៩៦៣) ននុ បញ្ចវិញ្ញាណា បុរេជាតវត្ថុកា បុរេជាតារម្មណា អជ្ឈត្តិកវត្ថុកា ពាហិរារម្មណា

ៗ បេ ៗ ការតាំងចិត្តទុក ចំពោះសម្មាសមាធិនោះ មិនមានទេឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ

[៩៦១] បុគ្គលមិនគួរនិយាយថា រូប របស់បុគ្គលដែលព្រមព្រៀង ដោយមគ្គ ជាមគ្គទេឬ ៗ អើ ៗ ក្រែងសម្មាវាចា សម្មាកម្មន្ត: សម្មាអាជីវ: ជាមគ្គឬ ៗ អើ ៗ ប្រសិនបើ សម្មាវាចា សម្មាកម្មន្ត: សម្មាអាជីវ: ជាមគ្គ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូប របស់បុគ្គលដែលព្រមព្រៀង ដោយមគ្គ ជាមគ្គ ៗ

ចប់ រូបមគ្គោតិកថា ។

# បញ្ចវិញ្ញាណសមង្គិមគ្គភាវនាកថា

[៩៦២] មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយបញ្ចវិញ្ញាណ មានឬ ៗ អើ ៗ ក្រែងបញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយឬ ៗ អើ ៗ ប្រសិនបើ បញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយបញ្ចវិញ្ញាណ មានទេ ៗ

[៩៦៣] ក្រែងបញ្ចវិញ្ញាណ មានវត្ថុកើតឡើងមុន មានអារម្មណ៍កើតឡើងមុន មានវត្ថុប្រព្រឹត្តទៅខាងក្នុង មានអារម្មណ៍ខាងក្រៅ

អសម្បត្តវត្ថុកា អសម្បត្តារម្មណា អាបាថវត្ថុកា អាបាថារម្មណា ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចនុភោន្តិ ន អសមន្នាហារា ឧប្បជ្ជន្តិ ន អមនសិការា ឧប្បជ្ជន្តិ ន អព្យោកិណ្ណា ឧប្បជ្ជន្តិ ន អបុព្វំ អចរិមំ ឧប្បជ្ជន្តិ ន អញ្ញមញ្ញស្ស សមនន្តរា ឧប្បជ្ជន្តិ ។បេ។ នត្ថិ បញ្ចវិញ្ញាណា អនាភោគាតិ ។ អាមន្តា ។ ហញ្ចិ បញ្ចវិញ្ញាណា អនាភោគា នោ វត រេ វត្តព្វេ បញ្ចវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនាតិ ។

(៩៤៤) ចក្ខុវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនាតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ចក្ខុវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។

មានវត្ថុមិនប្រឡំគ្នា មានអារម្មណ៍មិនប្រឡំគ្នា មានវត្ថុផ្សេងៗគ្នា មានអារម្មណ៍ផ្សេងៗគ្នា មិនទទួល នូវគោចរវិស័យ របស់គ្នានិងគ្នា មិនកើតឡើង អំពីការមិនប្រមូលមក មិនកើតឡើង អំពីការមិនធ្វើទុកក្នុងចិត្ត មិនកើតឡើង អំពីការមិ ប្រឡូកប្រឡំគ្នា មិនកើតឡើងមិនមុន មិនក្រោយ មិនកើតឡើងក្នុងលំដាប់ស្មើនៃគ្នានិងគ្នា ។ បេ ។ ក្រែងបញ្ចវិញ្ញាណ មិនមានការពិចារណាទេឬ ។ អើ ។ ប្រសិនបើ បញ្ចវិញ្ញាណ មិនមានការពិចារណាទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយបញ្ចវិញ្ញាណ មានទេ ។

(៩៨៨) មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយចក្ខុ-វិញ្ញាណ មានឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។

## បញ្ចវិញ្ញាណសមង្គិស្ស មគ្គភាវនាកថា

អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ ។ នោ វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

(៨៤៥) ចក្ខុវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនាតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ អតីតានាគតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចក្ខុវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនាតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ ផស្សំ អារព្ភ វេទនំ អារព្ភ សញ្ញំ អារព្ភ ចេតនំ អារព្ភ ចិត្តំ អារព្ភ ចក្ខុំ អារព្ភ ។ បេ ។ កាយំ អារព្ភ សទ្ទំ អារព្ភ ។ បេ ។ ផោដ្ឋព្វំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនោវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនា មនោវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនា ចក្ខុវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនោវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនា មនោវិញ្ញាណំ អតីតានាគតំ អារព្ភ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនា ចក្ខុវិញ្ញាណំ អតីតានាគតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ

## បញ្ចវិញ្ញាណសមង្គិមគ្គភាវនាកថា

អើ ។ ប្រសិនបើ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើងទេ ។

(៩៨៥) មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយចក្ខុវិញ្ញាណ មានឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀងដោយចក្ខុវិញ្ញាណ មានឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធផស្សៈ ប្រារព្ធវេទនា ប្រារព្ធសញ្ញា ប្រារព្ធចេតនា ប្រារព្ធចិត្ត ប្រារព្ធចក្ខុ ។ បេ ។ ប្រារព្ធកាយ ប្រារព្ធសំឡេង ។ បេ ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយមនោវិញ្ញាណ មាន ឯមនោវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀងដោយចក្ខុវិញ្ញាណ មាន ឯចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយមនោវិញ្ញាណ មាន ឯមនោវិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អើ ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀងដោយចក្ខុវិញ្ញាណ មាន ឯចក្ខុវិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ

។ បេ ។ មនោវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនា មនោវិញ្ញាណំ ជតស្សំ អារព្ភ ។ បេ ។ ផោដ្ឋព្វំ អារព្ភ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនា ចក្ខុវិញ្ញាណំ ជតស្សំ អារព្ភ ។ បេ ។ ផោដ្ឋព្វំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៩៤៦) ន វត្តព្វំ បញ្ចវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី ។ បេ ។ សោតេន សទ្ទំ សុត្វា ។ បេ ។ ឃានេន គន្ធំ ឃាយិត្វា ។ បេ ។ ជិវ្ហាយ រសំ សាយិត្វា ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ បញ្ចវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនាតិ ។

បញ្ចវិញ្ញាណសមង្គិស្ស មគ្គភាវនាកថា ។

## បញ្ចវិញ្ញាណា កុសលាបីតិកថា

(៩៤៧) បញ្ចវិញ្ញាណា កុសលាបិ អកុសលាបីតិ ។

។ បេ ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយមនោវិញ្ញាណ មាន ឯមនោវិញ្ញាណ ប្រារព្ធផស្ស ។ បេ ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អើ ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយចក្ខុវិញ្ញាណ មាន ឯចក្ខុវិញ្ញាណ ប្រារព្ធផស្សៈ ។ បេ ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩៤៦] បុគ្គលមិនគួរនិយាយថា មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយបញ្ចវិញ្ញាណ មានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ ឃើញរូប ដោយចក្ខុ មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ ។ បេ ។ ឮសំឡេង ដោយត្រចៀក ។ បេ ។ ធុំក្លិន ដោយច្រមុះ ។ បេ ។ លិទ្ធរស ដោយអណ្តាត ។ បេ ។ ពាល់ត្រូវផោដ្ឋព្វៈ ដោយកាយ មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយបញ្ចវិញ្ញាណ មាន ។

ចប់ បញ្ចវិញ្ញាណសមង្គិមគ្គភាវនាកថា ។

## បញ្ចវិញ្ញាណា កុសលាបីតិកថា

[៩៤៧] បញ្ចវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មានឬ ។

## បញ្ចវិញ្ញាណា កុសលាបីតិកថា

អាមន្តា ។ ននុ បញ្ចវិញ្ញាណា ឧប្បន្នវត្ថុកា ឧប្បន្នា-
រម្មណាតិ ។ អាមន្តា ។ ហញ្ចិ បញ្ចវិញ្ញាណា ឧប្បន្ន-
វត្ថុកា ឧប្បន្នារម្មណា នោ វត រេ វត្តព្វេ បញ្ចវិញ្ញា-
ណា កុសលាបិ អកុសលាបីតិ ។ ននុ បញ្ចវិញ្ញា-
ណា បុរេជាតវត្ថុកា បុរេជាតារម្មណា អជ្ឈត្តិកវត្ថុ-
កា ពាហិរារម្មណា អសម្ភិន្នវត្ថុកា អសម្ភិន្នារម្មណា
នានាវត្ថុកា នានារម្មណា ន អញ្ញមញ្ញស្ស គោចរវិ-
សយំ បច្ចនុភោន្តិ ន អសមន្នាហារា ឧប្បជ្ជន្តិ ន អ-
មនសិការា ឧប្បជ្ជន្តិ ន អព្វោកិណ្ណា ឧប្បជ្ជន្តិ ន
អបុព្វំ អចរិមំ ឧប្បជ្ជន្តិ ន អញ្ញមញ្ញស្ស សមនន្តរា
ឧប្បជ្ជន្តិ ននុ បញ្ចវិញ្ញាណា អនាភោគាតិ ។ អាមន្តា ។
ហញ្ចិ បញ្ចវិញ្ញាណា អនាភោគា នោ វត រេ វត្តព្វេ
បញ្ចវិញ្ញាណា កុសលាបិ អកុសលាបីតិ ។

[៩៤៨] ចក្ខុវិញ្ញាណំ កុសលន្តិ ។ អាមន្តា ។
ចក្ខុវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ
។ បេ ។ ចក្ខុវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ អាម-
ន្តា ។ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ

## បញ្ចវិញ្ញាណា កុសលាបីតិកថា

អើ ។ ក្រែងបញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយឬ ។ អើ ។ ប្រសិនបើ បញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បញ្ចវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មានទេ ។ ក្រែងបញ្ចវិញ្ញាណ មានវត្ថុកើតមុន មានអារម្មណ៍កើតមុន មានវត្ថុប្រព្រឹត្តទៅខាងក្នុង មានអារម្មណ៍ខាងក្រៅ មានវត្ថុមិនប្រឡំគ្នា មានអារម្មណ៍មិនប្រឡំគ្នា មានវត្ថុផ្សេង ៗ គ្នា មានអារម្មណ៍ផ្សេង ៗ គ្នា មិនទទួលនូវគោចរវិស័យនៃគ្នានិងគ្នា មិនកើតឡើង អំពីការមិនពិចារណា មិនកើតឡើង អំពីការមិនធ្វើទុកក្នុងចិត្ត មិនកើតឡើង អំពីការមិនប្រឡូកប្រឡំគ្នា មិនកើតឡើងមិនមុនមិនក្រោយ មិនកើតឡើង ក្នុងលំដាប់ស្មើ នៃគ្នានិងគ្នា ក្រែង បញ្ចវិញ្ញាណ មិនមានកំណត់ទុកក្នុងចិត្តទេឬ ។ អើ ។ ប្រសិនបើ បញ្ចវិញ្ញាណ មិនមានកំណត់ទុកក្នុងចិត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បញ្ចវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មានទេ ។

(៩៤៨) ចក្ខុវិញ្ញាណ ជាកុសលឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើងឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ នោ វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្ប-ជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

(៩៤៩) ចក្ខុវិញ្ញាណំ កុសលម្បិ អកុស-លម្បីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ អតីតានាគតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចក្ខុ-វិញ្ញាណំ កុសលម្បិ អកុសលម្បីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ ផស្សំ អារព្ភ ។ បេ ។ ចិត្តំ អារព្ភ ។ បេ ។ ចក្ខុំ អារព្ភ ។ បេ ។ កាយំ អារព្ភ ។ បេ ។ សទ្ទំ អារព្ភ ។ បេ ។ ផោដ្ឋព្វំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនោវិញ្ញាណំ កុសលម្បិ

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ប្រសិនបើ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើងទេ ។

( ៩៤៩ ) ចក្ខុវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មានឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មានឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធផស្សៈ ។ បេ ។ ប្រារព្ធចិត្ត ។ បេ ។ ប្រារព្ធចក្ខុ ។ បេ ។ ប្រារព្ធកាយ ។ បេ ។ ប្រារព្ធសំឡេង ។ បេ ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មនោវិញ្ញាណ ជាកុសលក៏មាន

## បញ្ចវិញ្ញាណា កុសលាបីតិកថា

អកុសលម្បិ មនោវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ កុសលម្បិ អកុសលម្បិ ចក្ខុវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនោវិញ្ញាណំ កុសលម្បិ អកុសលម្បិ មនោវិញ្ញាណំ អតីតានាគតំ អារព្ភ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ កុសលម្បិ អកុសលម្បិ ចក្ខុវិញ្ញាណំ អតីតានាគតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនោវិញ្ញាណំ កុសលម្បិ អកុសលម្បិ មនោវិញ្ញាណំ ផស្សំ អារព្ភ ។ បេ ។ ចិត្តំ អារព្ភ ចក្ខុំ អារព្ភ ។ បេ ។ កាយំ អារព្ភ សទ្ទំ អារព្ភ ។ បេ ។ ផោដ្ឋព្វំ អារព្ភ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ កុសលម្បិ អកុសលម្បិ ចក្ខុវិញ្ញាណំ ផស្សំ អារព្ភ ។ បេ ។ ផោដ្ឋព្វំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៩៥០) ន វត្តព្វំ បញ្ចវិញ្ញាណា កុសលាបិ អកុសលាបីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា និមិត្តគ្គាហី ហោតិ ។ បេ ។ ន និមិត្តគ្គាហី ហោតិ ។ បេ ។

ជាអកុសលក៏មាន ឯមនោវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ឯចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មនោវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ឯមនោ-វិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អើ ។ ចក្ខុ-វិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ឯចក្ខុវិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មនោវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ឯមនោ-វិញ្ញាណ ប្រារព្ធផស្សៈ ។ បេ ។ ប្រារព្ធចិត្ត ប្រារព្ធចក្ខុ ។ បេ ។ ប្រារព្ធកាយ ប្រារព្ធសំឡេង ។ បេ ។ ប្រារព្ធផោដ្ឋព្វ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ឯចក្ខុវិញ្ញាណ ប្រារព្ធផស្សៈ ។ បេ ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៩៤០ ) បុគ្គលមិនគួរនិយាយថា បញ្ចវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មានឬ ។ អើ ។ ព្រោះព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ ឃើញរូបដោយចក្ខុ ជាអ្នកកាន់យកនូវនិមិត្ត ។ បេ ។ ជាអ្នកមិនកាន់យកនូវនិមិត្ត ។ បេ ។

សោតេន សទ្ទំ សុត្វា ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសិត្វា និមិត្តគ្គាហី ហោតីតិ ។ បេ ។ ន និមិត្តគ្គាហី ហោតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ បញ្ចវិញ្ញាណា កុសលាបិ អកុសលាបីតិ ។

បញ្ចវិញ្ញាណា កុសលាបីតិកថា ។

## បញ្ចវិញ្ញាណា សាភោគាតិកថា

(៩៤១) បញ្ចវិញ្ញាណា សាភោគាតិ ។ អាមន្តា ។ ននុ បញ្ចវិញ្ញាណា ឧប្បន្នវត្ថុកា ឧប្បន្នារម្មណាតិ ។ អាមន្តា ។ ហញ្ចិ បញ្ចវិញ្ញាណា ឧប្បន្នវត្ថុកា ឧប្បន្នារម្មណា នោ វត រេ វត្តព្វេ បញ្ចវិញ្ញាណា សាភោគាតិ ។ បេ ។ ននុ បញ្ចវិញ្ញាណា បុរេជាតវត្ថុកា បុរេជាតារម្មណា អជ្ឈត្តិកវត្ថុកា ពាហិរារម្មណា អសម្ភិន្នវត្ថុកា អសម្ភិន្នារម្មណា នានាវត្ថុកា នានារម្មណា ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចនុភោន្តិ ន អសមន្នាហារា ឧប្បជ្ជន្តិ ន អមនសិការា ឧប្បជ្ជន្តិ ន អព្វោកិណ្ណា ឧប្បជ្ជន្តិ ន អបុព្វំ អចរិមំ ឧប្បជ្ជន្តិ ននុ បញ្ចវិញ្ញាណា ន អញ្ញមញ្ញស្ស សមនន្តរា ឧប្បជ្ជន្តីតិ ។

